ហាមលក់

# សៀវភៅណែនាំស្តីអំពី "កម្មវិធីប្រឆាំងអំពើពុករលួយ សម្រាប់ធុរកិច្ចនៅកម្ពុជា"



អង្គភាពប្រឆាំងអំពើពុករលួយ

បោះពុម្ពលើកទី១ ឆ្នាំ ២០១៥
ចំនួន ៥,០០០ ក្បាល

សៀវភៅនេះ អាចទាញយកបានពីគេហទំព័ររបស់
អង្គភាពប្រឆាំងអំពើពុករលួយ
www.acu.gov.kh
សៀវភៅនេះ អាចថតចម្លង ឬបោះពុម្ពដើម្បីប្រើប្រាស់បាន!

ឧបត្ថម្ភបោះពុម្ពដោយ

ប៊ុណ្ណា រៀលធី គ្រុប
BONNA REALTY GROUP
Trust - Experience - Professional

ក្រុមហ៊ុនឈានមុខគេលើវិស័យអចលនទ្រព្យនៅកម្ពុជា **Since 1999**

BRE ប៊ុណ្ណា សេវាអចលនទ្រព្យ BONNA REAL ESTATE

BAA ប៊ុណ្ណា វាយតម្លៃទ្រព្យសម្បត្តិ BONNA ASSET APPRAISAL

BPR ប៊ុណ្ណា ស្រាវជ្រាវអចលនទ្រព្យ BONNA PROPERTY RESEARCH

ប៊ី ភី ខនសាល់ធេន
B P Consultant

- ផ្នែកប្រឹក្សា អចលនទ្រព្យ " ទិញ លក់ និង ជួល "
- ផ្នែកវាយតម្លៃ អចលនទ្រព្យ
- ផ្នែកស្រាវជ្រាវ អចលនទ្រព្យ
- ផ្នែកប្រឹក្សាផ្លូវច្បាប់

ផ្ទះលេខ ១២៦ មហាវិថី ព្រះនរោត្តម, សង្កាត់ ទន្លេបាសាក់, ខណ្ឌ ចំការមន, រាជធានីភ្នំពេញ
ទូរស័ព្ទ : (+៨៥៥ ) ២៣ ២១៦ ៥៥៦ / ២៣ ៨៦១ ៩៩៩ ទូរសា : (+៨៥៥ ) ២៣ ៩៩៣ ៣៩២
info@bonnarealty.com.kh www.bonnarealty.com.kh

ហាមលក់

# សៀវភៅណែនាំស្ដីអំពី "កម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ធុរកិច្ចនៅកម្ពុជា"



អង្គភាពប្រឆាំងអំពើពុករលួយ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

*****

*ធុរជន និងវិនិយោគិនទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ជាទីស្រឡាញ់!*

*កំណើនសេដ្ឋកិច្ចកម្ពុជាជាទីគាប់ចិត្តក្នុងទសវត្សកន្លងទៅនេះ មិនអាចកាត់ផ្តាច់បានពីតួនាទីដ៏មានសារៈសំខាន់របស់វិស័យឯកជននៅកម្ពុជាបានឡើយ ។ រាជរដ្ឋាភិបាលកម្ពុជាដែលមានរូបខ្ញុំជា នាយករដ្ឋមន្ត្រី តែងតែយកចិត្តទុកដាក់កសាងនូវបរិយាកាសធុរកិច្ចនៅកម្ពុជា ឱ្យមានការទាក់ទាញ និងអំណោយផលដល់ភាពស្ថិតស្ថេរ និងការរីកចម្រើនយូរអង្វែង ។*

*ខ្ញុំមានជំនឿថា គោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ទាក់ទងនឹងវិស័យឯកជន ដែលរាជរដ្ឋាភិបាលបានដាក់ចេញ មិនគ្រាន់តែត្រូវការនូវការប្រតិបត្តិ និងអនុវត្ត ដោយយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់ ពីសំណាក់ក្រសួងស្ថាប័នរដ្ឋ និងស្ថាប័នឯករាជ្យពាក់ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការជាចាំបាច់ នូវការចូលរួមឱ្យអស់សក្តានុពលពីសំណាក់វិស័យឯកជនផងដែរ ។ ការចូលរួមចំណែកនេះ គឺគ្មានអ្វីក្រៅពីការយកចិត្តទុកដាក់ប្រកាន់យកនូវការប្រកបធុរកិច្ច ដោយផ្អែកលើមូលដ្ឋាន និងគុណតម្លៃជាសារវន្ត មានដូចជាធុរកិច្ចដោយតម្លាភាព គណនេយ្យភាព គោរពការប្រកួតប្រជែងដោយស្មើភាព-យុត្តិធម៌ មានការទទួលខុសត្រូវចំពោះសង្គម និងដោយគោរពប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។*

*ដើម្បីសម្រេចបានគោលបំណងនេះ ខ្ញុំយល់ថា ពិតណាស់ ឆន្ទៈ និងការប្តេជ្ញារួមគ្នាដើម្បីបម្រើដល់គោលដៅរួម ជាពិសេសការមានក្របខ័ណ្ឌធុរកិច្ច ដែលគោរព និងប្រតិបត្តិនូវវប្បធម៌ស្អាតស្អំ មិនមានការប្រព្រឹត្តអំពើពុករលួយ ពីសំណាក់ធុរជន និងវិនិយោគិន គឺជា*

កត្តាសំខាន់ និងជាការចេញដំណើរ តែក្នុងពេលជាមួយគ្នានេះ វិស័យឯកជន ក៏ត្រូវមាននូវ ចំណេះដឹង និងចំណេះធ្វើ ឱ្យបានគ្រប់គ្រាន់ ហើយនិងមាននូវការអនុវត្តជាក់ស្តែង ប្រកបដោយប្រសិទ្ធភាពផងដែរ ។

អាស្រ័យដូច្នេះហើយ ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ចំពោះ អង្គភាពប្រឆាំងអំពើពុករលួយ និងតួអង្គនៃវិស័យឯកជនជាច្រើនដែលបានរួមគ្នា រៀបចំ ចងក្រង និងឈានដល់ការបោះពុម្ព **«សៀវភៅណែនាំស្តីអំពីកម្មវិធីប្រឆាំងអំពើពុករលួយ សម្រាប់ធុរកិច្ចនៅកម្ពុជា»** ដើម្បីជាឯកសារជំនួយ ជាមគ្គុទេសន៍មួយបន្ថែមទៀត សម្រាប់ជួយដល់វិស័យឯកជនទូទៅនៅកម្ពុជា ប្រកាន់យក បន្តយក និងពង្រឹងកិច្ចប្រឹងប្រែងប្រែក្លាយឆន្ទៈ និងការប្តេជ្ញាអនុវត្ត ធុរកិច្ចល្អ-ស្អាតស្អំ ឱ្យទៅជាសកម្មភាពជាក់ស្តែង ជាពិសេសតាមរយៈការពិចារណារៀបចំ បង្កើត និងពង្រឹងនូវកម្មវិធីស្តីពីការប្រឆាំងអំពើពុករលួយសម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រុមហ៊ុន-សហគ្រាស នៅក្នុងកម្រិតសមស្របមួយ ស្របតាមបរិបទ និងកាលៈទេសៈជាក់ស្តែងរៀងៗខ្លួន ។

ខ្ញុំសង្ឃឹមថា សៀវភៅណែនាំ ដែលត្រូវបានរៀបចំឡើង ដោយស្របទៅតាមបទដ្ឋាន និងបទប្បញ្ញត្តិជាតិ និងអន្តរជាតិ និងផ្អែកទៅលើការអនុវត្តល្អៗក្នុងការបំពេញធុរកិច្ចប្រកបដោយក្រមសីលធម៌ និងការអនុលោមតាមច្បាប់ជាធរមាន ពីសំណាក់សហគ្រាស និងក្រុមហ៊ុនជាច្រើន នៅតាមបណ្តាប្រទេសនានា រួមទាំងនៅកម្ពុជាផងដែរ នឹងចូលរួមចំណែកដល់ការចាក់ឫសធុរកិច្ចល្អ-ស្អាតស្អំ ឱ្យចូលកាន់តែជ្រៅទៅក្នុងបរិយាកាសវិនិយោគនៅកម្ពុជា ។

ខ្ញុំសូមជូនពរដល់ធុរជន និងវិនិយោគិនទាំងអស់ ឱ្យទទួលបាននូវការរីកចម្រើនរុងរឿង និងជោគជ័យថ្មីៗបន្ថែមទៀត លើរាល់គ្រប់កិច្ចការជំនួញរបស់ខ្លួន ទាំងនៅកម្ពុជា និងនៅលើឆាកអន្តរជាតិ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១៥

**ហ៊ុន សែន**

# កថាមុខ

ទស្សនៈមួយថា «វិស័យឯកជនដែលខ្លាំង និងដែលមាននិរន្តរភាពយូរអង្វែង គឺវិស័យឯកជនដែលប្រកបធុរកិច្ច ដោយសុចរិតភាព និងតម្លាភាព មានការប្រកួតប្រជែងដោយត្រឹមត្រូវ និងយុត្តិធម៌ និងការទទួលខុសត្រូវចំពោះសង្គម» ។ ក្នុងនាមអង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) ដែលជាស្ថាប័នឯករាជ្យ ខ្ញុំយល់ថា នេះជាទស្សនៈទំនើបដែលឆ្លុះញាំងពីតថភាពជាក់ស្តែងនៅក្នុងពិភពធុរកិច្ច នាយុគសម័យនេះ ហើយក៏ជាទស្សនៈដែលស្របជាមួយនឹងកម្មវិធី និងគោលនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ផងដែរ ។ ខ្ញុំជឿជាក់ថា ដើម្បីអនុវត្តស្របតាមទស្សនៈខាងលើ វិស័យឯកជនផ្ទាល់ចាំបាច់ត្រូវប្រកាន់យកនូវវប្បធម៌ធុរកិច្ចស្អាតស្អំ គោរពច្បាប់ និងបទប្បញ្ញត្តិជាធរមាន ហើយក៏គប្បីរៀបចំបង្កើត និងអនុវត្តនូវកម្មវិធី និងគោលនយោបាយនានា ដែលគាំទ្រដល់តម្រូវការសំខាន់ៗ ដើម្បីអាចឆ្លើយតប និងបំពេញកាតព្វកិច្ចក្នុងនាមជា ពលរដ្ឋសាជីវកម្មល្អ-ស្អាតស្អំ ។

អ.ប.ព. ដែលតែងតែចាត់ទុកវិស័យឯកជន ជាដៃគូយុទ្ធសាស្ត្រមិនអាចខ្វះបាន ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ប្តេជ្ញាផ្តល់នូវការគាំទ្រ និងការផ្លាស់ប្តូរគំនិតទស្សនៈចាំបាច់នានា ដែលអាចជួយដល់វិស័យឯកជន ក្នុងការប្រកបធុរកិច្ចក្នុងបរិយាកាសមួយដែលអំណោយផលដល់ភាពរឹងមាំ និងការរីកចម្រើនប្រកបដោយចីរភាព ។ អាស្រ័យដូច្នេះហើយទើប អ.ប.ព. បានសហការជាមួយតួអង្គជាច្រើននៃវិស័យឯកជន រៀបចំចងក្រង និងបោះពុម្ពនូវ *«សៀវភៅណែនាំស្តីអំពីកម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ធុរកិច្ចនៅកម្ពុជា»* ដើម្បីវិស័យឯកជនទូទៅ អាចយកទៅប្រើប្រាស់ តាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែងរៀងៗខ្លួន ។

សៀវភៅណែនាំបានរំលេចនូវធាតុផ្សំសំខាន់ជាមូលដ្ឋានជាច្រើន សម្រាប់វិស័យឯកជនយកទៅពិចារណា និងអនុវត្ត ក្នុងការកសាង ក៏ដូចជាពង្រឹងកម្មវិធី និងគោលនយោបាយផ្ទៃក្នុងរបស់ខ្លួន សម្រាប់ប្រតិបត្តិការធុរកិច្ច ប្រកបដោយក្រមសីលធម៌ ការអនុលោមតាមច្បាប់ជាធរមាន និងការទទួលខុសត្រូវចំពោះសង្គម ។

អ.ប.ព. សូមលើកទឹកចិត្តដល់ថ្នាក់ដឹកនាំធុរកិច្ច និងអ្នកពាក់ព័ន្ធទាំងអស់ ទាញចំណេញឱ្យអស់សក្តានុពលពីសៀវភៅណែនាំ ដើម្បីពង្រឹងកិច្ចប្រឹងប្រែងរបស់យើងរួមគ្នាក្នុងការកសាងនូវសង្គមស្អាតស្អំ ទីផ្សារយុត្តិធម៌ និងវិស័យឯកជនខ្លាំង និងមាននិរន្តរភាពយូរអង្វែង នៅកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១៥

**ទេសរដ្ឋមន្ត្រី**
**ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ**

**បណ្ឌិត ឱម យ៉ិនទៀង**

# សេចក្តីថ្លែងអំណរគុណ

*"សៀវភៅណែនាំស្តីអំពីកម្មវិធីប្រឆាំងអំពើពុករលួយ សម្រាប់ធុរកិច្ចនៅកម្ពុជា"* តំណាងឱ្យការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងរួមគ្នារបស់អង្គភាពប្រឆាំងអំពើពុករលួយ និងវិស័យឯកជន ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ជាពិសេសលើផ្នែកធុរកិច្ចនៅកម្ពុជា ស្របតាមគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធដាក់ចេញដោយ រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ។

សៀវភៅណែនាំ មិនអាចបោះពុម្ពបានទេ បើគ្មានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមយ៉ាងសកម្មពីតួអង្គ និងភាគីពាក់ព័ន្ធជាច្រើន ដែលអង្គភាពប្រឆាំងអំពើពុករលួយ ចាំបាច់ត្រូវថ្លែងអំណរគុណដោយស្មោះស្ម័គ្រ ដូចខាងក្រោម ៖

- សភាពាណិជ្ជកម្មអន្តរជាតិនៅកម្ពុជា ក្រុមហ៊ុនភេសជ្ជៈកម្ពុជា អិលធីឌី (កូកា-កូឡា) ក្រុមហ៊ុនព្រូដិនសល(ខេមបូឌា) ឡាយហ្វ៍អ៊ីស្សូរិនស៍ ភីអិលស៊ី និង ធនាគារអេស៊ីលីដា ភីអិលស៊ី ដែលបានផ្តល់ជាយោបល់ និងជាតុចូលលើខ្លឹមសារក្នុងសៀវភៅ
- ក្រុមហ៊ុន សមាគម និងសភាពាណិជ្ជកម្ម រួមមាន៖ (១)ធនាគារអេស៊ីលីដា ភីអិលស៊ី, (២)ក្រុមហ៊ុនអ៊ីអន (ខេមបូឌា) ខូអិលធីឌី, (៣)ក្រុមហ៊ុនអេប្រាធី ហ្វ៊ូដ (កម្ពុជា) អិលធីឌី, (៤)ក្រុមហ៊ុនចម្រុះសិប្បករអង្គរ, (៥)ប៊ែលធី គ្រុប, (៦)ប៊ុណ្ណា រៀលធី គ្រុប, (៧)ក្រុមហ៊ុនភេសជ្ជៈកម្ពុជាអិលធីឌី (កូកា-កូឡា), (៨)សភាពាណិជ្ជកម្មកម្ពុជា, (៩)សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា, (១០)សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា, (១១)ធនាគារកាណាឌីយ៉ា ក.អ, (១២)ឌីអេហ្វអាយ ឡាក់គី ប្រាយវេតលីមីធីត, (១៣)Ernth &Young (Cambodia) Ltd., (១៤)សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា, (១៥)ក្រុមហ៊ុនជានាវ៉ាប់រង FORTE កម្ពុជា, (១៦)Gordon & Associates, (១៧)Herbalife (Cambodia) Co. Ltd., (១៨)សភាពាណិជ្ជកម្មអន្តរជាតិនៅកម្ពុជា, (១៩)វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករ កម្ពុជា, (២០)KPMG (Cambodia) Ltd.,

(២១)ក្រុមហ៊ុនមេនូឡាយហ្វ៍ (ខេមបូឌា) ភីអ៊ិលស៊ី, (២២)តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ, (២៣)PricewaterhouseCoopers (Cambodia) Ltd., (២៤)ក្រុមហ៊ុនព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរ៉ិនស៍ ភីអិលស៊ី, (២៥)ក្រុមហ៊ុនវ៉ាន់ដាគណនេយ្យ និងសវនកម្ម, (២៦)ក្រុមហ៊ុនវីត្រាស់គ្រុប, (២៧)សមាគមសហគ្រិនវ័យក្មេងកម្ពុជា ដែលបានចូលរួមចំណែកក្នុងកិច្ចពិគ្រោះយោបល់ស្តីពីកម្មវិធីប្រឆាំងអំពើពុករលួយ សម្រាប់ធុរកិច្ចនៅកម្ពុជា ដែលត្រូវបានរៀបចំឡើង ជាមូលដ្ឋានមួយក្នុងការរៀបចំសៀវភៅណែនាំ

- ក្រុមការងារវិស័យឯកជន ក្នុងវេទិកាពជរដ្ឋាភិបាល-ផ្នែកឯកជន រួមមាន៖ (១)ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម (២)ក្រុមការងារផ្នែកទេសចរណ៍ (៣)ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា (៤)ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច (៥)ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ (៦)ក្រុមការងារផ្នែកដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ (៧)ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម (៨)ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ (៩)ក្រុមការងារផ្នែកស្រូវ-អង្ករ (១០)ក្រុមការងារផ្នែកថាមពល និងធនធានរ៉ែ ដែលបានចូលរួមចំណែកក្នុងកិច្ចពិគ្រោះយោបល់ស្តីពីកម្មវិធីប្រឆាំងអំពើពុករលួយ សម្រាប់ធុរកិច្ចនៅកម្ពុជា
- សភាពាណិជ្ជកម្មអន្តរជាតិនៅកម្ពុជា និងសមាគមពេងចក្រកាត់ដេរនៅកម្ពុជា ដែលបានសហការជួយក្នុងការបកប្រែសៀវភៅណែនាំ ពីភាសាខ្មែរ ទៅជាភាសាអង់គ្លេស
- ក្រុមការងារអង្គភាពប្រឆាំងអំពើពុករលួយ រួមមាន ឯកឧត្តម យន់ ស៊ីណាត - លោកស្រី ឃាង រតនា - លោកស្រី វេជ្ជ. ម៉ា សូយ៉ិនដា - លោក ញ៉ែម បូរ៉ា - លោកស្រី អ៊ូ ស៊ីថា - លោកស្រី កែម សុភាព - លោក ស្រ៊ិន សុវណ្ណ - និងកញ្ញា យ៉ិនទៀង ពុទ្ធិរស្មី ដែលបានចូលរួមផ្តួចផ្តើមគំនិត និងខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ រៀបចំ និងចងក្រងសៀវភៅណែនាំ ៕

# មាតិកា

ទំព័រ


I សេចក្តីផ្តើម ............................................................ ០១

II ការវាយតម្លៃហានិភ័យ ............................................................ ០៦

III ការកសាង និងអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ ............................................................ ១២

A. ការគាំទ្រ និងការប្តេជ្ញាពីថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីទប់ស្កាត់អំពើពុករលួយ .......... ១៣

B. ការកសាងកម្មវិធីប្រឆាំងអំពើពុករលួយ ............................................................ ១៧

C. ការត្រួតពិនិត្យមើលលើកម្មវិធីប្រឆាំងអំពើពុករលួយ ............................................................ ២១

D. គោលនយោបាយច្បាស់ៗសម្រាប់ទប់ស្កាត់អំពើពុករលួយ ............................................................ ២៥

E. គោលនយោបាយលម្អិតសម្រាប់ផ្នែកហានិភ័យជាក់លាក់ ............................................................ ២៩

F. ការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ដៃគូធុរកិច្ច ............................................................ ៣៩

G. ការត្រួតពិនិត្យផ្ទៃក្នុង និងការកត់ត្រាឯកសារ ............................................................ ៤៨

H. ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាល ............................................................ ៥៥

I. ការលើកទឹកចិត្តចំពោះការប្រព្រឹត្តិដោយសីលធម៌ និងការអនុលោមតាមច្បាប់.......... ៦០

J. ការស្វែងរកការណែនាំ - ការតាមរក និងការរាយការណ៍ពីការរំលោភបំពាន ........ ៦៤

K. ការឆ្លើយតបទៅនឹងការរំលោភបំពានគោលការណ៍ ............................................................ ៦៨

L. ការត្រួតពិនិត្យឡើងវិញ និងវាយតម្លៃជាប្រចាំនូវកម្មវិធីប្រឆាំងអំពើពុករលួយ .......... ៧៧

IV ការផ្លាស់ប្តូរពីកម្រិតក្រុមហ៊ុន ទៅជាចំណាត់ការរួម ............................................................ ៨៣

V សេចក្តីបញ្ចប់ ............................................................ ៨៤

ឯកសារយោង ............................................................ ៨៦

ឧបសម្ព័ន្ធ ............................................................ ៨៨

ឧបសម្ព័ន្ធ ១៖ សម្រង់មាត្រាមួយចំនួននៃច្បាប់ជាតិពាក់ព័ន្ធនឹងវិស័យឯកជន...... ៩០

ឧបសម្ព័ន្ធ ២៖ វិបសាយខ្លះពាក់ព័ន្ធនឹងកម្មវិធីប្រឆាំងអំពើពុករលួយ ................. ៩៨

# I. សេចក្តីផ្តើម

## ការចូលរួមប្រឆាំងអំពើពុករលួយរបស់វិស័យឯកជន

- ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយឱ្យមានប្រសិទ្ធភាពខ្ពស់ ទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ចាំបាច់ត្រូវធ្វើការជាមួយគ្នាជាប់ជានិច្ច ហើយធានាថាយន្តការនៃការប្រឆាំងអំពើពុករលួយត្រូវបានអនុវត្តជាប់ជាប្រចាំ ។
- មូលហេតុមួយចំនួនដែលផ្នែកឯកជន ចាំបាច់ត្រូវចូលរួមក្នុងការប្រឆាំងអំពើពុករលួយ៖
    - ជាការទទួលខុសត្រូវក្នុងការធ្វើជាពលរដ្ឋសាជីវកម្មល្អ (Good Corporate Citizen)
    - មានភស្តុតាង និងការយល់ដឹងកាន់តែច្រើនថា ការប្រឆាំងអំពើពុករលួយ ជាទង្វើដែលនាំឱ្យចំណេញដល់ផ្នែកធុរកិច្ច ហើយការមានកម្មវិធីក្រមសីលធម៌ និងអនុលោមតាមការប្រឆាំងអំពើពុករលួយល្អ ផ្តល់នូវផលចំណេញកាន់តែច្រើននាពេលអនាគត
    - ការវិវឌ្ឍន៍ដ៏លឿននៃក្របខ័ណ្ឌច្បាប់អន្តរជាតិ និងបទដ្ឋានពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្ម នៅជុំវិញពិភពលោក ក៏ជាកត្តាជំរុញឱ្យក្រុមហ៊ុនផ្តោតលើវិធានការប្រឆាំងអំពើពុករលួយសម្រាប់ជាផ្នែកមួយដ៏សំខាន់ក្នុងការការពារកេរ្តិ៍ឈ្មោះនិងផលប្រយោជន៍ដល់វិនិយោគិន និងភាគហ៊ុនិក ។
- ផលវិបាកនៃអំពើពុករលួយ ដែលមានឥទ្ធិពលមកលើធុរកិច្ច៖
    - ចំណាយកើនឡើង ដោយសារត្រូវបង់ប្រាក់មិនផ្លូវការ/ក្រៅផ្លូវការ/មិនស្របច្បាប់
    - ការពឹងផ្អែកដោយមិនអំណោយផលរវាងផ្នែកផ្គត់ផ្គង់ និងតម្រូវការចំពោះអំពើពុករលួយ (នាំឱ្យមានអំពើទារប្រាក់មិនផ្លូវការ/ក្រៅផ្លូវការ/មិនស្របច្បាប់ដោយមិនចេះចប់)
    - ខកខានឱកាសធុរកិច្ច នៅក្នុងទីផ្សារដែលត្រូវបានបន្ទំ
    - អំពើខុសច្បាប់ នឹងប្រឈមជាមួយផលវិបាកធ្ងន់ធ្ងរចំពោះទង្វើពុករលួយនេះ
    - ការប៉ាន់ប្រមាណហានិភ័យខ្ពស់ ។
- វិស័យឯកជនអាចចូលរួមចំណែកក្នុងការងារប្រឆាំងអំពើពុករលួយ តាមទម្រង់ និងចំណាត់ការជាច្រើន ។ ក្នុងនេះចំណាត់ការមួយដែលសំខាន់ គឺការប្តេជ្ញាកសាង អនុវត្ត និងពង្រឹងយន្តការប្រឆាំងអំពើពុករលួយផ្ទៃក្នុងរបស់វិស័យឯកជន ដើម្បីជាមូលដ្ឋានគ្រឹះ

សម្រាប់ការចូលរួមប្រឆាំងអំពើពុករលួយមួយដែលមានប្រសិទ្ធភាព និងប្រសិទ្ធផល ។

- ដើម្បីអនុវត្តនូវចំណាត់ការនេះ វិស័យឯកជនចាំបាច់ត្រូវកសាង និងរៀបចំផែនការ និងកម្មវិធីប្រឆាំងអំពើពុករលួយនៅតាមស្ថាប័នរបស់ខ្លួនឱ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់ ហើយក៏ត្រូវធានាឱ្យបានថាផែនការ និងកម្មវិធីនេះត្រូវបានអនុវត្តល្អ ក៏ដូចជាត្រូវបានតាមដានត្រួតពិនិត្យ និងវាយតម្លៃនូវការអនុវត្តជាប្រចាំ ដើម្បីធានានូវប្រសិទ្ធភាព ប្រសិទ្ធផល និងការវិវឌ្ឍន៍ទៅរកភាពកាន់តែប្រសើរឡើង ។ ចំណាត់ការនេះ ក៏ត្រូវបានចាត់ទុកថា ជាផ្នែកមួយដែលមានសារៈសំខាន់ជាសារវន្តសម្រាប់ការទទួលខុសត្រូវចំពោះសង្គម (Corporate Social Responsibility ឬ CSR) របស់វិស័យឯកជនផងដែរ ។

**ចំណាំ៖** CSR គឺជាការទទួលខុសត្រូវរបស់អាជីវកម្ម ឬក៏អង្គការណាមួយទៅលើផលប៉ះពាល់នៃការសម្រេចចិត្ត និងសកម្មភាពទាំងឡាយណារបស់អង្គភាពទាំងនោះ ទៅលើសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដោយតម្លាភាព និងក្រមសីលធម៌ ។ អង្គការ UN Global Compact បានជំរុញឱ្យអាជីវកម្ម និងអង្គការនានាផ្តោតទៅលើផ្នែក ៤ ធំៗ សម្រាប់ CSR៖ ១) សិទ្ធិមនុស្ស ២) បទដ្ឋានកម្លាំងពលកម្ម ៣) បរិស្ថាន និង ៤) ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

## ហេតុអ្វី សៀវភៅណែនាំស្តីអំពីកម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ធុរកិច្ចនៅកម្ពុជា ត្រូវបានរៀបចំឡើង ?

- ជាការពិតណាស់ថា ក្នុងបរិបទកម្ពុជា និងសាកលភាវូបនីយកម្ម តួអង្គក្នុងវិស័យឯកជនកាន់តែច្រើន យល់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ហើយក៏បានចូលរួមយ៉ាងសកម្មក្នុងការធានាថា ការប្រកបធុរកិច្ចរបស់ខ្លួន ត្រូវបានធ្វើឡើងដោយសុចរិតភាព តម្លាភាព និងគណនេយ្យភាព ។ តួអង្គជាច្រើនទៀត ក៏កំពុងវិវឌ្ឍន៍ខ្លួនឆ្ពោះទៅមុខនៅលើវិថីស្អាតស្អំនេះ ហើយខ្លះទៀត ក៏កំពុងរៀបចំខ្លួនជាបណ្តើរៗ ដើម្បីឈានជើងចូលមាគ៌ាដ៏បវរនេះដែរ ។
- អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) ដែលជាស្ថាប័នអនុវត្តច្បាប់ឯករាជ្យ មានបំណងចូលរួមចំណែក ជួយជ្រោមជ្រែងដល់តួអង្គឯកជន ដែលកំពុងធ្វើដំណើរលើមាគ៌ាស្អាតស្អំ ធ្វើការកសាងចាក់គ្រឹះស្អាតស្អំ និងគោរពខ្ជាប់ខ្ជួននូវបទបញ្ញត្តិច្បាប់ជា

ធរមាន សំដៅកសាងបរិយាកាសធុរកិច្ចឱ្យកាន់តែអំណោយផលដល់ការវិនិយោគ និងការប្រកួតប្រជែងដោយស្មើភាព និងយុត្តិធម៌នៅកម្ពុជា អាស្រ័យដូច្នេះហើយទើបសៀវភៅណែនាំអំពីកម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ធុរកិច្ចនៅកម្ពុជា ត្រូវបានបង្កើតឡើង ។

- សៀវភៅណែនាំ ត្រូវបានរៀបចំឡើង៖

(១) ស្របតាមគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គភាពប្រឆាំងអំពើពុករលួយ ដែលតែងតែចាត់ទុកវិស័យឯកជនជាដៃគូចាំបាច់មិនអាចខ្វះបាន ក្នុងការអនុវត្តនូវកម្មវិធី និងគោលនយោបាយប្រឆាំងអំពើពុករលួយដែលរាជរដ្ឋាភិបាលបានដាក់ចេញ ។

(២) ដោយផ្អែកលើការសិក្សាស្រាវជ្រាវ ដកស្រង់បទពិសោធន៍ពីការអនុវត្តនៅតាមបណ្តាប្រទេសនានា និងស្ថាប័នឯកជនមួយចំនួន និងជាពិសេសផ្អែកលើការចូលរួមពិគ្រោះយោបល់ពីសំណាក់ក្រុមហ៊ុន សមាគម សម្ព័ន្ធ និងសហព័ន្ធឯកជន មួយចំនួនដែលកំពុងមានប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

(៣) សម្រាប់វិស័យឯកជនទូទៅ ប្រើប្រាស់ជាប្រភពព័ត៌មាន ជាមគ្គុទេសក៍សម្រាប់ពង្រឹងការចូលរួមប្រឆាំងអំពើពុករលួយក្នុងធុរកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ។

## ការរៀបចំសៀវភៅណែនាំ

- សៀវភៅណែនាំ ត្រូវបានបែងចែកជា ៣ ផ្នែកធំៗ៖

១. ការវាយតម្លៃហានិភ័យ

២. ការកសាង និងអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ

៣. ពីការផ្លាស់ប្តូរកម្រិតក្រុមហ៊ុន ទៅជាចំណាត់ការរួម ។

- ផ្នែកនីមួយៗ ជាទូទៅ រួមមាន៖

១. សេចក្តីណែនាំអំពីខ្លឹមសារ៖ ជាការពន្យល់អំពីសារៈសំខាន់ លក្ខណៈពិសេស មូលហេតុ និងរបៀបរបបនៃការរៀបចំ និងអនុវត្តនូវផ្នែកនីមួយៗឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព សម្រាប់ការប្រឆាំងអំពើពុករលួយ ។

២. យោងបទដ្ឋានជាតិ និង/ឬអន្តរជាតិ៖ ជាការផ្តល់នូវខ្លឹមសារសង្ខេបជារួមនៃលិខិតបទដ្ឋានជាតិ និងអន្តរជាតិដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋាន សម្រាប់រៀបចំសៀវភៅ

ណែនាំ ។ បទដ្ឋានអន្តរជាតិដែលត្រូវបានប្រើជាមូលដ្ឋានសម្រាប់យោងមានច្រើនក្នុងនោះរួមមាន អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC), UN Global Compact ។ល។ ខណៈដែលបទដ្ឋានជាតិ រួមមានច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងច្បាប់ពាក់ព័ន្ធជាច្រើនទៀត ។

៣. ករណីសិក្សា៖ ជាការផ្តល់នូវឧទាហរណ៍នៃការអនុវត្តចំណាត់ការប្រឆាំងអំពើពុករលួយជាគំរូផ្សេងៗ របស់ក្រុមហ៊ុនឯកជននានា នៅកម្ពុជា និងនៅបរទេស ។

- ផ្នែកនីមួយៗ អាចត្រូវសង្ខេបខ្លឹមសារដូចខាងក្រោម៖

**ផ្នែកទី១៖ ការវាយតម្លៃហានិភ័យនៃអំពើពុករលួយ**

គឺជាការងារសំខាន់ចាំបាច់ត្រូវធ្វើ មុនអាចរៀបចំកម្មវិធីប្រឆាំងអំពើពុករលួយ ដែលអាចឆ្លើយតបនឹងតម្រូវការ និងកាលៈទេសៈជាក់ស្តែងបាន ។ ការងារនេះជាគោលការណ៍ គឺធ្វើដើម្បីកំណត់ថាតើ ហានិភ័យនៃអំពើពុករលួយមានអ្វីខ្លះ មាននៅទីណា កម្រិតណា ពេលណា ជាមួយនរណា និងដោយរបៀបណា ។

**ផ្នែកទី ២៖ ការកសាង និងអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ**

ផ្នែកនេះ រួមមានធាតុផ្សំសំខាន់ៗចំនួន ១២ គឺ៖

១. **ការគាំទ្រពីថ្នាក់ដឹកនាំកំពូល៖** ជាធាតុផ្សំចាំបាច់ ដើម្បីអាចឱ្យក្រុមហ៊ុនមួយអនុវត្តនូវវប្បធម៌ស្អាតស្អំ និងប្រឆាំងអំពើពុករលួយបាន ។ ដើម្បីឱ្យថ្នាក់ក្រោមអនុវត្តតាមដោយប្រសិទ្ធភាព ថ្នាក់លើត្រូវតែនិយាយជាគំរូ និងធ្វើជាគំរូ ។

២. **ការកសាងកម្មវិធីប្រឆាំងអំពើពុករលួយ៖** ផ្តោតសំខាន់លើចរិកលក្ខណៈចាំបាច់នានា ដែលកម្មវិធីប្រឆាំងអំពើពុករលួយ ត្រូវមាន ។

៣. **ការត្រួតពិនិត្យមើលពីលើចំពោះកម្មវិធីប្រឆាំងអំពើពុករលួយ៖** ផ្តោតលើតួនាទី និងសារៈសំខាន់របស់អ្នកត្រួតពិនិត្យពីលើ ដែលមានដូចជាក្រុមប្រឹក្សានាយក ឬតួអង្គឯករាជ្យផ្សេងពីនេះណាមួយ ។

៤. **គោលនយោបាយច្បាស់សម្រាប់ ទប់ស្កាត់អំពើពុករលួយ៖** ផ្តោតលើការដាក់ចេញនូវគោលការណ៍ច្បាស់លាស់ អ្វីដែលហាមឃាត់ អ្វីដែលអនុញ្ញាត និងអ្វីដែលត្រូវបំពេញ ដើម្បីអនុលោមតាមច្បាប់ជាធរមាន ។

**៥. គោលនយោបាយលម្អិត សម្រាប់ផ្នែកហានិភ័យជាក់លាក់៖** ផ្តោតលើការកំណត់ឱ្យច្បាស់ពីបញ្ហាជាក់លាក់មួយចំនួន ជាពិសេសទាក់ទងនឹងប្រាក់សម្រួលការងារ អំណោយ ចំណាយលើបដិសណ្ឋារកិច្ច ។ល។ និងចំណាត់ការដែលគប្បីត្រូវធ្វើទាក់ទងនឹងបញ្ហានេះ ។

**៦. ការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ដៃគូធុរកិច្ច៖** ផ្តោតលើប្រភេទនៃដៃគូធុរកិច្ច និងចំណាត់ការផ្សេងៗ ដែលគប្បីមានសម្រាប់ទប់ស្កាត់ និងជៀសវាងការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើពុករលួយពីសំណាក់ភាគីទី៣ ។

**៧. ការត្រួតពិនិត្យផ្ទៃក្នុង និងកំណត់ត្រា៖** ផ្តោតលើយន្តការនៃការត្រួតពិនិត្យផ្ទៃក្នុង និងការបង្កើត និងរក្សាទុកនូវកំណត់ត្រាធុរកិច្ចនានា ។

**៨. ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាល៖** ផ្តោតលើរបៀបរបប ក្នុងការទំនាក់ទំនងផ្តល់ព័ត៌មានផ្ទៃក្នុងឱ្យគ្នា និងការបណ្តុះបណ្តាលផ្ទៃក្នុងពីគោលនយោបាយ និងនីតិវិធីប្រឆាំងអំពើពុករលួយដល់ដៃគូធុរកិច្ច និងបុគ្គលិក ។

**៩. ការលើកទឹកចិត្តចំពោះការប្រព្រឹត្តដោយក្រមសីលធម៌ និងការអនុលោមតាមច្បាប់៖** ផ្តោតលើការលើកទឹកចិត្តក្នុងទម្រង់ផ្សេងៗ ដល់អ្នកគោរពតាមក្រមសីលធម៌ វិធាន និងបទបញ្ជារបស់ក្រុមហ៊ុន ក៏ដូចជាតាមច្បាប់ជាធរមាន ។

**១០. ការស្វែងរកការណែនាំ-ការរកឱ្យឃើញ និងការរាយការណ៍ពីការរំលោភបំពាន៖** ផ្តោតលើយន្តការផ្សេងៗដែលអាចអនុវត្តបានសម្រាប់ជួយរកឱ្យឃើញ និងការផ្តល់ព័ត៌មានអំពីបទល្មើសដែលអាចបានប្រព្រឹត្ត ។

**១១. ការដោះស្រាយការរំលោភបំពាន៖** ផ្តោតលើការបង្កើតគោលនយោបាយវិន័យ និងការឆ្លើយតបទៅនឹងការប្រព្រឹត្តបទល្មើស ។

**១២. ការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ លើកម្មវិធីប្រឆាំងអំពើពុករលួយ៖** ផ្តោតលើការបន្តកែលម្អលើកម្មវិធីប្រឆាំងអំពើពុករលួយដែលបាននឹងកំពុងអនុវត្ត ។

### ផ្នែកទី ៣៖ ពីការផ្លាស់ប្តូរ ពីកម្រិតក្រុមហ៊ុន ទៅជាចំណាត់ការរួម (កម្រិតសមាគម ឬវិស័យ)

ផ្តោតលើការផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុននីមួយៗ ជាពិសេសបើនៅក្នុងវិស័យដូចគ្នា ក្រុមហ៊ុនគប្បីសហការ និងរួមគ្នា ដើម្បីដាក់ចេញ និងអនុវត្តនូវចំណាត់ការប្រឆាំងអំពើពុករលួយ ដើម្បីភាពចំណេញ និងឈ្នះៗទាំងអស់គ្នា ។

## II. ការវាយតម្លៃហានិភ័យ

- ដើម្បីបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយឱ្យមានប្រសិទ្ធភាព និងឱ្យមានសមាមាត្រនៅក្នុងស្ថាប័នឯកជន ក្រុមហ៊ុនចាំបាច់ត្រូវយល់ដឹងពីហានិភ័យដែលអាចមាន ។ ដូច្នេះគ្រឹះនៃការអនុវត្ត និងការរក្សាបាននូវកម្មវិធីប្រឆាំងអំពើពុករលួយ គឺការវាយតម្លៃហានិភ័យអំពើពុករលួយ ដើម្បីអាចជួយដល់ការកំណត់អត្តសញ្ញាណ និងអាទិភាពនៃហានិភ័យដែលអាចមាន ។
- ហានិភ័យដែលកើតចេញពីអំពើពុករលួយ មានភាពខុសគ្នារវាងក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀត អាស្រ័យលើ៖ ទំហំ រចនាសម្ព័ន្ធ ភូមិសាស្ត្រ ប្រតិបត្តិការ ឬប្រភេទធុរកិច្ច ប្រតិបត្តិការផ្ទៃក្នុង ដូចជាលទ្ធកម្ម ការលក់ និងការធ្វើទីផ្សារ ។
- មិនមានកម្មវិធីប្រឆាំងអំពើពុករលួយមួយដែល «ត្រូវសម្រាប់គ្រប់គ្នានោះទេ» ដូច្នេះកម្មវិធីប្រឆាំងអំពើពុករលួយ ត្រូវសម្របតាមតម្រូវការជាក់ស្តែងរបស់ក្រុមហ៊ុន នីមួយៗដើម្បីកាត់បន្ថយហានិភ័យអំពើពុករលួយ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។

### ១. មុនធ្វើការវាយតម្លៃហានិភ័យ

- ជាញឹកញាប់ហានិភ័យត្រូវបានគិតថាផ្តល់ផលអវិជ្ជមាន ហើយក្រុមហ៊ុនខ្លះមិនចង់ធ្វើការវាយតម្លៃពីហានិភ័យជាផ្លូវការទេ ព្រោះខ្លាចមានទស្សនទាន ឬពាក្យចចាមអារាមអវិជ្ជមាន ។
- ជាក់ស្តែងគ្មានក្រុមហ៊ុនណា មានប្រព័ន្ធការពារពីការឆ្លងអំពើពុករលួយទេ ហើយហានិភ័យផ្តល់ផលអវិជ្ជមាន តែនៅពេលណាពួកគេមិនយកចិត្តទុកដាក់ និងនៅពេលមានផលវិបាក ដែលមិនបានរំពឹងទុកមុនប៉ុណ្ណោះ ។
- មុនធ្វើការវាយតម្លៃហានិភ័យ ក្រុមហ៊ុនគប្បីកំណត់៖

#### (១) តួនាទីក្នុងការវាយតម្លៃ និងការទទួលខុសត្រូវ

- ក្រុមហ៊ុន ត្រូវធានាថា បុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រង និងធ្វើការវាយតម្លៃហានិភ័យបាន មានគ្រប់គ្រាន់
- សម្រាប់ក្រុមហ៊ុនធំៗ និងមានវិមជ្ឈការ បុគ្គលិកនៅស្នាក់ការកណ្តាល និងសាខាអាចទទួលធ្វើការវាយតម្លៃហានិភ័យ តាមរយៈការធ្វើទំនាក់ទំនងជាមួយបុគ្គលិកដែលងាយរងគ្រោះនឹងហានិភ័យអំពើពុករលួយ ដូចជាផ្នែកលក់ លទ្ធកម្ម ។ល។

(២) <u>ដំណើរការវាយតម្លៃ</u>

ត្រូវកំណត់សកម្មភាព និងដែនកំណត់នៃផែនការវាយតម្លៃឱ្យបានច្បាស់ ដូចជា៖

- ពេលវេលានៃការវាយតម្លៃហានិភ័យ
- ភាពញឹកញាប់នៃការវាយតម្លៃហានិភ័យ (ប្រចាំខែ ឬប្រចាំឆ្នាំ)
- ប្រភពនៃការកំណត់អត្តសញ្ញាណហានិភ័យ
- ការប្រមូលព័ត៌មាន
- ដំណើរការសម្រាប់ការវាយតម្លៃហានិភ័យ
- បុគ្គលត្រូវទទួលការវាយតម្លៃហានិភ័យ (ដូចជាបុគ្គលិក ដៃគូធុរកិច្ច និងភាគីពាក់ព័ន្ធ)
- កំណត់អត្តសញ្ញាណ ប្រមូលចងក្រង និងសំយោគព័ត៌មាន
- រាយការណ៍ផ្ទៃក្នុង និងផ្ទៃក្រៅពីលទ្ធផល ។

**ចំណាំ៖** ការវាយតម្លៃហានិភ័យ អាចធ្វើបានប្រសិទ្ធភាព និងប្រសិទ្ធផលបំផុត ប្រសិនបើធ្វើដោយភ្ជាប់ទៅនឹងដំណើរការនៃការងារដែលមានស្រាប់រួចហើយ ។

(៣) <u>ការត្រួតពិនិត្យ</u>

ចាំបាច់ត្រូវធ្វើឡើង ដើម្បីធានាថា ការវាយតម្លៃហានិភ័យធ្វើត្រឹមត្រូវតាមដំណើរការប្រតិបត្តិការការងារដែលបានកំណត់ ។

## ២. <u>ដំណើរការ</u>

- ដំណើរការវាយតម្លៃហានិភ័យ រួមមាន៖

(១) <u>កំណត់អត្តសញ្ញាណហានិភ័យ</u>

ប្រភពខាងក្នុង និងខាងក្រៅអង្គភាព ជាមូលដ្ឋានសំខាន់ក្នុងការកំណត់អត្តសញ្ញាណហានិភ័យទាក់ទងអំពើពុករលួយ ។ ប្រភពទាំងនេះ រួមមាន៖

- ពិគ្រោះយោបល់ជាមួយបុគ្គលិកខាងក្នុង និងបើចាំបាច់ត្រូវពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធខាងក្រៅទៀត ដូចជាសហជីពពាណិជ្ជកម្ម និងដៃគូធុរកិច្ច
- ព័ត៌មានពីអំពើពុករលួយដែលធ្លាប់បានកើតឡើងនៅពេលមុនៗ ជួយឱ្យក្រុមហ៊ុនមើលឃើញពីស្ថានភាពបម្រុងនឹងកើត កាលៈទេសៈ និងឱកាសទប់ស្កាត់ ទាំងនៅក្នុងក្រុមហ៊ុន និងនៅក្រៅក្រុមហ៊ុន
- អាចជួលទីប្រឹក្សាពីខាងក្រៅ ឬដកបទពិសោធន៍ពីក្រុមហ៊ុនផ្សេងៗ

- សិក្សាពីវិធីសាស្ត្រល្អៗក្នុងការវាយតម្លៃហានិភ័យ ពីប្រភពផ្សេងៗ ដែលអាចមាន
- សិក្សា និងពិនិត្យពីតម្រូវការច្បាប់ និងវិធានការផ្សេងៗ៖ អាចបង្ហាញថាប្រតិបត្តិការបែបណា ពាក់ព័ន្ធនឹងអំពើពុករលួយ ឧទា. ការិយាធិបតេយ្យ (ប្រាក់សម្រួលការងារ) ដើម្បីសុំអាជ្ញាប័ណ្ណ ។ ការសិក្សាអាចជួយឱ្យក្រុមហ៊ុនដឹងថា ត្រូវធ្វើអ្វីដើម្បីជៀសវាងការប្រព្រឹត្តមិនត្រឹមត្រូវ ។

(២) <u>កំណត់អាទិភាពហានិភ័យ</u>

ការកំណត់អាទិភាពហានិភ័យអំពើពុករលួយ អាចធ្វើឡើងបាន តាមរយៈ៖

- បែបបរិមាណ និង/ឬគុណភាព៖ បូកបញ្ចូលគ្នានូវតម្លៃ និង/ឬចំនួន សម្រាប់ផលប៉ះពាល់នៃការកើតឡើង និងលទ្ធភាពដែលអាចនឹងកើតឡើង (កំណត់អាទិភាពហានិភ័យដែលអាចងាយនឹងកើតឡើងបំផុត និងផលប៉ះពាល់ខ្លាំងបំផុត)
- ផលប៉ះពាល់នៃការកើតឡើង៖ ការប៉ាន់ស្មាននៃផលវិបាកអវិជ្ជមាន តាមច្បាប់ពាណិជ្ជកម្ម និងកេរ្តិ៍ឈ្មោះក្រុមហ៊ុន (ការពិន័យ ការហាមឃាត់ ការផ្សាយព័ត៌មានមិនល្អ ចំណាយលើផ្លូវច្បាប់ ឬពេលវេលាចំណាយលើរឿងក្តី)
- លទ្ធភាពដែលអាចកើតឡើង៖ ក្នុង ១២-២៤ ខែខាងមុខ ប្រសិនបើហានិភ័យមានកម្រិតខ្ពស់ នោះអំពើពុករលួយងាយនឹងកើតឡើង ។

(៣) <u>កាត់បន្ថយហានិភ័យ</u>

ដើម្បីកាត់បន្ថយលទ្ធភាពដែលអាចកើតឡើង និង/ឬផលវិបាកនៃហានិភ័យអំពើពុករលួយ ក្រុមហ៊ុនគប្បី៖

- បង្កើនការត្រួតពិនិត្យលើការគ្រប់គ្រង (គោលការណ៍អនុម័តភ្នែក ៤ = យ៉ាងតិចមានមនុស្ស ២នាក់ចូលរួម) សម្រាប់ការជួលភ្នាក់ងារផ្នែក្រៅ ឬការពាក់ព័ន្ធជាមួយភាគីទី៣
- បណ្តុះបណ្តាលដល់បុគ្គលិកផ្សេងៗ ដែលប្រឈមនឹងការទាមទារប្រាក់ក្រៅច្បាប់ពីសំណាក់មន្ត្រីសាធារណៈពាក់ព័ន្ធ
- បង្កើនការប្រាស្រ័យទាក់ទងជាមួយថ្នាក់ដឹកនាំកម្រិតមធ្យម (ឧទា. និយាយថ្លែងពីការប្រឆាំងអំពើពុករលួយនៅក្នុងព្រឹត្តិការណ៍នានា ដែលរៀបចំដោយក្រុមហ៊ុន)
- អនុវត្តការត្រួតពិនិត្យខាងក្នុងអង្គភាពដោយស្វ័យប្រវត្តិ ដើម្បីវិភាគលំហូរនៃការបង់ប្រាក់សម្រាប់កិច្ចសន្យារយៈពេលវែង និងដែលមានភាពស្មុគ្រស្មាញ
- បង្កើនការយកចិត្តទុកដាក់ស្គាល់អ្នកផ្គត់ផ្គង់សំខាន់ៗ ឬការវិនិយោគធំៗ

- ចូលរួមក្នុងគំនិតផ្តួចផ្តើមសកម្មភាពរួម (ជាមួយក្រុមហ៊ុននៅក្នុងឧស្សាហកម្មដូចគ្នា)
- អនុវត្តវិធានការបន្ថែមផ្សេងៗ ដើម្បីជៀសវាងប្រតិបត្តិការណាដែលមានហានិភ័យ - ទីផ្សារដែលមានហានិភ័យខ្ពស់ ។ល។
- រក្សាទុកឯកសារនៃការវាយតម្លៃហានិភ័យ ដើម្បីបង្កើនគុណភាពវាយតម្លៃ និងសម្រាប់ជាមូលដ្ឋាន ក្នុងការវាយតម្លៃនាពេលអនាគត ។ ឯកសារទាក់ទងនឹងវិចារណកម្ម និងកាលៈទេសៈជាក់ស្តែងទាក់ទងនឹងហានិភ័យតូចតាច ក៏គួររក្សាទុកដែរ
- ជំរុញការទូទាត់ជាអតិបរមាតាមប្រព័ន្ធធនាគារដើម្បីកាត់បន្ថយទំនាក់ទំនងរវាងបុគ្គល និងបុគ្គល ឬបុគ្គល និងសាច់ប្រាក់ ។

## ៣. ប្រភេទហានិភ័យទាក់ទងអំពើពុករលួយ

- ហានិភ័យមាន ៣ ប្រភេទ៖

(១) ហានិភ័យច្បាប់៖ ទាក់ទងនឹងទណ្ឌកម្មតាមផ្លូវច្បាប់ ចំពោះអំពើពុករលួយ (ទោសទណ្ឌ សំណងព្យសនកម្ម ជាប់ពន្ធនាគារ)

(២) ហានិភ័យពាណិជ្ជកម្ម និងប្រតិបត្តិការ៖ ទាក់ទងនឹងផលប៉ះពាល់អវិជ្ជមានលើសកម្មភាពប្រចាំថ្ងៃ ដូចជា ការទិញ ការផលិត ការលក់ ការជួល និងការវិនិយោគ (ការហាមឃាត់ពីការដេញថ្លៃសាធារណៈ-លក្ខខណ្ឌហិរញ្ញប្បទានមិនអំណោយផល)

(៣) ហានិភ័យកេរ្តិ៍ឈ្មោះ៖ ទាក់ទងនឹងមុខមាត់ក្រុមហ៊ុន និងបុគ្គលិក ក្នុងចំណោមធុរជនដូចគ្នា គ្រួសារ មិត្តភក្តិ និងសាធារណជនទូទៅ (នាំឱ្យធ្លាក់ចុះការលក់ ឬបាត់ការទាក់ទាញការវិនិយោគ) ។

**ចំណាំ៖** កម្រិតទោសទណ្ឌ គឺអាស្រ័យលើទីកន្លែងដែលក្រុមហ៊ុនស្ថិតនៅ - របៀបពុករលួយ - ទំនាក់ទំនងជាមួយដៃគូធុរកិច្ច និងរចនាសម្ព័ន្ធរបស់ក្រុមហ៊ុនផ្ទាល់ ។

- ក្នុងការរៀបចំកម្មវិធីប្រឆាំងអំពើពុករលួយ ក្រុមហ៊ុនត្រូវគិតពីឧស្សាហកម្ម និងទីតាំងភូមិសាស្ត្រ ព្រោះប្រភេទឧស្សាហកម្ម និងភូមិសាស្ត្រខ្លះមានអំពើពុករលួយខ្លាំង និងអាចមានឥទ្ធិពលដល់ទីផ្សារដែលក្រុមហ៊ុនកំពុងប្រកបអាជីវកម្ម ហើយក៏អាចមានផលប៉ះពាល់ដល់កម្រិតនៃការប្រកួតប្រជែង និយាម និងទំនៀមទម្លាប់ ក៏ដូចជាការរំពឹងទុកពីភាគីពាក់ព័ន្ធ ដូចជាអ្នកផ្គត់ផ្គង់ អតិថិជន និងមន្ត្រីរាជការ ។
- ប្រភេទធុរកិច្ចដែលមានហានិភ័យខ្ពស់៖ មានដូចជា ភ្នាក់ងារលក់ - អ្នកម៉ៅការបន្ត - បុគ្គលិកច្រើនប្រភេទ - ពឹងផ្អែកលើអាជ្ញាប័ណ្ណសំខាន់ៗ និងកិច្ចសន្យាស្មុគស្មាញ ឬផ្តោត

ទៅលើហិរញ្ញវត្ថុរយៈពេលខ្លី ។ល។

- វប្បធម៌ក្រុមហ៊ុន ដើរតួសំខាន់៖
  - វប្បធម៌ផ្អែកលើការប្រកួតប្រជែងខ្លាំងក្លា - កម្រិតនៃទំនុកចិត្តទាប និងសុចរិតភាពទាប នាំឱ្យងាយពុករលួយ
  - វប្បធម៌ស្មោះត្រង់ មានការចូលរួម និងមានតម្លៃសីលធម៌ នាំឱ្យមានអំពើពុករលួយតិច
- ប្រព័ន្ធលើកទឹកចិត្តរបស់ក្រុមហ៊ុនក៏សំខាន់ ហើយគួរត្រូវបានបញ្ចូលក្នុងការវាយតម្លៃហានិភ័យផងដែរ ។

## ៤. ការកត់ត្រាលទ្ធផលនៃការវាយតម្លៃហានិភ័យ

ការកត់ត្រាមានច្រើនរបៀប ។ ខាងក្រោមជាឧទាហរណ៍មួយ៖

ទីតាំង/តំបន់៖ ...........

ធុរកិច្ចផ្នែក៖ ..........................

| កត្តាហានិភ័យពុករលួយ | ហានិភ័យពុករលួយ | ប្រភេទហានិភ័យ | លទ្ធភាពអាចកើត | ផលប៉ះពាល់ | ផលវិបាកនៃហានិភ័យកើតពីនេះ | ចំណាត់ការប្រឆាំងអំពើពុករលួយ | ចំណាត់ថ្នាក់នៃចំណាត់ការ | ចំណាត់ថ្នាក់ហានិភ័យដែលនៅសល់ |
|---|---|---|---|---|---|---|---|---|
| បរិយាកាសធុរកិច្ចក្នុងស្រុក | សូកប៉ាន់មន្ត្រីរាជការ | ការបង់ប្រាក់ក្រៅផ្លូវការទៅឱ្យមន្ត្រីរាជការដើម្បីទទួលបានអាជ្ញាប័ណ្ណ | មធ្យម | ខ្ពស់ | ខ្ពស់ | -គោលនយោបាយនិងនីតិវិធីប្រឆាំងអំពើពុករលួយទាក់ទងនឹងការបង់ប្រាក់ជូនមន្ត្រីរាជការ<br>-ការបណ្តុះបណ្តាលបុគ្គលិក<br>-សវនកម្មប្រឆាំងអំពើពុករលួយប្រចាំឆ្នាំលើការបង់ប្រាក់ជូនមន្ត្រីរាជការ | ប្រសិទ្ធភាព | មធ្យម |

## សម្គាល់

+ បញ្ហាប្រឈម និងឱកាសសម្រាប់សហគ្រាសធុនតូច និងមធ្យម (Small and Medium Enterprises – SMEs)

- សហគ្រាសធុនតូច និងមធ្យម (SMEs) គប្បីត្រូវកំណត់ហានិភ័យពាក់ព័ន្ធ និងជានាថាកម្មវិធីប្រឆាំងអំពើពុករលួយខ្លួន អាចដោះស្រាយបញ្ហាហានិភ័យទាំងនេះបាន
- ដោយសារ SMEs មានអង្គការចាត់តាំងមិនស្មុគស្មាញ និងបុគ្គលិកតិច ដូច្នេះ SMEs ងាយស្រួលកំណត់ហានិភ័យ ដោយការស៊ើបសួរផ្ទាល់ៗតែម្តង
- SMEs គួរសហការជាមួយ SMEs ដទៃទៀត ឬសភាពាណិជ្ជកម្ម សមាគម និងសហជីពក្នុងភូមិសាស្ត្រ ឬឧស្សាហកម្មដូចគ្នា ឬក៏អាចផ្សេងពីគ្នា ដើម្បីប្រមូលព័ត៌មានទាក់ទងនឹងហានិភ័យអំពើពុករលួយ និងកំណត់ជម្រើសកាត់បន្ថយផលប៉ះពាល់ ។

+ ការរាយការណ៍

- ក្រុមហ៊ុនគ្រប់ទំហំ គប្បីរាយការណ៍ ពីកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយរបស់ខ្លួនដោយ៖
    - ពណ៌នាពីនីតិវិធីវាយតម្លៃហានិភ័យ (ធ្វើញឹកញាប់ប៉ុណ្ណា ផ្នែកណានៃក្រុមហ៊ុនទទួលខុសត្រូវ ការឆ្លើយតបនឹងលទ្ធផលនៃការវាយតម្លៃហានិភ័យ)
    - ពណ៌នាពីផ្នែក និងសាខា ដែលបានធ្វើការវាយតម្លៃហានិភ័យ
- ក្រុមហ៊ុនអាចផ្តល់ព័ត៌មានជាបរិមាណ និងគុណភាព និងលើកឡើងពីចំណាត់ការដែលបានធ្វើ ឬលទ្ធផលដែលបានទទួល ។

## III. ការកសាង និងការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ

- កម្មវិធីនេះ ចាំបាច់ត្រូវមានអន្តរទំនាក់ទំនងជាមួយក្របខ័ណ្ឌក្រមសីលធម៌ និងការអនុលោមតាមច្បាប់ទូទៅរបស់ក្រុមហ៊ុន ដើម្បីមានប្រសិទ្ធភាព ។
- គ្រប់ក្រុមហ៊ុនគួរមានការរាយការណ៍ពីកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយរបស់ខ្លួន ។ ការរាយការណ៍ គឺជាការបង្ហាញនូវភាពម៉ឺងម៉ាត់ ក្នុងការប្ដេជ្ញាទប់ស្កាត់ និងការប្រឆាំងអំពើពុករលួយ ក៏ដូចជាការប្ដេជ្ញាចិត្តលើការគោរពតាមតម្លៃមូលដ្ឋាន នៃសុចរិតភាព តម្លាភាព និងគណនេយ្យភាព ។
- ការរាយការណ៍ពីស្ថានភាព និងការអនុវត្តកម្មវិធីនេះ ដល់បុគ្គលិក ដៃគូធុរកិច្ច ភាគហ៊ុនិកផ្សេងៗទៀត ជួយពង្រឹងកម្មវិធីប្រឆាំងអំពើពុករលួយផ្ទៃក្នុង តាមរយៈការបង្កើនតម្លាភាព ពង្រឹងកេរ្តិ៍ឈ្មោះ និងភាពជឿទុកចិត្តបានរបស់ក្រុមហ៊ុន ។
- ការរាយការណ៍ក៏ផ្ដល់នូវមូលដ្ឋានសម្រាប់វាស់វែងវឌ្ឍនភាព ការកំណត់ការប្រៀបធៀប (Benchmark) និងការរៀនពីគ្នានឹងគ្នាដែរ ។ ការរាយការណ៍ក៏ទប់ស្កាត់កុំឱ្យធ្វើខុស និងជួយសម្រួលឱ្យមានការពិភាក្សាដោយចំហ និងបង្កើននូវបទដ្ឋានប្រឆាំងអំពើពុករលួយផងដែរ ។
- កម្មវិធីប្រឆាំងអំពើពុករលួយ គប្បីមាននូវធាតុផ្សំជាច្រើន ដែលនឹងត្រូវរៀបរាប់ដោយពិស្ដារជាបន្តបន្ទាប់ដូចខាងក្រោម៖

## A. ការគាំទ្រ និងការប្ដេជ្ញាពីថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីទប់ស្កាត់អំពើពុករលួយ

- ការគាំទ្រ និងការប្ដេជ្ញាពីថ្នាក់ដឹកនាំកំពូល ឬជាន់ខ្ពស់ ចាំបាច់ត្រូវតែមានភាពខ្លាំងក្លា ច្បាស់លាស់ និងអាចមើលឃើញបានថា មានពិតប្រាកដ និងត្រូវបានអនុវត្តជាក់ស្ដែងមែន ។
- ថ្នាក់ដឹកនាំជាន់ខ្ពស់ ត្រូវបញ្ជាក់ឱ្យច្បាស់ពីការមិនអត់ឱនដល់អំពើពុករលួយ ដោយមានគោលនយោបាយ និងនីតិវិធី សម្រាប់អនុវត្តតាម ។ ការប្ដេជ្ញាចិត្តនេះដើរតួយ៉ាងសំខាន់ក្នុងការកសាងវប្បធម៌សុចរិតភាព តម្លាភាព និងគណនេយ្យភាព ។

+ <u>ការប្ដេជ្ញាពីថ្នាក់កំពូល</u>

- ជះឥទ្ធិពលដល់និយាម និងតម្លៃក្រុមហ៊ុន និងធ្វើឱ្យបុគ្គលិក និងដៃគូពាក់ព័ន្ធដឹងថា ត្រូវគោរពតាមឱ្យបាន ។ ការប្ដេជ្ញាពីថ្នាក់កំពូលរួមមាន ពីម្ចាស់ក្រុមហ៊ុន អគ្គនាយក (CEO) ក្រុមប្រឹក្សានាយក ឬ អង្គស្មើ ។
- និយោជិតគ្រប់លំដាប់ថ្នាក់ ត្រូវជាម្ចាស់នៃកម្មវិធីប្រឆាំងអំពើពុករលួយ និងត្រូវចាត់ទុកថា ការទប់ស្កាត់អំពើពុករលួយ គឺជាការទទួលខុសត្រូវរបស់ខ្លួន ។
- ការប្ដេជ្ញាត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញ តាមរយៈការគាំទ្រដោយមិនងាករេ និងការវាយតម្លៃពីតម្លៃជាមូលដ្ឋានរបស់ក្រុមហ៊ុន ដូចជា សុចរិតភាព តម្លាភាព គណនេយ្យភាព និងការមិនអត់ឱនឱ្យអំពើពុករលួយ ។
- ការប្ដេជ្ញាត្រូវមានធាតុផ្សំចម្បង ២ គឺ៖
    - ១) គោលនយោបាយសាធារណៈពីការមិនអត់ឱនឱ្យអំពើពុករលួយ និង
    - ២) ការកសាង និងអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ ។
- ថ្នាក់ដឹកនាំជាន់ខ្ពស់ ត្រូវបញ្ជាក់ឱ្យច្បាស់ពី៖
    - ការហាមឃាត់អំពើពុករលួយគ្រប់ពេល - គ្រប់ទម្រង់ ទាំងតូច/ទាំងធំ ផ្ដល់ដោយផ្ទាល់ ឬដោយប្រយោល សកម្ម ឬអសកម្ម
    - ការហាមឃាត់ដោយមានសេចក្ដីថ្លែងជាផ្លូវការជាលាយលក្ខណ៍អក្សរ ពីការមិនអត់ឱនឱ្យអំពើពុករលួយ
    - ការបញ្ជាក់ពីការហាមឃាត់នេះ នៅគ្រប់ព្រឹត្តិការណ៍ខាងក្នុង និងខាងក្រៅអង្គភាព (ដូចជាការបណ្ដុះបណ្ដាលបុគ្គលិក កិច្ចប្រជុំភាគហ៊ុនិក សន្និសីទ)

- សេចក្តីថ្លែងត្រូវគាំទ្រដោយកម្មវិធីប្រឆាំងអំពើពុករលួយដែលមានប្រសិទ្ធភាព ដែលរួមមាន គោលនយោបាយ និងនីតិវិធីលម្អិត
- ការគាំទ្រ និងការប្តេជ្ញា ជាការងារធ្វើជាប្រចាំ មិនមែនម្តងហើយចប់នោះទេ ។

+ តួនាទីរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់

- ជានាថាមានការប្តេជ្ញាចិត្តនៅទូទាំងក្រុមហ៊ុន៖
    - ធ្វើឱ្យបុគ្គលិកគ្រប់កម្រិតយល់ពីការប្តេជ្ញាចិត្ត
    - ថ្នាក់ដឹកនាំកម្រិតកណ្តាល ត្រូវបង្ហាញពីភាពជាម្ចាស់លើកម្មវិធីប្រឆាំងអំពើពុករលួយ ។
- បង្កើតការទទួលខុសត្រូវ៖
    - ចាត់តាំងបុគ្គលិកសំខាន់ទទួលខុសត្រូវក្នុងអង្គភាព (ឧទា. អ្នកគ្រប់គ្រងផ្នែកអនុលោមតាមច្បាប់ ទទួលខុសត្រូវលើការប្រតិបត្តិសម្រាប់កាអនុវត្ត និងការគោរពតាមកម្មវិធីប្រឆាំងអំពើពុករលួយ និងការត្រួតពិនិត្យពីលើ ។
- ផ្តល់ធនធានគ្រប់គ្រាន់៖
    - កម្រិតជំនាញពាក់ព័ន្ធ និងធនធានហិរញ្ញវត្ថុ
    - អាចជួល និង/ឬពិគ្រោះជាមួយអ្នកជំនាញ ដើម្បីឱ្យកម្មវិធីមានគុណភាព ។
- កំណត់វិសាលភាព និងកម្រិតនៃកម្មវិធី៖
    - កម្រិតនៃការរាយការណ៍ជាសាធារណៈ
    - ថាតើកម្មវិធីនឹងធ្វើនូវការវាយតម្លៃដោយឯករាជ្យក្នុងទម្រង់ណាមួយ ឬ
    - ថាតើក្រុមហ៊ុននឹងបង្កើតឱ្យមាននូវគំនិតផ្តួចផ្តើមដោយស្ម័គ្រចិត្ត ឬចូលរួមក្នុងគំនិតផ្តួចផ្តើមសកម្មភាពរួមណាមួយ ដែលអាចមាន ឬដែលកំពុងរៀបចំឱ្យមាន ។
- គាំទ្រ និងប្តេជ្ញាធ្វើចំណាត់ការ៖
    - ថ្នាក់ដឹកនាំជាន់ខ្ពស់ចាំបាច់ត្រូវចូលរួមក្នុងដំណើរការអនុវត្ត និងការកែលម្អ ។ ការចូលរួម ជាការសំខាន់ ព្រោះការបង្កើតកម្មវិធីប្រឆាំងអំពើពុករលួយអាចនាំឱ្យមានចម្ងល់ ការព្រួយបារម្ភ ឬការជំទាស់ពីបុគ្គលិក ឬដៃគូជំនួញ ។
    - ការប្តេជ្ញាចិត្តតាមរយៈសកម្មភាពដែលអាចមើលឃើញ ឬដោយសកម្ម រួមមានការចូលរួមក្នុងគំនិតផ្តួចផ្តើមដោយស្ម័គ្រចិត្តនានាដែលអាចមាន ដូចជា United

Nations Global Compact (UNGC) ជាដើម ។ ការនិយាយក្នុងកិច្ចប្រជុំនានាអំពីវិចារណកម្ម និងសារៈសំខាន់នៃកម្មវិធី - ការលើកសរសើរបុគ្គលិកដែលអនុវត្តតាមតម្លៃក្រុមហ៊ុនបានល្អ ទោះបីជាមានការបាត់បង់ឱកាសធុរកិច្ចសម្រាប់ក្រុមហ៊ុនក៏ដោយ (ឧទា. បដិសេធទទួលកិច្ចសន្យាដែលអាចពាក់ព័ន្ធនឹងអំពើពុករលួយ) - ការលើកឡើងពីការប្តេជ្ញាប្រឆាំងអំពើពុករលួយ នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន - ការចូលរួមបណ្តុះបណ្តាល និងសកម្មភាពទំនាក់ទំនង - ការដើរតួជាបុគ្គលគំរូ (ព្រោះបុគ្គលិកតែងតែមើលបំណាំថ្នាក់លើ និងធ្វើគំរូតាម) ។

*សម្គាល់*

*+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs*

- ការប្តេជ្ញាពីថ្នាក់ដឹកនាំកំពូលៗរបស់ SMEs គឺសំខាន់ណាស់សម្រាប់ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ
- ដោយសារទំហំតូច ថ្នាក់ដឹកនាំកំពូលអាចធ្វើការប្តេជ្ញាដោយផ្ទាល់ និងហ្មត់ចត់បាន
- ថ្នាក់ដឹកនាំចាំបាច់ត្រូវធ្វើជាមនុស្សគំរូ ។

*+ ការរាយការណ៍*

- ក្រុមហ៊ុន គប្បីបង្ហាញពីគោលការណ៍មិនអត់ឱនដល់អំពើពុករលួយរបស់ក្រុមហ៊ុន
- ពណ៌នាអំពីថាតើសេចក្តីថ្លែងនេះ អាចរកបានជាសាធារណៈនៅទីណា?
- រៀបរាប់ពីនីតិវិធី និងកិច្ចប្រឹងប្រែងទាក់ទងនឹងសេចក្តីថ្លែងពីការប្រឆាំងអំពើពុករលួយ
- រៀបរាប់ពីគំនិតផ្តួចផ្តើមស្ម័គ្រចិត្ត ឬចំណាត់ការរួមដែលក្រុមហ៊ុនបានចូលរួម ។

## A. 1. **យោជ័បជដ្ឋានអន្តរជាតិ**

ថ្នាក់ដឹកនាំជាន់ខ្ពស់ ដូចជា ក្រុមប្រឹក្សានាយក ប្រធានប្រតិបត្តិ គួរដើរតួនាទីក្នុងការដាក់ឱ្យប្រើកម្មវិធីប្រឆាំងអំពើពុករលួយ ដោយត្រូវបង្ហាញពីភាពជាម្ចាស់ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តកម្មវិធីនេះ ។ ដោយផ្អែកលើតម្លៃជាមូលដ្ឋានគ្រឹះ នៃសុចរិតភាព តម្លាភាព និងគណនេយ្យភាព ប្រធានក្រុមប្រឹក្សានាយក គួរបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ និងជំហរច្បាស់លាស់ ក្នុងការអនុវត្តនូវកម្មវិធីដាក់ចេញដោយក្រុមហ៊ុន ។

## A. 2. ករណីសិក្សា

### *ក្រុមហ៊ុនចម្រុះជាតិសាសន៍មធ្យម A កំណត់ឱ្យថ្នាក់ដឹកនាំជាន់ខ្ពស់បង្កើតនូវកម្មវិធីប្រឆាំងអំពើពុករលួយ*

- ថ្មីៗនេះ ក្រុមហ៊ុន A ដែលមានការិយាល័យកណ្តាលនៅអឺរ៉ុបមានជាប់ពាក់ព័ន្ធការស៊ើបអង្កេតដោយអាជ្ញាធរអ៊ីតាលី ពីការសូកប៉ាន់នៅក្រៅប្រទេស ។ នាយករបស់បុត្រសម្ព័ន្ធនៃក្រុមហ៊ុន A ត្រូវបានចោទប្រកាន់ថាបានផ្តល់សំណូក ដើម្បីទទួលបានកិច្ចសន្យានៅក្រៅប្រទេស ។ ក្រុមហ៊ុន A បានព្យួរការងារអ្នកគ្រប់គ្រងជាន់ខ្ពស់ដែលជាប់ពាក់ព័ន្ធ ។ នេះជាការសម្រេចចិត្តធ្វើឡើងដោយក្រុមប្រឹក្សានាយកក្រុមហ៊ុន ហើយជាប្រវត្តិសាស្ត្រសម្រាប់ក្រុមហ៊ុនហើយ ដែលក្រុមហ៊ុនបានបំបែកឱ្យដាច់ចេញពីគ្នារវាងអ្នកគ្រប់គ្រងក្រុមហ៊ុន និងម្ចាស់ក្រុមហ៊ុន ។
- ក្រុមហ៊ុន A មិនមានរចនាសម្ព័ន្ធគ្រប់គ្រងសម្រាប់ទប់ស្កាត់ការសូកប៉ាន់ទេ មុនពេលមានការស៊ើបអង្កេតត្រូវបានធ្វើឡើង ។ ដូចនេះពេលមានរឿងកើតឡើង គឺមិនមានគោលនយោបាយសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធការសូកប៉ាន់នេះទេ ។ ក្រុមប្រឹក្សានាយកបានសម្រេចចិត្តបង្កើតនូវកម្មវិធីដែលសមស្រប សម្រាប់ការការពារទប់ស្កាត់ការសូកប៉ាន់នៅបរទេស ។ ម៉ូដែលនៃការគ្រប់គ្រងថ្មីរបស់ក្រុមហ៊ុនត្រូវបានបង្កើតឡើង ដោយរួមមាននូវគោលនយោបាយ និងនីតិវិធីដើម្បីការពារ ទប់ស្កាត់ ប្រឆាំងនឹងហានិភ័យនៃអំពើពុករលួយដែលអាចមាន ។
- ម៉ូដែលថ្មីនៃការគ្រប់គ្រងដំណើរការងាររបស់ក្រុមហ៊ុន បានបង្កលក្ខណៈឱ្យក្រុមហ៊ុន A អនុម័តបាននូវក្រមសីលធម៌ គោលនយោបាយ និងនីតិវិធីសំខាន់ៗ ព្រមទាំងបង្កើតបាននូវផ្នែកត្រួតពិនិត្យដែលមានកាតព្វកិច្ចធានាថា គោលនយោបាយ និងនីតិវិធីត្រូវបានគោរពតាមយ៉ាងខ្ជាប់ខ្ជួន ។ ការបណ្តុះបណ្តាលដល់និយោជិតឱ្យយល់ច្បាស់អំពីនីតិវិធី និងគោលការណ៍ទាំងនេះ ជាពិសេសផ្នែកដែលមានហានិភ័យដល់និយោជិតដែលពាក់ព័ន្ធត្រូវបានអនុវត្ត ។ អ្នកគ្រប់គ្រងជាន់ខ្ពស់ និងអ្នកជំនាញក្រុមហ៊ុនបានពន្យល់យ៉ាងម៉ឺងម៉ាត់ដល់បុគ្គលិកអំពីគោលការណ៍គ្មានការលើកលែង ("Zero Tolerence") ចំពោះការសូកប៉ាន់នៅបរទេស ។

## B. ការកសាងកម្មវិធីប្រឆាំងអំពើពុករលួយ

កម្មវិធីរួមមានគោលនយោបាយ និងនីតិវិធីលម្អិតដូចតទៅ៖

+ ចរិតលក្ខណៈនៃកម្មវិធីប្រឆាំងអំពើពុករលួយ

- ត្រូវមានសង្គតិភាពជាមួយច្បាប់ជាធរមានទាំងអស់៖
    - ក្រុមហ៊ុនត្រូវសិក្សា និងស្រាវជ្រាវឱ្យបានគ្រប់ជ្រុងជ្រោយ
    - អាចចាត់តាំងអ្នកជំនាញផ្នែកច្បាប់ ឱ្យត្រួតពិនិត្យមើលកម្មវិធីពីសង្គតិភាពរវាងច្បាប់ជាតិ និងអន្តរជាតិ ។
- សម្របទៅតាមតម្រូវការជាក់លាក់៖
    - ស្របតាមលក្ខណៈនៃស្ថានភាពក្រុមហ៊ុនរៀងៗខ្លួន
    - ការវាយតម្លៃហានិភ័យ អាចបង្ហាញពីហានិភ័យ និងវិធានការប្រឆាំងអំពើពុករលួយដែលត្រូវធ្វើ ហើយអាចរួមមាននូវវប្បធម៌នៃអង្គភាព ការចង់បាន ឬទំនៀមទម្លាប់ដែលអាចជួយដល់ការរៀបចំការបណ្តុះបណ្តាលឱ្យមានប្រសិទ្ធភាព ។
- ការចូលរួមរបស់ភាគីពាក់ព័ន្ធ មានដូចជា៖
    - បង្កើតភាពជាម្ចាស់ និងគាំទ្រដល់ការទទួលស្គាល់ និងទទួលយកនូវកម្មវិធីប្រឆាំងអំពើពុករលួយ
    - អាចផ្តល់ឱកាសឱ្យភាគីពាក់ព័ន្ធសំខាន់ៗ ដូចជាភាគហ៊ុនិក ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ដៃគូធុរកិច្ច និង/ឬបុគ្គលិកទូទៅផ្តល់យោបល់លើកម្មវិធីប្រឆាំងអំពើពុករលួយ
    - បង្កើតការទុកចិត្ត ការយល់ដឹង និងជួយកាត់បន្ថយការជំទាស់ទៅនឹងការអនុវត្តកម្មវិធី ។
- ការទទួលខុសត្រូវរួមគ្នា គឺ៖
    - ការគោរពតាមកម្មវិធីប្រឆាំងអំពើពុករលួយ គឺជាការតម្រូវ និងត្រូវអនុវត្តឱ្យបានគ្រប់កម្រិតមុខងារ និងផ្នែក
    - ចាំបាច់ត្រូវជៀសវាងការមានបទដ្ឋានឌុប និងភាពបត់បែនក្នុងការបកស្រាយគោលនយោបាយ និងកម្មវិធី - គ្រប់គ្នាត្រូវគោរពតាមគោលការណ៍ និងច្បាប់ដូចគ្នា
    - ត្រូវមានសង្គតិភាពក្នុងការអនុវត្តកម្មវិធី ហើយត្រូវឆ្លុះបញ្ចាំងក្នុងគោលនយោបាយធនធានមនុស្សរបស់ក្រុមហ៊ុន ។

- ការទទួលបានៈ
    - ការផ្សាយលើវិបសាយ - ឯកសារបោះពុម្ព - ការបិទផ្សាយលើរថយន្ត ។ល។ ជួយសម្រួលដល់ភាពងាយទទួលបាន
    - ការទទួលបានព័ត៌មាន លើកស្ទួយដល់កម្មវិធីប្រឆាំងអំពើពុករលួយ
    - វិធានការច្បាស់លាស់ ដូចជា ផ្នែកគាំទ្រ និងប្រឹក្សាយោបល់ ក៏សំខាន់ដែរ ។
- អាចអានបានៈ
    - ប្រើពាក្យ - បកប្រែជាភាសាណាដែលចាំបាច់ - ជៀសវាងពាក្យបច្ចេកទេស ឬអក្សរកាត់ បើអាច ។
- លើកស្ទួយវប្បធម៌ទុកចិត្តផ្ទៃក្នុងៈ
    - វប្បធម៌នេះ អាចជួយបំលែងគោលនយោបាយប្រឆាំងអំពើពុករលួយទៅជាតម្លៃនិយាម និងគោលការណ៍
    - បង្កើតបរិយាកាសសមស្របសម្រាប់ឱ្យបុគ្គលិកដែលស្មោះត្រង់ និងដែលគោរពក្រមសីលធម៌ទទួលបាននូវការប្រឹក្សាយោបល់ នៅពេលពួកគេជួបស្ថានភាពលំបាកហើយមិនអាចធ្វើការសម្រេចចិត្តឱ្យបានល្អ ដើម្បីជៀសវាងនូវការរំលោភលើគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ក្រុមហ៊ុន ។
- អាចអនុវត្តបានៈ
    - អាចអនុវត្តបានចំពោះបុគ្គលិក ក៏ដូចជាដៃគូធុរកិច្ចពាក់ព័ន្ធ និងភាគហ៊ុនិក
    - មានការចូលរួមពីភាគីខាងក្រៅ ក្នុងយុទ្ធសាស្ត្រទំនាក់ទំនង បណ្តុះបណ្តាល វិធានការផ្សេងៗទៀត អាចជួយឱ្យសម្រេចនូវការយល់ដឹងខ្ពស់ និងកាត់បន្ថយហានិភ័យអំពើពុករលួយ (ឧទា. សំណើផ្តល់សំណូកពីអ្នកផ្គត់ផ្គង់) ។
- និរន្តរភាពៈ
    - ការអនុវត្តកម្មវិធីត្រូវបន្តជានិច្ច និងត្រូវសម្របតាមការប្រែប្រួលបរិយាកាសធុរកិច្ច ការវិវឌ្ឍន៍ និងចំណេះដឹងថ្មីៗដែលមាន ។
- ប្រសិទ្ធផលៈ
    - មានធនធាន (មនុស្ស - ថវិកា) គ្រប់គ្រាន់សម្រាប់កម្មវិធីប្រឆាំងអំពើពុករលួយ ។ ប្រសិនបើមិនមាន ក្រុមហ៊ុនអាចនឹងទទួលរងការខាតបង់ និង ជួបឧបសគ្គ ។

*សម្គាល់*

*+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs*

- SMEs មានភាពងាយស្រួលជាងក្រុមហ៊ុនធំៗក្នុងការព្យាយាមគោរពតាមចរិតលក្ខណៈខាងលើ ដោយសារកម្រិតឋានានុក្រមតិចជាង និងទំនាក់ទំនងរវាងថ្នាក់គ្រប់គ្រងបុគ្គលិក និងដៃគូធុរកិច្ចជិតស្និទ្ធជាង ។

*+ ការរាយការណ៍*

- ក្រុមហ៊ុនគប្បីផ្តល់នូវសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរជាសាធារណៈ អំពីការប្តេជ្ញាអនុលោមតាមច្បាប់ពាក់ព័ន្ធទាំងអស់ - បោះពុម្ពសេចក្តីថ្លែង
- ពណ៌នាអំពីនីតិវិធី និងកិច្ចប្រឹងប្រែងទាក់ទងនឹងសេចក្តីថ្លែង
- រាយការណ៍ពីវត្តមាន និងធាតុផ្សំរបស់កម្មវិធី
- ពណ៌នាអំពីរបៀបអនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលនយោបាយ និងដំណើរការការងារដែលគាំទ្រដល់ការប្តេជ្ញាចិត្តប្រឆាំងអំពើពុករលួយ ។

## B. 1. **យោជ័បធនដ្ឋានអន្តរជាតិ**

សហគ្រាសគួរបង្កើតកម្មវិធីក្នុងការទប់ស្កាត់ការសូកប៉ាន់ ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាននៅគ្រប់ដែនយុត្តាធិការ ដែលសហគ្រាសមានប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ។ សហគ្រាសគួរតែជានាថារាល់ឯកសារពាក់ព័ន្ធដែលបានសរសេរឡើងត្រូវបានផ្សព្វផ្សាយដល់គ្រប់ភាគីពាក់ព័ន្ធទាំងខាងផ្ទៃក្នុង និងខាងក្រៅដើម្បីអនុវត្តនូវកម្មវិធីនេះ ប្រកបដោយប្រសិទ្ធភាព ។ ដោយមានការពិគ្រោះយោបល់ជាមួយបុគ្គលផ្ទៃក្នុងសំខាន់ៗ សហគ្រាសគួរបង្កើតកម្មវិធីនេះផ្អែកទៅតាមទំហំ ប្រភេទអាជីវកម្មហានិភ័យដែលអាចមាន និងទីតាំងប្រតិបត្តិការ ដោយត្រូវបង្ហាញឱ្យបានច្បាស់នូវតម្លៃគោលនយោបាយ និងនីតិវិធីនានា ក្រោមការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់អំពើពុករលួយ ។ សហគ្រាសត្រូវហាមឃាត់រាល់ការសូកប៉ាន់គ្រប់ទម្រង់ ដោយផ្ទាល់ និងដោយប្រយោល ។

## B. 2. **ការណីសិក្សា**

***ក្រុមហ៊ុនមានទំហំមធ្យម B លើកទឹកចិត្តឱ្យមានការអនុលោមតាមគោលនយោបាយហាមឃាត់សំណូករបស់ខ្លួន ដោយប្រើនូវធាតុចូលធុរកិច្ចក្នុងស្រុក ដើម្បីធ្វើបច្ចុប្បន្នភាព និង***

## ពង្រឹងក្រមប្រតិបត្តិរបស់ខ្លួន

- ក្រុមហ៊ុន B គឺជាក្រុមហ៊ុនមធ្យមមួយ មានមូលដ្ឋាននៅអឺរ៉ុប ប្រកបធុរកិច្ចលើផលិតផលឱសថ និងសេវាកម្ម ដែលមាននិយោជិតសរុបប្រមាណជា ៧៥០០ នាក់ ជាមួយនឹង ៧០% នៃការលក់មាននៅអឺរ៉ុប ក្រុមហ៊ុន B បានមើលឃើញថាការកើនឡើង នៃការលក់នឹងមានកាន់តែធំក្នុងទីផ្សារ។ នៅក្នុងឆ្នាំ២០១០ ក្រុមហ៊ុន B សម្រេចចិត្តពង្រឹងក្រមប្រតិបត្តិ និងប្រព័ន្ធអនុលោមតាមច្បាប់របស់ខ្លួន ដោយផ្អែកលើមូលហេតុ ៣ សំខាន់៖ (១) ក្រុមហ៊ុនត្រូវអនុវត្តតាមច្បាប់ប្រឆាំងការសូកប៉ាន់របស់អង់គ្លេស ដែលបានកំណត់នូវបទបញ្ញត្តិថ្មីៗសម្រាប់ប្រាក់សម្រួលការងារ អំណោយ និងបដិសណ្ឋារកិច្ចផ្សេងៗ ដែលក្រុមហ៊ុន B គិតថាចាំបាច់ត្រូវដោះស្រាយភ្លាមៗ (២) និយោជិតធ្លាប់តែគិតថាពួកគេមិនចាំបាច់មានការយល់ដឹងគ្រប់គ្រាន់អំពីគោលនយោបាយបច្ចុប្បន្នរបស់ក្រុមហ៊ុន សម្រាប់ការបំពេញការងារប្រកបដោយសីលធម៌នោះទេ (៣) បញ្ហាប្រឈមមួយចំនួន ដូចជា ការគ្រប់គ្រងទំនាស់ផលប្រយោជន៍ត្រូវការដោះស្រាយដោយផ្អែកលើក្រមប្រតិបត្តិថ្មីរបស់ក្រុមហ៊ុន B ។
- គោលបំណងចម្បងរបស់ក្រុមហ៊ុន B គឺបង្កើតនូវក្រមសីលធម៌សាកលមួយ ដែលអាចអនុវត្តបានដោយមិនគិតពីទីតាំង និងវប្បធម៌របស់និយោជិតដែលមកពីប្រទេសខុសៗគ្នា ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រុមអនុលោមតាមច្បាប់ និងការទទួលខុសត្រូវសាជីវកម្ម ត្រូវបានបង្កើតឡើង និងបានចាប់ផ្តើមធ្វើការសម្ភាសន៍នាយកប្រចាំប្រទេស និងប្រធានផ្នែកទីផ្សារប្រចាំប្រទេសនីមួយៗ ដែលក្រុមហ៊ុន B កំពុងមានប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ។
- ក្រមប្រតិបត្តិថ្មីរបស់ក្រុមហ៊ុន B ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មរួច មាន៣ ចំណុចសំខាន់ៗ៖
    - ហាមឃាត់ការសូកប៉ាន់ ក៏ដូចជាការចំណាយក្រៅច្បាប់ជាពិសេសការចំណាយប្រាក់សម្រួលការងារ
    - ទប់ស្កាត់ការគៃបន្លំ និងទំនាស់ផលប្រយោជន៍
    - ហាមឃាត់ការទទួលទានអាហារ ការកំសាន្តផ្សេងៗ អំណោយ បដិសណ្ឋារកិច្ច ដែលមិនសមាមាត្រ និងមិនសមហេតុផល ។

## C. ការត្រួតពិនិត្យមើលលើកម្មវិធីប្រឆាំងអំពើពុករលួយ

*+ ការទទួលខុសត្រូវសម្រាប់កម្មវិធីប្រឆាំងអំពើពុករលួយ*

- ក្រុមប្រឹក្សានាយក ឬអង្គស្មើ អាចតែងតាំងគណៈកម្មាធិការអនុលោមតាមច្បាប់ សវនកម្ម ឬក្រុមសីលធម៌ ដើម្បីជួយក្រុមប្រឹក្សានាយក ។
- ការអនុវត្តកម្មវិធី ស្ថិតនៅក្នុងដៃថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដែលមានភារកិច្ចផ្តល់ព័ត៌មាន ពីស្ថានភាពនៃការអនុវត្តជាក់ស្តែងទៅក្រុមប្រឹក្សានាយក ឬអង្គស្មើ ។
- ក្រុមហ៊ុនធំៗអាចបង្កើតផ្នែកត្រួតពិនិត្យផ្ទៃក្នុងឯករាជ្យ ដែលមានចំណេះដឹង និងភាពជំនាញ ដើម្បីវាយតម្លៃសកម្មភាពប្រចាំថ្ងៃទាក់ទងនឹងការអនុវត្តគោលនយោបាយ និងនីតិវិធីនៃកម្មវិធីប្រឆាំងអំពើពុករលួយ ។
- ទម្រង់នៃផ្នែកនេះ ដូចជាធនធានមនុស្ស តួនាទី និងការទទួលខុសត្រូវជាដើម គឺអាស្រ័យលើរចនាសម្ព័ន្ធ និងទំហំរបស់ក្រុមហ៊ុន ។
- ផ្នែកនេះ ប្រមូលឯកសារពីសកម្មភាពពាក់ព័ន្ធនឹងកម្មវិធីប្រឆាំងអំពើពុករលួយ និងរាយការណ៍ទៅថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដោយផ្ទាល់ ។

*+ ការទទួលខុសត្រូវត្រួតពិនិត្យមើលពីលើ*

- ក្រុមប្រឹក្សានាយក ឬអង្គស្មើ ត្រូវធានាថាកម្មវិធីប្រឆាំងអំពើពុករលួយ ត្រូវបានអនុវត្តដោយ៖
  - ទទួលយកការប្រឆាំងអំពើពុករលួយ ជាអាទិភាពរបស់ក្រុមហ៊ុន (ជារបៀបវារៈមួយ ឬជាការធានារបស់ក្រុមប្រឹក្សានាយក)
  - ត្រួតពិនិត្យថ្នាក់គ្រប់គ្រងនានា ទាក់ទងនឹងការអនុវត្តគោលនយោបាយ និងនីតិវិធីប្រឆាំងអំពើពុករលួយ (ទទួលព័ត៌មានជាប្រចាំពីស្ថានភាពអនុវត្តកម្មវិធី និងករណីធំៗ និងចំណាត់ការដោះស្រាយកែតម្រូវ)
  - វាយតម្លៃលើការគ្រប់គ្រងទូទៅនៃកម្មវិធី តាមរយៈការត្រួតពិនិត្យនូវព័ត៌មានពីស្ថានភាពរបស់ថ្នាក់គ្រប់គ្រងនានា និងពីការវាយតម្លៃឯករាជ្យនានា (បើចាំបាច់ ក្រុមប្រឹក្សានាយកអាចដាក់ចេញចំណាត់ការដោះស្រាយ)
  - ឆ្លើយតបទៅនឹងភាពមិនប្រក្រតីភ្លាមៗ ឬបញ្ហាប្រឈមធ្ងន់ធ្ងរមាននៅក្នុងក្រុមហ៊ុន ។
- ក្រុមប្រឹក្សានាយក ឬអង្គស្មើអាចដាក់ចេញ នូវគោលនយោបាយជាផ្លូវការពីការទទួលខុសត្រូវ របស់សមាជិកក្រុមប្រឹក្សានាយក ទាក់ទងនឹងការត្រួតពិនិត្យមើលពីលើ - ការ

*រំពឹងទុកនូវអាកប្បកិរិយា ការគាំទ្រ និងការប្តេជ្ញាចិត្តចំពោះកម្មវិធីប្រឆាំងអំពើពុករលួយរបស់សមាជិកក្រុមប្រឹក្សានាយក ។*

*សម្គាល់*

*+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs*

- SMEs *អាចពិបាករកបុគ្គលិកធ្វើការងារនេះ ប៉ុន្តែបើមិនអាចមានផ្នែក ឬក្រុមធ្វើការនេះទេ យ៉ាងហោចណាស់ក៏មានម្នាក់ទទួលការងារនេះដែរ*
- *ងាយស្រួលធ្វើការត្រួតពិនិត្យ ដោយសាររចនាសម្ព័ន្ធសាមញ្ញ និងងាយស្រួលប្រមូលព័ត៌មាន (អាចធ្វើពេលប្រជុំផ្ទៃក្នុងក៏បាន ប៉ុន្តែត្រូវមានការកំណត់ការទទួលខុសត្រូវលើប្រតិបត្តិការច្បាស់លាស់ ហើយលទ្ធផលពីកិច្ចប្រជុំត្រូវតែកត់ត្រា)*
- *បើគ្មានធនធានគ្រប់គ្រាន់ សម្រាប់បំបែកការទទួលខុសត្រូវប្រតិបត្តិការពីការត្រួតពិនិត្យលើកម្មវិធីទេ* SMEs *អាចជួលទីប្រឹក្សាផ្ទៃក្រៅឱ្យជួយវាយតម្លៃឯករាជ្យ ។*

*+ ការរាយការណ៍*

- *ក្រុមហ៊ុនគប្បីបង្ហាញពីរបៀបផ្តល់ការទទួលខុសត្រូវ នៅក្នុងរចនាសម្ព័ន្ធក្រុមហ៊ុន*
- *ពណ៌នាពីការផ្តល់ការទទួលខុសត្រូវលើការត្រួតពិនិត្យ និងការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ*
- *បើអាច ផ្តល់របាយការណ៍ជាក់លាក់ដែលបានធ្វើ ដើម្បីគាំទ្រការទទួលខុសត្រូវ និងគណនេយ្យភាព សម្រាប់ការអនុវត្តការប្តេជ្ញាចិត្ត ឬគោលនយោបាយប្រឆាំងអំពើពុករលួយ ។*

## C.1. យោងបងង្គានអន្តរជាតិ

*ក្រុមប្រឹក្សានាយក ឬអង្គស្មើ គប្បីធានាថាកម្មវិធីប្រឆាំងអំពើពុករលួយ ដែលត្រូវបានបង្កើត និងអនុវត្ត ត្រូវបានត្រួតពិនិត្យឡើងវិញដើម្បីឱ្យមានប្រសិទ្ធភាព និងកែលម្អនៅពេលរកឃើញភាពខ្វះចន្លោះ ។ នាយកប្រតិបត្តិ ឬអង្គស្មើ ត្រូវទទួលខុសត្រូវ ក្នុងការមើលថាកម្មវិធី ត្រូវបានអនុវត្តដោយប្រសិទ្ធភាព ជាមួយនឹងខ្សែបន្ទាត់គ្រប់គ្រងច្បាស់លាស់ ។ អាស្រ័យលើទំហំនៃសហគ្រាស ការសម្រេចទៅលើប្រតិបត្តិការ និងការត្រួតពិនិត្យមើលលើការមិនអនុវត្តនូវក្រមសីលធម៌ គួរតែកំណត់ថាជាតួនាទីរបស់មន្ត្រីជាន់ខ្ពស់ក្រុមហ៊ុនមួយរូប ។*

## C.2. ករណីសិក្សា

### ករណីសិក្សា C.2.1៖ ក្រុមហ៊ុនវិស្វកម្មអឺរ៉ុបមួយបង្កើតក្រុមការងារត្រួតពិនិត្យលើការអនុលោមតាមច្បាប់

- ក្រុមហ៊ុនបម្រើសេវាកម្មផ្នែកវិស្វកម្មរបស់ប្រទេសអ៊ីតាលីមួយ បានបង្កើតឡើងជាង ៩០ ឆ្នាំ ហើយមានសាខា នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើននៅលើពិភពលោក ។
- ដោយមានសាខាច្រើន ក្រុមហ៊ុនបានបង្កើតនូវយន្តការត្រួតពិនិត្យ គ្រប់គ្រងអង្គភាពសម្រាប់អនុវត្តជារួម ។ តាមរយៈយន្តការនេះ ក្រុមហ៊ុនបានបង្កើតក្រុមការងារត្រួតពិនិត្យមួយ ដើម្បីអនុវត្តការងារនេះ ។ ក្រុមការងារត្រួតពិនិត្យ មានលក្ខណៈសម្បត្តិដូចជា៖
    - សមាជិក ៣ នាក់ (មានសមត្ថភាព & បទពិសោធន៍ការងារត្រួតពិនិត្យ)
    - ធ្វើការដោយឯករាជ្យ
    - អាចជួលទីប្រឹក្សាពីខាងក្រៅដើម្បីជួយ
    - មានកញ្ចប់ថវិកាពិសេស
    - អាចអនុញ្ញាតឱ្យវិស្វករជាន់ខ្ពស់ក្រុមហ៊ុនចូលរួមប្រជុំ និងផ្តល់ព័ត៌មានតាមការចាំបាច់ ។
- ក្រុមហ៊ុនបានធ្វើការបណ្តុះបណ្តាល និងផ្សព្វផ្សាយពីយន្តការនេះ ដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងដៃគូពាណិជ្ជកម្ម និងទីប្រឹក្សានានា ។

### ករណីសិក្សា C.2.2៖ ក្រុមហ៊ុនទូរគមនាគមន៍ចម្រុះជាតិមួយបង្កើតការិយាល័យទទួលបន្ទុកគោលការណ៍អាជីវកម្ម ដើម្បីធានាភាពអនុលោមតាមច្បាប់

- ក្រុមហ៊ុនទូរគមនាគមន៍ចម្រុះជាតិមួយ មានទីតាំងនៅតាមប្រទេសមួយចំនួននៅសហគមន៍អឺរ៉ុប ។ នៅក្នុងកំឡុងពេលដែលក្រុមហ៊ុនធ្វើការពង្រីកអាជីវកម្មរបស់ខ្លួនខ្លាំងទៅក្នុងទីផ្សារអន្តរជាតិ ក្រុមហ៊ុនបានបង្កើតនូវគោលការណ៍អាជីវកម្មថ្មី ដែលគោលការណ៍នេះរួមបញ្ចូលនូវគោលការណ៍អាជីវកម្មដែលមានស្រាប់ និងក្រមសីលធម៌របស់ក្រុមហ៊ុន ។

- គោលការណ៍នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល ហើយផ្តោតទៅលើសុចរិតភាព ការអនុលោមតាមច្បាប់ និងការគោរពសិទ្ធិមនុស្ស ។ ដើម្បីឱ្យការអនុវត្តនូវគោលការណ៍ថ្មីមានប្រសិទ្ធភាព ក្រុមហ៊ុនបានបង្កើតនូវការិយាល័យទទួលបន្ទុកគោលការណ៍អាជីវកម្មសាកល ដែលមានផ្នែកមួយចំនួនចូលរួម មានដូចជាផ្នែកធនធានមនុស្ស សវនកម្មផ្ទៃក្នុង លេខាធិការដ្ឋាន និងកិច្ចការច្បាប់ និងផ្នែកលេខាធិការនាយក ។ ការិយាល័យនេះមានទីតាំងនៅក្នុងប្រទេសដែលទីស្នាក់ការកណ្តាលស្ថិតនៅ ហើយមានកាតព្វកិច្ចបង្កើតយុទ្ធសាស្ត្រ គោលការណ៍ បទដ្ឋាន និងយន្តការគ្រប់គ្រងក្រមសីលធម៌ សម្រាប់ប្រតិបត្តិការរបស់ក្រុមហ៊ុន ។ ក្រៅពីការិយាល័យនៅទីស្នាក់ការកណ្តាល ក្រុមហ៊ុនក៏មានការិយាល័យដូចគ្នានេះនៅតាមសាខានៃប្រទេសផ្សេងៗផងដែរ ។ ការិយាល័យទាំងនេះ មានភារកិច្ច ដូចជា៖
    - ប្រជុំមួយត្រីមាសម្តង ដើម្បីត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាព
    - វាយតម្លៃហានិភ័យអំពើពុករលួយ
    - ទទួល និងដោះស្រាយបណ្តឹង គ្រប់ប្រភេទពីអ្នកពាក់ព័ន្ធ
    - ស៊ើបអង្កេតលើបណ្តឹង និងរាយការណ៍ទៅអ្នកគ្រប់គ្រងធនធានមនុស្ស និងផ្នែកច្បាប់ ដើម្បីដោះស្រាយ
- ក្រុមហ៊ុននឹងដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តកំហុសក្នុងកម្រិតរដ្ឋបាល វិន័យ និងព្រហ្មទណ្ឌ ប្តឹងទៅតុលាការ ។ ការិយាល័យនេះ ក៏បានរៀបចំជាវគ្គបណ្តុះបណ្តាលទៅលើគោលការណ៍ផ្សេងៗដល់និយោជិតខ្លួន តាមប្រព័ន្ធអ៊ីនធឺណែតផងដែរ ។ គោលបំណងនៃការបណ្តុះបណ្តាល គឺចង់ឱ្យរាល់និយោជិតទាំងអស់យល់នូវក្រមសីលធម៌របស់ក្រុមហ៊ុនចំពោះការអនុវត្តការងារប្រចាំថ្ងៃរបស់ពួកគេ ។

## D. គោលនយោបាយច្បាស់ៗសម្រាប់ទប់ស្កាត់អំពើពុករលួយ

គោលនយោបាយនេះ ជាមូលដ្ឋានប្រតិបត្តិការសម្រាប់ធាតុផ្សំជាក់ស្តែងផ្សេងទៀតទាំងអស់នៃកម្មវិធីប្រឆាំងអំពើពុករលួយ ។ គោលនយោបាយ ដាក់ចេញនូវគោលការណ៍ និងបទវិន័យ ហើយក៏ជាការកំណត់នូវការទប់ស្កាត់អំពើពុករលួយជាផ្លូវការផងដែរ ។ ដើម្បីយល់ច្បាស់ពីគោលនយោបាយបែបនេះ ក្រុមហ៊ុនចាំបាច់ត្រូវយល់ពីចំណុចនានាខាងក្រោម៖

### + និយមន័យនៃអំពើពុករលួយ

- មានច្រើនរូបភាពពេក ទើបនិយមន័យផ្លូវច្បាប់មួយមិនបានកំណត់ឡើងនៅក្នុង អនុសញ្ញា អ.ស.ប. ប្រឆាំងអំពើពុករលួយ (UNCAC) និងនៅក្នុងច្បាប់ប្រឆាំងអំពើពុករលួយជាច្រើន រួមទាំងច្បាប់របស់កម្ពុជាផងដែរ
- UNCAC ទុកឱ្យរដ្ឋភាគីកំណត់ជាក់ស្តែងខ្លួនឯង ហើយរដ្ឋភាគីអាចកំណត់ហួសពីបទដ្ឋានអប្បបរិមា UNCAC បាន ។

### + ការកំណត់ពីអំពើពុករលួយ

- អំពើពុករលួយមានដូចជា ស៊ីសំណូក គៃបំបាត់ រារាំងយុត្តិធម៌ ជំនួញឥទ្ធិពល ការលាក់បាំង ឬលាងសម្អាតផលនៃអំពើពុករលួយ អំពើពុករលួយក្នុងវិស័យឯកជន-រដ្ឋ ការរំលោភអំណាច និងមានទ្រព្យដោយខុសច្បាប់ ។ល។
- គោលនយោបាយ ដែលផ្តល់ព័ត៌មានពីការកំណត់នូវអំពើពុករលួយ និងវិសាលភាពនៃការអនុវត្តគោលនយោបាយ ជួយប្រែក្លាយការប្តេជ្ញាជារួមក្នុងការមិនអត់ឱនចំពោះអំពើពុករលួយ ឱ្យទៅជាសកម្មភាពជាក់ស្តែង និងអាចយល់បាន ។
- ការកំណត់ច្បាស់ៗ កាត់បន្ថយនូវចន្លោះប្រហោងក្នុងការបកស្រាយខុស ។ ឧទា. និយមន័យ «មន្ត្រីសាធារណៈ» ឬ «ប្រាក់សម្រួលការងារ» ចាំបាច់ត្រូវតែកំណត់ឱ្យច្បាស់ ។
- គោលនយោបាយគួរគិតឱ្យបានគ្រប់ជ្រុងជ្រោយដល់ទម្រង់ និងបញ្ហាប្រឈមផ្សេងៗ ឧទា. ស៊ីសំណូកអាចមានច្រើនទម្រង់ (ដូចជាប្រាក់សំណូក ឬប្រាក់ក្រៅច្បាប់) - ការចំណាយស្របច្បាប់ក៏អាចជាអំពើពុករលួយ ដូចជាអំណោយ ការទទួលបដិសណ្ឋារកិច្ច ការធ្វើដំណើរ ការកំសាន្ត ការឧបត្ថម្ភ ការចូលរួមសប្បុរសធម៌ និង/ឬការចូលរួមនយោបាយ ប្រសិនបើមិនត្រូវបានអនុញ្ញាតដោយច្បាប់ ។

## + គោលនយោបាយហាមឃាត់អំពើពុករលួយ

គោលនយោបាយបែបនេះ ជាទូទៅៈ

- ជាសារ ជាឯកសារផ្លូវការ ឧទា. ជាផ្នែកមួយនៃក្រមប្រតិបត្តិ ក្រមសីលធម៌ ឬឯកសារប្រហាក់ប្រហែលនេះ
- ប្រើភាសាច្បាស់ៗ និងងាយយល់ (បកប្រែ ជាភាសាដែលចាំបាច់)
- ងាយមើលឃើញ និងអាចទទួលបានពីគ្រប់ភាគីទាំងអស់ ទាំងក្នុង និងក្រៅក្រុមហ៊ុន
- អាចមានការពណ៌នាពីករណី ឬស្ថានភាព ដែលអាច ឬបានកើតឡើង ដើម្បីងាយស្រួលយល់ពីរបៀបអនុវត្តគោលនយោបាយ ក្នុងស្ថានភាពការងារប្រចាំថ្ងៃ ។

## + ពហុយុត្តាធិការច្បាប់

- ការកំណត់គោលនយោបាយ ចាំបាច់ត្រូវគិតពីយុត្តាធិការ ឬដែនសមត្ថកិច្ច ដែលក្រុមហ៊ុន អាចពាក់ព័ន្ធ ហើយនេះជាប្រការមួយសំខាន់ ជាពិសេសនៅពេលក្រុមហ៊ុនមានធុរកិច្ចទាក់ទងនឹងដៃគូ ឬអ្នកពាក់ព័ន្ធច្រើនប្រទេស ឧទា. ករណីប្រាក់សម្រួលការងារ អាចជាការស្មុគស្មាញ ព្រោះប្រទេសខ្លះហាមឃាត់ដាច់ខាត និងប្រទេសមួយចំនួនអនុញ្ញាតឱ្យមានប្រាក់បែបនេះខ្លះ ។
- ក្រុមហ៊ុនអាចកំណត់បទដ្ឋានគោលនយោបាយប្រឆាំងអំពើពុករលួយ ជាលក្ខណៈសាកលដូចៗគ្នានៅគ្រប់ប្រទេសដែលខ្លួនប្រកបធុរកិច្ច ។ បទដ្ឋានសាកលនេះផ្តល់ផលចំណេញៈ
  - ពង្រឹងការប្តេជ្ញា និងកេរ្តិ៍ឈ្មោះនៃគោលនយោបាយមិនអត់ឱនដល់អំពើពុករលួយ
  - កំណត់ការរំពឹងទុកច្បាស់លាស់ សម្រាប់បុគ្គលិក និងដៃគូទាំងអស់
  - ជៀសវាងការយល់ថា គោលនយោបាយប្រឆាំងអំពើពុករលួយ អនុវត្តតែពេលមានឱកាស ។
- ក្រុមហ៊ុនត្រូវត្រួតពិនិត្យបច្ចុប្បន្នភាព និងការបកប្រែនូវឯកសារផ្លូវច្បាប់សំខាន់ៗ ជាភាសាចាំបាច់ និងវាយតម្លៃថាតើគោលនយោបាយប្រឆាំងអំពើពុករលួយសាកលរបស់ក្រុមហ៊ុនត្រូវកែសម្រួល ឬអត់ ។

*សម្គាល់*

*+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs*

- SMEs អាចប្រឈមដូចក្រុមហ៊ុនធំៗដែរ ប៉ុន្តែអាចមានការលំបាកតិចជាងក្រុមហ៊ុនធំៗ ហើយបើមិនសូវមានប្រតិបត្តិការអន្តរជាតិ គឺកាន់តែងាយស្រួលក្នុងការកំណត់គោលនយោបាយសាកលសម្រាប់អំពើពុករលួយ
- ចាំបាច់ត្រូវមានឯកសារផ្លូវការ និងបោះពុម្ពពីគោលនយោបាយប្រឆាំងអំពើពុករលួយ
- អាចប្រើគំរូគោលនយោបាយប្រឆាំងអំពើពុករលួយ ដែលមានស្រាប់ (ឧទា. ផ្តល់ឱ្យដោយសមាគមរបស់ខ្លួន) ហើយកែសម្រួលស្របតាម តម្រូវការជាក់ស្តែងរបស់ខ្លួន
- អាចទទួលការគាំទ្រពីសភាពាណិជ្ជកម្មក្នុងស្រុក សមាគមពាណិជ្ជកម្ម ឬផ្នែកផ្សេងពីនេះ។

*+ ការរាយការណ៍*

- ក្រុមហ៊ុនគប្បីរាយការណ៍ពីកម្មវិធីប្រឆាំងអំពើពុករលួយ និងធាតុផ្សំដែលមាន
- រៀបរាប់ពីចំណុចដែលងាយមានហានិភ័យ នៅក្នុងគោលនយោបាយប្រឆាំងអំពើពុករលួយលម្អិត
- ពណ៌នាពីនីតិវិធី និងកិច្ចប្រឹងប្រែងទាក់ទងនឹងគោលនយោបាយនេះ និង
- ពណ៌នាពីកន្លែងដែលអាចរកគោលនយោបាយនេះបាន និងពីរបៀបផ្សព្វផ្សាយដល់បុគ្គលិក និងដៃគូធុរកិច្ច ។

## D. 1. យោធ៍បធដ្ឋានអន្តរជាតិ៖

សំណូកគ្រប់រូបភាពត្រូវហាមឃាត់ក្នុងរាល់ប្រតិបត្តិការធុរកិច្ចរួមមាន ទាក់ទងនឹងបុត្រសម្ព័ន្ធក្រុមហ៊ុន ភ្នាក់ងារតំណាង ទីប្រឹក្សា ឈ្មួញកណ្តាល អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ ឬនិយោជិត នៅពេលទាក់ទងនឹងមន្ត្រីរាជការ សមាជិកគ្រួសារ និងអ្នកពាក់ព័ន្ធជិតស្និទ្ធរបស់មន្ត្រីរាជការ ឬរបស់បេក្ខជនឈរឈ្មោះគណបក្សនយោបាយ ឬមន្ត្រីបក្ស បុគ្គលិកក្នុងវិស័យឯកជនណាមួយ ឬជនទី៣ ណាម្នាក់ ។ ព្រមជាមួយគ្នានេះ ក្រុមប្រឹក្សានាយក ឬអង្គស្មើណាមួយ គួរបង្ហាញពីការប្តេជ្ញាច្បាស់ៗ និងដោយសកម្មក្នុងការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយរបស់ខ្លួន ។

## D. 2. ករណីសិក្សា

*ក្រុមហ៊ុនផ្គត់ផ្គង់ផលិតផល និងសេវាកម្មដឹកជញ្ជូន កំណត់គោលនយោបាយសាជីវកម្មហាមឃាត់ការសូកប៉ាន់*

- ក្រុមហ៊ុន ដែលផ្គត់ផ្គង់ផលិតផល និងសេវាកម្មថ្នាក់អន្តរជាតិ ទាក់ទងនឹងឧស្សាហកម្មដឹកជញ្ជូន ហើយមានសាខា និងប្រតិបត្តិការនៅទូទាំងពិភពលោក ។ នៅឆ្នាំ ២០១១ ក្រុមហ៊ុន បានចរចាជាមួយនឹងក្រុមហ៊ុនទី៣ មួយ ដើម្បីទទួលបានកិច្ចសន្យាផ្គត់ផ្គង់ឧបករណ៍សម្រាប់សង់ផ្លូវនៅប្រទេសម៉ិកស៊ិក ។ ប៉ុន្តែដោយដឹងថា ក្រុមហ៊ុនទី៣ មានបំណងប្រើឥទ្ធិពលដែលពួកគេមានជាមួយនឹងមន្ត្រីរដ្ឋ ដើម្បីទទួលបានកិច្ចសន្យា ក្រុមហ៊ុនយល់ថាហានិភ័យមានខ្ពស់ ទើបបញ្ឈប់នូវការចរចាជាមួយក្រុមហ៊ុនទី៣ ។
- ក្រុមហ៊ុនក៏ចាប់ផ្តើមរៀបចំវិភាគ និងកំណត់អត្តសញ្ញាណស្រាវជ្រាវពីដៃគូកិច្ចសន្យា អ្នកអាចក្លាយជាដៃគូ និយោជិត បុគ្គលិក និងមន្ត្រីពាក់ព័ន្ធ ដើម្បីដឹង និងជៀសវាងការប្រព្រឹត្តអំពើពុករលួយ និងការជាប់ពាក់ព័ន្ធដល់ខ្លួន ។ ក្រុមហ៊ុនបានដាក់ចេញគោលនយោបាយសាជីវកម្មហាមឃាត់សំណូក ដោយក្នុងនេះ សំខាន់គឺ ក្រុមហ៊ុននឹងបញ្ចប់នូវទំនាក់ទំនងធុរកិច្ចភ្លាម នៅពេលរកឃើញថាដៃគូខ្លួនអាចពាក់ព័ន្ធ ឬប្រព្រឹត្តអំពើពុករលួយ ។
- ក្រុមហ៊ុនក៏បានចេញនូវសៀវភៅណែនាំពីការប្រឆាំងអំពើពុករលួយ សម្រាប់អនុវត្តផ្ទៃក្នុងដែលណែនាំអំពីនីតិវិធីតម្រូវមុនការចរចាចុះកិច្ចសន្យា ជាមួយភាគីទី៣ណាមួយ រួមមានការស្រាវជ្រាវប្រមូលព័ត៌មានពីភាគីទី ៣ ទោសទណ្ឌចំពោះការធ្វើខុស និងការអះអាងទទួលយល់ដឹង និងព្រមអនុវត្តតាមគោលនយោបាយក្រមសីលធម៌របស់ក្រុមហ៊ុនសម្រាប់បុគ្គលិកគ្រប់ៗរូប ។

## E. គោលនយោបាយលម្អិតសម្រាប់ផ្នែកហានិភ័យជាក់លាក់

- កិច្ចប្រឹងប្រែងក្នុងការឆ្លើយតបនឹងបញ្ហាអំពើពុករលួយ តាមរយៈការមានគោលនយោបាយ និងនីតិវិធី គឺសំខាន់ណាស់សម្រាប់ក្រុមហ៊ុន ហើយក៏មិនងាយស្រួលដែរ ជាពិសេស នៅពេលដែលមានភាពមិនច្បាស់លាស់រវាងការអនុវត្តផ្លូវច្បាប់ និងការប្រព្រឹត្តអំពើពុករលួយ ឧទា. ការផ្តល់អំណោយជាទង្វើទូទៅ ប៉ុន្តែច្បាប់ហាមឃាត់បើអំណោយនោះមានឥទ្ធិពលដល់ការសម្រេចចិត្ត
- អាចមានករណីមិនច្បាស់ច្រើន (grey areas) ពេលខ្វះ ដូច្នេះក្រុមហ៊ុនត្រូវគូសវាសឱ្យច្បាស់ពីការអនុវត្តស្របច្បាប់ និងមិនស្របច្បាប់ ។ បញ្ហាប្រឈមក្នុងការធ្វើដូច្នេះរួមមាន៖
    - ការអនុវត្តខុសច្បាប់ ប៉ុន្តែចាត់ទុកថាធម្មតា ឬជាតម្រូវការ (ឧទា. ប្រាក់សម្រួលការងារ)
    - ការអនុវត្តស្របច្បាប់ ប៉ុន្តែមានហានិភ័យអាចធ្វើខុស ដើម្បីបិទបាំងអំពើពុករលួយ (ឧទា. ការប្រើមិនត្រឹមត្រូវនៃវិភាគទាននយោបាយ អំណោយ ឬបដិសណ្ឋារកិច្ច ។ល។)
    - ការអនុវត្តផ្អែកលើការសម្រេចចិត្តដោយលម្អៀង (ឧទា.ទំនាស់ផលប្រយោជន៍) ។

### E. 1. ប្រាក់សម្រួលការងារ

- ប្រាក់សម្រួលការងារ គឺ៖
    - ជាប្រាក់ចំណាយក្រៅផ្លូវការ - ប្រាក់មិនត្រឹមត្រូវតិចតួចទៅមន្ត្រីថ្នាក់ទាប ដើម្បីទទួលបាន ឬពន្លឿនការបំពេញការងារប្រចាំថ្ងៃ ឬចាំបាច់ ដែលអ្នកបង់មានសិទ្ធិទទួលបានស្របច្បាប់ (ឧទា. ដើម្បីអាជ្ញាប័ណ្ណ និងសេវាសាធារណៈផ្សេងៗ)
    - ជាសំណួកនៅក្នុង UNCAC ហើយក៏ត្រូវបានហាមឃាត់នៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយកម្ពុជាដែរ
    - បើអត់ឱន អាចនាំឱ្យខូចដល់វប្បធម៌មិនអត់ឱនចំពោះអំពើពុករលួយរបស់ក្រុមហ៊ុនបាន ។

+ កាត់បន្ថយហានិភ័យនៃប្រាក់សម្រួលការងារ

- ការធ្វើធុរកិច្ចនៅប្រទេសខ្លះ ត្រូវប្រើប្រាក់សម្រួលការងារជាធម្មតា ឬចាំបាច់ ដូច្នេះក្រុមហ៊ុនក្នុងបរិស្ថាននេះ អាចបាត់បង់ការប្រកួតប្រជែង បើមិនផ្តល់ប្រាក់សម្រួលការងារដូចគេ ។ ប៉ុន្តែក្រុមហ៊ុនត្រូវដឹងថា ប្រាក់សម្រួលការងារ គឺជាបទល្មើសក្នុងច្បាប់ប្រទេសដែលខ្លួនធ្វើធុរកិច្ច (ដូចជានៅកម្ពុជាជាដើម) ដូច្នេះក្រុមហ៊ុនចាំបាច់ត្រូវដោះស្រាយហានិភ័យនៃប្រាក់សម្រួលការងារនេះ នៅក្នុងកម្មវិធីប្រឆាំងអំពើពុករលួយរបស់ខ្លួន ។
- ក្រុមហ៊ុនត្រូវមាននិយមន័យប្រាក់សម្រួលការងារច្បាស់លាស់ - គោលនយោបាយលម្អិត ហាមឃាត់ប្រាក់សម្រួលការងារសម្រាប់ទូទាំងក្រុមហ៊ុន (បើអាច) ទោះបីជានៅប្រទេសដែលប្រាក់សម្រួលការងារមិនខុសច្បាប់ ឬខុសច្បាប់តែការអនុវត្តច្បាប់ទាបក៏ដោយ ហើយក្រុមហ៊ុនក៏គប្បីមានការកំណត់ហានិភ័យ និងប្រឹងប្រែងកាត់បន្ថយហានិភ័យឱ្យបានគ្រប់ជ្រុងជ្រោយផងដែរ ។
- ដើម្បីបានព័ត៌មានពីភាពងាយរងគ្រោះនៅតាមតំបន់ផ្សេងៗគ្នា ក្រុមហ៊ុនគួរធ្វើការវាយតម្លៃហានិភ័យលម្អិត (ដើម្បីកំណត់ថាប្រាក់សម្រួលការងារងាយកើតនៅទីណា ឧទា. នៅពេលរៀបចំបើកការិយាល័យថ្មី)
- ការយល់ដឹងខ្ពស់ពីហានិភ័យនៃប្រាក់សម្រួលការងារ អាចឱ្យក្រុមហ៊ុនរៀបចំវគ្គបណ្តុះបណ្តាល និងឯកសារណែនាំបានល្អ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមធំៗ (ឧទា. របៀបកំណត់អត្តសញ្ញាណមន្ត្រីសាធារណៈបរទេស ឬរបៀបឆ្លើយតបនឹងការទារប្រាក់សម្រួលការងារសម្រាប់ការរត់ការទំនិញដែលងាយខូចខាតបានទាន់ពេល) ។
- ក្រុមហ៊ុនគួរមានវិធានការ និងការបណ្តុះបណ្តាលជាក់លាក់សម្រាប់បញ្ហាផ្សេងៗដែរ ដូចជាការទារប្រាក់ ឬការគំរាមដល់សន្តិសុខ និងសុវត្ថិភាព (ករណីបែបនេះ ក្រុមហ៊ុនអាចមានការលើកលែងក្នុងគោលនយោបាយប្រាក់សម្រួលការងារខ្លួន) ។
- ក្រុមហ៊ុនដែលមានឥទ្ធិពលលើទីផ្សារច្រើន គប្បីប្រើឥទ្ធិពលខ្លួនដើម្បីគាំទ្រដល់ការហាមឃាត់ប្រាក់សម្រួលការងារនៅក្នុងប្រទេសដែលមិនទាន់មានច្បាប់ពាក់ព័ន្ធ ឬខ្វះការអនុវត្តច្បាប់ ។

សម្គាល់

+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs

- មានការលំបាកខ្លាំងក្នុងរឿងប្រាក់សម្រួលការងារនេះ ដោយ SMEs ខ្វះស្ទើរតែរកស៊ី

មិនបាន បើមិនបង់ប្រាក់សម្រួលការងារ ព្រោះការមិនបង់អាចមានផលវិបាកអវិជ្ជមាន ដូចជា ការពន្យារប្រតិបត្តិការ ឬការខាតបង់ច្រើនជាងការបង់ប្រាក់សម្រួលការងារ ។ SMEs ក៏មិនមានឥទ្ធិពលទីផ្សារ ដើម្បីដាក់សម្ពាធនយោបាយឱ្យមានការផ្លាស់ប្តូរដែរ ។

- ទោះបីជាយ៉ាងណាក៏ដោយ SMEs គួរមានគោលនយោបាយ និងនីតិវិធីប្រឆាំងប្រាក់សម្រួលការងារដូចក្រុមហ៊ុនធំដែរ ឧទា. គួរមានដំណើរការច្បាស់លាស់ពេលមានការទារប្រាក់សម្រួលការងារ ដូចជា ការសុំយោបល់ពីម្ចាស់ SMEs ។ល។
- ឯកសារណែនាំ និងបណ្តុះបណ្តាល មានច្រើន និងអាចរកបាន ។ SMEs គួររកចំណាត់ការរួមជាមួយដៃគូជំនួញ និងអាចរកការគាំទ្របានពីសមាគមធុរកិច្ចក្នុងស្រុក ។ល។

+ <u>ការរាយការណ៍</u>

- ក្រុមហ៊ុនគប្បីរៀបរាប់ពីផ្នែកងាយរងហានិភ័យនៃអំពើពុករលួយ ដែលមានគោលនយោបាយប្រឆាំងអំពើពុករលួយលម្អិត
- ពណ៌នាពីនីតិវិធី និងកិច្ចប្រឹងប្រែងទាក់ទងនឹងគោលនយោបាយទាំងនេះ
- ពណ៌នាពីកន្លែងមានគោលនយោបាយទាំងនេះ និងរបៀបផ្តល់ដល់បុគ្គលិក និងដៃគូជំនួញ ។

## E. 2. ប្រភេទចំណាយពិសេសៗ

- ចំណាយបែបនេះ សំដៅលើប្រភេទចំណាយដែលអាចត្រូវបានធ្វើឡើងដើម្បីលាក់បាំងសំណូក ឬជំនួញឥទ្ធិពល រួមមានអំណោយបដិសណ្ឋារកិច្ច ការធ្វើដំណើរ ការកំសាន្ត វិភាគទាននយោបាយ វិភាគទានសប្បុរសធម៌ និងការឧបត្ថម្ភនានា ។
- អាស្រ័យដោយភាពស្របច្បាប់ជាទូទៅនៃការចំណាយបែបនេះ ក្រុមហ៊ុនត្រូវប្រឹងប្រែងធ្វើការប្រាស្រ័យទាក់ទងឱ្យបានច្រើន ពីហានិភ័យ និងភាពចាំបាច់ក្នុងការគោរពតាមគោលនយោបាយ និងនីតិវិធីគាំទ្រដល់ការទប់ស្កាត់ការចំណាយមិនត្រឹមត្រូវ ។
- ក្រុមហ៊ុនជួយបុគ្គលិកឱ្យចេះបែងចែករវាង ការប្រើប្រាស់ចំណាយស្របច្បាប់ និងសមស្រប និងការប្រើប្រាស់ចំណាយដើម្បីទទួលបានប្រយោជន៍មិនស្របច្បាប់ ។

+ <u>កាត់បន្ថយហានិភ័យចំណាយលើអំណោយ បដិសណ្ឋារកិច្ច ការធ្វើដំណើរ និងការកំសាន្ត</u>

- មូលហេតុមានចំណាយបែបនេះ មានដូចជាកសាងទំនាក់ទំនង - ថ្លែងអំណរគុណ - បង្ហាញសក្តានុពលក្រុមហ៊ុន ។ល។

- ហានិភ័យនៃការចំណាយបែបនេះ គឺមិនមែនកើតចេញពីការចំណាយហ្នឹងទេ តែពីកត្តាស្ថានភាព និងអសមាមាត្រ ឧទា. អញ្ជើញមន្ត្រីរដ្ឋពាក់ព័ន្ធរឿងលទ្ធកម្មទៅកំសាន្តពេលដេញថ្លៃ គឺពិតជានាំឱ្យមានការសង្ស័យ ។
- ក្រុមហ៊ុនគប្បីចាត់ទុកចំណាយបែបនេះ ថាជាចំណាយពិសេសនៅក្នុងកម្មវិធីប្រឆាំងអំពើពុករលួយខ្លួន ។
- ក្រុមហ៊ុនត្រូវមាននិយមន័យច្បាស់លាស់ពីការចំណាយបែបនេះ និងមានគោលនយោបាយលម្អិតសម្រាប់ទូទាំងក្រុមហ៊ុន ដោយហាមមិនឱ្យមានចំណាយបែបនេះ ដើម្បីបានប្រយោជន៍ខុសច្បាប់ ឬលួចលាក់បាំងប្រតិបត្តិការខុសច្បាប់ ។
- ក្រុមហ៊ុនគប្បីមានឯកសារណែនាំលម្អិតពីការចំណាយបែបនេះ (អាចរួមមានជាតារាងសម្រាប់ត្រួតពិនិត្យ ឬ Checklists) ដោយគិតពីវប្បធម៌ក្នុងស្រុក និងកាលៈទេសៈសេដ្ឋកិច្ចផ្សេងៗគ្នា ។ ក្រុមហ៊ុនក៏ត្រូវមាននីតិវិធីគ្រប់ជ្រុងជ្រោយដើម្បីកំណត់ហានិភ័យ និងជម្រើសកាត់បន្ថយផលវិបាកផងដែរ ។
- គោលការណ៍ណែនាំអាចកំណត់ព្រំដែនច្បាស់លាស់ និងតម្លាភាពទាក់ទងនឹងអំណោយបដិសណ្ឋារកិច្ច មធ្យោបាយធ្វើដំណើរ ឬប្រភេទនៃការកំសាន្ត - កម្រិតនៃការចំណាយ (គិតតាមតំបន់) - ប្រភេទនៃទំនាក់ទំនងជំនួញ និងឱកាស ។
- សកម្មភាពកាត់បន្ថយហានិភ័យនៃការយល់ខុសរបស់បុគ្គលិក ដោយចេតនា ឬអចេតនាទាក់ទងនឹងគោលនយោបាយ គោលការណ៍ និងការណែនាំអាចរួមមាន នីតិវិធីអនុម័ត (ឧទា. ការអនុម័តលើសពីម្នាក់ សម្រាប់ផលប្រយោជន៍ទាក់ទងនឹងមន្ត្រីរាជការ) - ការទទួលខុសត្រូវដែលបានកំណត់ (ឧទា. នរណាត្រូវដឹង) និងតម្រូវការ កត់ត្រាជាឯកសារ (ឧទា. កត់ត្រាអ្វី) ។

+ កាត់បន្ថយហានិភ័យនៃការផ្តល់វិភាគទាននយោបាយមិនត្រឹមត្រូវ

- ហានិភ័យអាចខុសច្បាប់ - ជះឥទ្ធិពលដល់ដំណើរការនយោបាយ និងការសម្រេចចិត្តដើម្បីប្រយោជន៍ខុសច្បាប់ - លួចលាក់បាំងដើម្បីប្រព្រឹត្តអំពើពុករលួយ ។
- ដូចចំណាយខាងលើដែរ គួរមានគោលនយោបាយលម្អិត និងកំណត់ប្រភេទវិភាគទានអនុញ្ញាត ឧទា. វិភាគទានដើម្បីគោលដៅនយោបាយ ឬសង្គម ដែលក្រុមហ៊ុនចង់គាំទ្រ ឬសម្រាប់សកម្មភាពផ្សព្វផ្សាយដើម្បីគាំទ្របក្សនយោបាយមួយជាដើម ប្រសិនបើមិនត្រូវបានហាមឃាត់ដោយច្បាប់ ។

- សកម្មភាពកាត់បន្ថយហានិភ័យមានដូចជា៖
    - ពេលវេលាសមស្រប (ឧទា. មិនផ្តល់ក្នុងពេលមានដំណើរការសម្រេចចិត្ត នយោបាយធំទេ)
    - កំណត់ព្រំដែននៃវិភាគទាន
    - រក្សាសៀវភៅ និងកំណត់ត្រាត្រឹមត្រូវ
    - វាយតម្លៃបុគ្គលិក និងដៃគូជំនួញ ដើម្បីកំណត់ពីទំនាស់ផលប្រយោជន៍
    - បង្កើតនីតិវិធីអនុម័ត (ឧទា. គោលការណ៍ភ្នែក 4 ក្នុងការអនុម័តផ្តល់)
    - ធ្វើការត្រួតពិនិត្យជាប្រចាំ
    - បង្ហាញការផ្តល់វិភាគទាននយោបាយ បើយល់ថាចាំបាច់ (លើកលែងច្បាប់កំណត់ឱ្យលាក់ការសម្ងាត់) ។
- ក្រុមហ៊ុនអាចធ្វើសកម្មភាពផ្សព្វផ្សាយទស្សនៈ និងជំនាញពួកគេ លើបញ្ហាគោលនយោបាយសាធារណៈ តាមរយៈការតស៊ូមតិ ឬការឡប់ប៊ីនយោបាយតាមរយៈអ្នកឡប់ប៊ី ប៉ុន្តែចាំបាច់ត្រូវធានាថា ការតស៊ូមតិមិនធ្វើដោយរំលោភបំពានតាមរយៈការបង់ប្រាក់អំណោយ ដើម្បីផលប្រយោជន៍ខុសច្បាប់ទេ ។

+ កាត់បន្ថយហានិភ័យនៃការផ្តល់វិភាគទានសប្បុរសធម៌ និងការឧបត្ថម្ភមិនត្រឹមត្រូវ

- ហានិភ័យគឺអាចកើតឡើងក្នុងព្រឹត្តិការណ៍កីឡា វប្បធម៌ អប់រំ ការបោះពុម្ព - អាចជាប្រាក់ ទំនិញ ឬសេវាកម្ម សមាជិកភាព ។ល។
- ហានិភ័យ គឺវិភាគទានបែបនេះ អាចត្រូវប្រើដើម្បីប្រយោជន៍ខុសច្បាប់ ឬល្បិចលាក់បាំងអំពើពុករលួយ ។
- ក្រុមហ៊ុនគប្បីមានគោលនយោបាយលម្អិត និងសកម្មភាពនានា ដូចបានរៀបរាប់ខាងលើដែរ ។

សម្គាល់

+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs

- SMEs មានហានិភ័យប្រហែលក្រុមហ៊ុនធំៗដែរ
- SMEs អាចផ្តោតលើការអនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលនយោបាយ និងនីតិវិធីទាក់ទងនឹងប្រយោជន៍ខុសច្បាប់ និងប្រយោជន៍ពិសេសបែបនេះ ។

+ ការរាយការណ៍

- ក្រុមហ៊ុនគប្បីរៀបរាប់ពីផ្នែកដែលអាចមានហានិភ័យអំពើពុករលួយ ដែលមានក្នុងគោលនយោបាយ ប្រឆាំងអំពើពុករលួយលម្អិត
- ពណ៌នាអំពីនីតិវិធី និងកិច្ចប្រឹងប្រែងទាក់ទងនឹងគោលនយោបាយទាំងនេះ
- ពណ៌នាអំពីកន្លែងដែលមានគោលនយោបាយនេះ និងរបៀបផ្តល់ពត៌មានដល់បុគ្គលិក និងដៃគូជំនួញ ។

## E. 3. ទំនាស់ផលប្រយោជន៍

- ក្រុមហ៊ុនអាចប្រឈមនឹងហានិភ័យដែរ បើការសម្រេចចិត្តពាណិជ្ជកម្មពឹងផ្អែកលើទំនាស់ផលប្រយោជន៍ ។
- ទំនាស់ផលប្រយោជន៍កើតឡើង ពេលបុគ្គលក្នុងក្រុមហ៊ុនមានផលប្រយោជន៍អាជីពផ្ទាល់ខ្លួន ឬឯកជនប្រជែងនឹងផលប្រយោជន៍ក្រុមហ៊ុន ឧទា. ប្រធានទីផ្សារក្រុមហ៊ុនផ្តល់ការឧបត្ថម្ភដល់ព្រឹត្តិការណ៍កីឡាមួយ ដែលគាត់ជាសមាជិកដឹកនាំព្រឹត្តិការណ៍កីឡានោះ ។
- ទំនាស់ផលប្រយោជន៍មាននៅគ្រប់អង្គភាព ប៉ុន្តែមិនមែនអវិជ្ជមានរហូតសម្រាប់ក្រុមហ៊ុនទេ ដូច្នេះពាក្យនេះ មិនគួរប្រើសម្រាប់សំដៅលើអាកប្បកិរិយាខុសច្បាប់ ឬអំពើពុករលួយទេ ។
- បុគ្គលិកមានទំនាស់ផលប្រយោជន៍អាចៈ
    - សម្រេចអ្វីដែលល្អបំផុតសម្រាប់ក្រុមហ៊ុនដែរ
    - ពាក់ព័ន្ធនឹងសកម្មភាពខាងក្រៅដែលស្របច្បាប់ និងមានផលចំណេញដល់ក្រុមហ៊ុន ក៏ដូចជាដល់ខ្លួនគាត់
    - ប៉ុន្តែស្ថានភាពនេះ អាចធ្វើឱ្យគេយល់ខុស និងអាចឱ្យមានចំណោទចំពោះការសម្រេចចិត្តខ្លះ ។
- ក្រុមហ៊ុនត្រូវដឹងពីប្រភេទទំនាស់ផលប្រយោជន៍នានា និងមានគោលនយោបាយ និងនីតិវិធីអាចដោះស្រាយបានសមរម្យ (ឧទា. មានយុទ្ធសាស្ត្រទំនាក់ទំនង និងកត់ត្រាច្បាស់លាស់ក្នុងករណីមានទំនាស់ផលប្រយោជន៍) ។

+ ប្រភពនៃទំនាស់ផលប្រយោជន៍

ប្រភពនៃទំនាស់ផលប្រយោជន៍ រួមមានៈ

- អំណោយ តាវកាលិក និងបដិសណ្ឋារកិច្ច៖ អាចជាទំនាស់ផលប្រយោជន៍ បើបុគ្គលិកគិតថា ទទួល ឬឱ្យហើយ នឹងបានប្រយោជន៍ខុសច្បាប់ ដែលមិនមែនជាប្រយោជន៍របស់ក្រុមហ៊ុន ។
- ការតែងតាំងពីក្រៅ៖ បើបុគ្គលិកមានតួនាទីនៅកន្លែងលើសពីមួយ ហើយត្រូវមានការសម្រេចចិត្តដែលនាំឱ្យមានការដោះដូរប្រយោជន៍សម្រាប់កន្លែងទាំង ២ ។
- តួនាទីផ្ទៃក្នុងស្របគ្នា៖ នៅពេលបុគ្គល ១ មានតួនាទី ២ ក្នុងក្រុមហ៊ុន (តួនាទីទំនាស់គ្នា) ។
- ការវិនិយោគហិរញ្ញវត្ថុ៖ បើបុគ្គលិកមានលម្អៀងទៅក្រុមហ៊ុនណាមួយ ដែលត្រូវធ្វើការវិនិយោគ ឧទា. ដេញថ្លៃរើសអ្នកផ្គត់ផ្គង់ ។
- ការជួលសាច់ញាតិ៖ បក្សពួក - បក្ខានុគ្រោះ - ផលវិបាកអវិជ្ជមានសម្រាប់ក្រុមហ៊ុន (ជាពិសេសបញ្ហាអសមត្ថភាព) ។
- ពាក់ព័ន្ធជាមួយមន្ត្រីសាធារណៈ៖ ទោះបីជាក្រុមហ៊ុនអាចបានចំណេញស្របច្បាប់ពីបទពិសោធន៍ និងចំណេះដឹងពីអតីតមន្ត្រីសាធារណៈ និងមន្ត្រីបច្ចុប្បន្ន ក៏ការពាក់ព័ន្ធនេះ ត្រូវតែត្រួតពិនិត្យដែរ ហើយត្រូវត្រួតពិនិត្យទាំងសងខាង ។

*+ កាត់បន្ថយហានិភ័យនៃទំនាស់ផលប្រយោជន៍*

- ត្រូវមាននិយមន័យទំនាស់ផលប្រយោជន៍ច្បាស់លាស់ និងគោលនយោបាយលម្អិត ហើយត្រូវឱ្យទាំងបុគ្គលិក និងដៃគូ និងភាគីពាក់ព័ន្ធខាងក្រៅដឹងដែរ ព្រោះទំនាស់ផលប្រយោជន៍ក៏រួមមានភាគីពីក្រៅដែរ (អំណោយ តាវកាលិក ឬការតែងតាំងពីក្រៅ) ។
- ទោះបីជាទំនាស់ផលប្រយោជន៍ មិនមែនជាការល្មើសច្បាប់ ក្រុមហ៊ុនក៏គប្បីមានគោលនយោបាយដែលមាន ឧទាហរណ៍រៀបរាប់ពីហានិភ័យនៃស្ថានភាពបែបនេះដែរ ។
- ក្រុមហ៊ុនអាចតម្រូវឱ្យបុគ្គលិក និងដៃគូជំនួញពាក់ព័ន្ធទាំងអស់ រួមមាន ទីប្រឹក្សា - ឈ្មួញកណ្តាល - សវនករ ឬអ្នកតំណាងដែលត្រូវបានជ្រើសរើស ដូចជា អ្នកនៅផ្នែកហិរញ្ញវត្ថុ ផ្នែកលក់ និងទីផ្សារ លទ្ធកម្ម និងធនធានមនុស្ស ប្រកាសពីទំនាស់ផលប្រយោជន៍ដែលអាចមាន ។
- ការប្រកាសបែបនេះ អាចឱ្យឃើញទំនាស់ផលប្រយោជន៍ដែលអាចមាន និងជួយជៀសវាងនូវស្ថានភាពដែលនាំឱ្យមានការសម្រេចចិត្តដោយលម្អៀង ដោយចេតនា ឬដោយចៃដន្យ ។

- ក្រុមហ៊ុនក៏គួរធ្វើការយកចិត្តទុកដាក់ស្គាល់អតិថិជនខ្លួនឱ្យច្បាស់ផងដែរ ក្នុងករណីប្រតិបត្តិការធំៗ និងគួរអនុវត្តនីតិវិធីដើម្បីកំណត់ទំនាស់ផលប្រយោជន៍ ។ ឧទា. ការធ្វើដូច្នេះ អាចបង្ហាញពីទំនាក់ទំនងផ្ទាល់ខ្លួនពីអតីតកាល ឬបច្ចុប្បន្នកាល រវាងអ្នកផ្គត់ផ្គង់ និងបុគ្គលិកក្រុមហ៊ុន ។

## + ឆ្លើយតបនឹងទំនាស់ផលប្រយោជន៍ដែលអាចមាន

- ល្អបំផុត គឺជៀសវាងស្ថានភាពដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ឧទា. មិនទទួលការតែងតាំងក្រៅក្រុមហ៊ុន ដែលអាចនាំឱ្យមានទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួន និងក្រុមហ៊ុន (បើអាច អនុញ្ញាតឱ្យមានតែករណីខ្លះដែលជៀសមិនរួចបានហើយ) ។
- ដកចេញនូវបុគ្គលិកដែលប្រឈមនឹងទំនាស់ផលប្រយោជន៍ ក្នុងស្ថានភាពជាក់លាក់ ។ ប៉ុន្តែករណីខ្លះពិបាកដក ឬដូរ បើក្រុមហ៊ុនខ្វះធនធាន ឬបុគ្គលនោះជាចំណុចទំនាក់ទំនងជាមួយអតិថិជនជាក់លាក់មួយ ។
- អាចមានភាគីទី៣ ណាមួយ វាយតម្លៃលើកិច្ចសន្យាដែលកំពុងចរចាគ្នា ។

## សម្គាល់

## + បញ្ហាប្រឈម និង ឱកាសសម្រាប់ SMEs

- SMEs អាចជួបបញ្ហាទំនាស់ផលប្រយោជន៍ជាងក្រុមហ៊ុនធំៗ ដោយសារទំនាក់ទំនងជិតស្និទ្ធនៅក្នុងសហគមន៍ ឬរចនាសម្ព័ន្ធម្ចាស់កម្មសិទ្ធិ
- ត្រូវមានគោលនយោបាយ និងនីតិវិធីទាក់ទងទំនាស់ផលប្រយោជន៍ច្បាស់លាស់ ជាពិសេសលើការវាយតម្លៃ និងប្រកាសទំនាស់ផលប្រយោជន៍ដែលមិនអាចជៀសបាន ឬដែលមិនអាចដក ឬដូរបុគ្គលិកបាន
- អាចរកការគាំទ្រពីសមាគមធុរកិច្ចក្នុងស្រុក សភាពាណិជ្ជកម្ម ។ល។

## + ការរាយការណ៍

- ក្រុមហ៊ុនគប្បីរៀបរាប់ពីផ្នែកដែលអាចមានហានិភ័យអំពើពុករលួយ ដែលមានក្នុងគោលនយោបាយ ប្រឆាំងអំពើពុករលួយលម្អិត
- ពណ៌នាអំពីនីតិវិធី និងកិច្ចប្រឹងប្រែងទាក់ទងនឹងគោលនយោបាយទាំងនេះ
- ពណ៌នាអំពីកន្លែងដែលមានគោលនយោបាយនេះ និងរបៀបផ្តល់ព័ត៌មានដល់បុគ្គលិក និងដៃគូជំនួញ ។

## E. 4. យោជបនដ្ឋានអន្តរជាតិ៖

ប្រាក់សម្រួលការងារ និងការចំណាយលើអំណោយ ក៏ដូចជាបដិសណ្ឋាកិច្ចគួរត្រូវហាមឃាត់ នៅពេលផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់ជាតិ ។ ដូចគ្នានេះដែរ ការផ្តល់វិភាគទានដែលធ្វើឡើងក្នុងរូបភាពសប្បុរសធម៌ និងនយោបាយមិនត្រូវធ្វើឡើងក្នុងគោលបំណងលាក់បំបាំងសំណូកទេ ពោលគឺត្រូវធ្វើឡើង ដោយតម្លាភាព និងស្របតាមបទបញ្ញត្តិនៃច្បាប់ជាតិ ។ ជារួម ក្រុមហ៊ុនគប្បីមានគោលនយោបាយ នីតិវិធីត្រឹមត្រូវ និងមានការត្រួតពិនិត្យច្បាស់លាស់លើចំណាយទាំងនេះ ។

## E. 5. ករណីសិក្សា

**ករណីសិក្សា E.5.1: ក្រុមហ៊ុនចម្រុះជាតិសាសន៍អាមេរិកមួយ ប្រើទម្រង់អេឡិចត្រូនិចដើម្បីអនុម័តលើអំណោយ និងការបង់ប្រាក់ដល់មន្ត្រីរដ្ឋ**

- ក្រុមហ៊ុន មានប្រតិបត្តិការនៅជាង ៣០ ប្រទេសនៅលើពិភពលោក ។ ទោះបីជាការប្រគល់អំណោយ ដែលគ្មានបំណងពុករលួយនៅប្រទេសមួយចំនួនអាចធ្វើបានក៏ដោយ ក៏នៅប្រទេសមួយចំនួនទៀត នេះជាទង្វើខុសច្បាប់ ហើយអាចនាំឱ្យអាជ្ញាធរអាមេរិក ចោទជាសំណួរបានពីបញ្ហានេះ ។ ដោយសារឥរិយាបថចំពោះអំណោយបដិសណ្ឋារកិច្ច និងការបង់ប្រាក់ក្រៅផ្លូវការ ងាយនឹងកើតមាន ក្រុមហ៊ុនអាចទទួលនូវហានិភ័យដែលមិនចាំបាច់ ពីការចំណាយបែបនេះបាន ។
- ក្រុមហ៊ុនបានបង្កើតគោលនយោបាយ ដោយតម្រូវឱ្យអ្នកគ្រប់គ្រងជាន់ខ្ពស់ម្នាក់អនុម័តលើការចំណាយបែបនេះ (មិនផ្តល់ឱ្យអ្នកគ្រប់គ្រងថ្នាក់មធ្យមសម្រេចទេ ដើម្បីកុំឱ្យពិបាកបដិសេធជាមួយថ្នាក់ក្រោម) តាមរយៈទម្រង់អនុម័តអេឡិចត្រូនិចសម្រាប់អំណោយបដិសណ្ឋារកិច្ច និងប្រាក់ក្រៅច្បាប់ដើម្បីធានាថា ថ្នាក់ដឹកនាំមានការដឹងឮ ហើយក៏មានបន្សល់នូវតម្រុយសម្រាប់ធ្វើសវនកម្ម (ឧទា. ពេលវេលាស្នើសុំត្រូវបានកំណត់ដោយកុំព្យូទ័រ) ។
- ប្រព័ន្ធនេះ មានតែសវនករ និងអ្នកស៊ើបអង្កេតទេ ដែលអាចមើលទិន្នន័យបែបនេះបាន ហើយប្រព័ន្ធនេះ ក៏មានប្រសិទ្ធភាពខ្ពស់ជាងអ៊ីមេលផងដែរ ។ ប៉ុន្តែការអនុម័តលើការចំណាយបែបនេះ ក៏លើកលែងករណីពិសេសៗដែរ ដូចជាការចំណាយលើមន្ត្រីរដ្ឋទៅទស្សនកិច្ចនៅសាខារបស់ក្រុមហ៊ុន នៅប្រទេសមួយ ដោយខានមិនបានជាដើម ។

**ករណីសិក្សា E.5.2៖ *ក្រុមហ៊ុនចម្រុះជាតិសាសន៍អាល្លឺម៉ង់មួយចេញគោលនយោបាយ ពីទស្សនកិច្ចគណៈប្រតិភូ***

- *ក្រុមហ៊ុនទទួលស្គាល់ពីសារៈសំខាន់ក្នុងការផ្តល់នូវដំណើរទស្សនកិច្ច ទៅត្រួតពិនិត្យមើលផលិតផល និងរោងចក្ររបស់ខ្លួន ព្រោះនេះជាផ្នែកមួយសំខាន់នៃគោលនយោបាយទីផ្សារស្របច្បាប់ ។ ដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់មកលើក្រុមហ៊ុនលើការចំណាយមិនត្រឹមត្រូវចំពោះការធ្វើដំណើរ និងការកំសាន្តដែលផ្តល់ដល់អតិថិជននោះ ក្រុមហ៊ុនក៏បានសម្រេចពង្រឹង និងកែសម្រួលកម្មវិធីអនុលោមតាមច្បាប់របស់ខ្លួននៅឆ្នាំ ២០០៨ ដើម្បីឈានទៅពង្រឹងឱ្យកាន់តែមានប្រសិទ្ធភាពនូវការទប់ស្កាត់រាល់ចំណាយមិនសមស្រប ។*
- *ក្រុមហ៊ុនបានកំណត់ថា ចំណាយត្រូវស្របតាមគោលបំណងធុរកិច្ចស្របច្បាប់ហើយកម្រិតនៃការទទួល និងការកំសាន្តត្រូវតែតូចល្មមសមនឹងពេលវេលា និងតម្លៃអាជីព ។ ក្រុមហ៊ុនក៏បានហាមឃាត់ការចំណាយលើការធ្វើដំណើរ និងការស្នាក់នៅលើកលែងតែមានការស្នើសុំជាលាយលក្ខណ៍អក្សរច្បាស់ៗពីអតិថិជន ឬក្នុងករណីពិសេសបំផុត ។ ការសងប្រាក់លើការចំណាយក្នុងទម្រង់ជាសាច់ប្រាក់ ត្រូវហាមឃាត់ដាច់ខាត ។*
- *ក្រុមហ៊ុនក៏បានដាក់ចេញនូវលក្ខខណ្ឌចាំបាច់មួយចំនួនដើម្បីប្រសិទ្ធភាព រួមមាន៖ (ក) ត្រូវមានការអនុម័តពីថ្នាក់គ្រប់គ្រងប្រតិបត្តិ ឬករណីខ្វះ ត្រូវមានការត្រួតពិនិត្យពីមន្ត្រីផ្នែកច្បាប់ ឬមន្ត្រីអនុលោមតាមច្បាប់ (ខ) ត្រូវមានឯកសារគ្រប់ជ្រុងជ្រោយរួមមានលិខិតអញ្ជើញ របៀបវារៈ ការទទួល និងការកំសាន្ត (រួមមានវិសាលភាព និងតម្លៃដែលផ្តល់ឱ្យ) (គ) ត្រូវគោរពច្បាប់ក្នុងស្រុក និងវិធានរបស់ក្រុមហ៊ុន ។*

## F. ការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយសម្រាប់ដៃគូធុរកិច្ច

- ដៃគូធុរកិច្ច រួមមាន៖
    - អ្នកផ្គត់ផ្គង់ អ្នកម៉ៅការ ភ្នាក់ងារ បុត្រសម្ព័ន្ធ និងអ្នកធ្វើធុរកិច្ចរួមគ្នា ។ល។
    - ខ្លះឯករាជ្យពេញលេញ ខ្លះមានទំនាក់ទំនងហិរញ្ញវត្ថុក្នុងទម្រង់តូច ឬធំ និងខ្លះអាចជាតំណាងឱ្យក្រុមហ៊ុន
    - ទំនាក់ទំនងអាចក្រៅផ្លូវការ - តាមកិច្ចសន្យាមួយៗ ឬសមាហរណកម្មជិតស្និទ្ធ ។
- បើដៃគូធុរកិច្ចមានបទដ្ឋានប្រឆាំងអំពើពុករលួយទាប នោះក្រុមហ៊ុនអាច៖
    - មានហានិភ័យអំពើពុករលួយ - ប៉ះពាល់កិត្តិយស
    - អាចត្រូវច្បាប់កំណត់ឱ្យទទួលខុសត្រូវការប្រព្រឹត្តមិនសមរម្យរបស់ដៃគូខ្លួន
    - ច្បាប់នៅតាមប្រទេសជាច្រើន តម្រូវឱ្យក្រុមហ៊ុនទទួលខុសត្រូវពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់ដៃគូខ្លួន ។

### + ប្រភេទទំនាក់ទំនងធុរកិច្ច

- ការកំណត់ប្រភេទទំនាក់ទំនង ជួយឱ្យក្រុមហ៊ុនវាយតម្លៃពីហានិភ័យបានគ្រប់គ្រាន់ និងកាត់បន្ថយផលវិបាកសម្រាប់ប្រទេសនីមួយៗ ។
- ជាទូទៅ ក្រុមហ៊ុនត្រូវមានគោលនយោបាយ និងបទដ្ឋានប្រហែលគ្នា សម្រាប់ដៃគូធុរកិច្ច ដែលពួកគេមានអំណាចត្រួតពិនិត្យ និងឥទ្ធិពលលើ
- គ្រប់ដៃគូធុរកិច្ចត្រូវដឹងពីគោលនយោបាយ និងនីតិវិធីរបស់ក្រុមហ៊ុន និងផលវិបាកពីការមិនអនុលោមតាមច្បាប់ ។
- ប្រភេទទំនាក់ទំនង មានដូចខាងក្រោម៖

#### ១) បុត្រសម្ព័ន្ធ (Subsidiaries)

- មានទំនាក់ទំនងជិតស្និទ្ធជាងគេ
- ក្រុមហ៊ុនមានឥទ្ធិពលលើ ប្រសិនបើក្រុមហ៊ុនមានការសម្រេចចិត្ត មានអំណាចគ្រប់គ្រងពីលើ និងមានអំណាចកំណត់សមាសភាពក្រុមប្រឹក្សានាយក ឬការសម្រេចចិត្តធុរកិច្ចធំៗរបស់បុត្រសម្ព័ន្ធ ។
- ក្រុមហ៊ុនគួរតម្រូវឱ្យបុត្រសម្ព័ន្ធ គោរពតាមគោលនយោបាយ និងនីតិវិធី ប្រឆាំងអំពើពុករលួយ ហើយកម្មវិធីប្រឆាំងអំពើពុករលួយ គួររៀបចំតាមហានិភ័យជាក់លាក់របស់បុត្រសម្ព័ន្ធ ។

## ២) ដៃគូទំនាក់ទំនង (Affiliates)

- ក្រុមហ៊ុនមានភាគហ៊ុនតិចតួច (ជាទូទៅទាបជាង ៥០%) ដូច្នេះក៏មានអំណាចត្រួតពិនិត្យតិចតួចដែរ ។
- ក្រុមហ៊ុន គួរលើកទឹកចិត្តឱ្យដៃគូទំនាក់ទំនងពង្រឹងប្រសិទ្ធភាពកម្មវិធីប្រឆាំងអំពើពុករលួយ ហើយក៏អាចជួយគាំទ្រដល់ពួកគេផងដែរ ។ បើដៃគូទំនាក់ទំនងមិនប្រឹងប្រែងប្រឆាំងអំពើពុករលួយ ក្រុមហ៊ុនគួរដកខ្លួនពីទំនាក់ទំនង ។

## ៣) ធុរកិច្ចរួមគ្នា (Joint Ventures)

- គោលការណ៍ចម្បងនៃកម្មវិធីប្រឆាំងអំពើពុករលួយ សម្រាប់ធុរកិច្ចរួមគ្នាគួរកំណត់ឱ្យបានមុនចាប់ផ្ដើម ។
- បើចាប់ផ្ដើម ហើយដៃគូមិនអាចអនុវត្តតាមបទដ្ឋានប្រឆាំងអំពើពុករលួយខ្លួនបានទេ ក្រុមហ៊ុនគួរដកខ្លួន ។

## ៤) ភ្នាក់ងារ និងឈ្មួញកណ្ដាល (Agents and intermediaries)

- អាចជាអង្គភាពដោយឡែក ឬបុគ្គលតំណាងឱ្យក្រុមហ៊ុន និងដែលក្រុមហ៊ុនមានឥទ្ធិពលកំណត់ទង្វើជាទូទៅក្នុងការងារប្រចាំថ្ងៃ ដូចជាការទទួលអាជ្ញាប័ណ្ណ ឬការអនុញ្ញាតផ្សេងទៀត ក៏ដូចជាក្នុងការអភិវឌ្ឍធុរកិច្ច រួមមាន ទីប្រឹក្សា តំណាងលក់ ភ្នាក់ងារគយ មេធាវី និងគណនេយ្យ ។
- ការពឹងផ្អែកលើភ្នាក់ងារ និងឈ្មួញកណ្ដាល អាចជាហានិភ័យធំសម្រាប់ក្រុមហ៊ុន ព្រោះពួកគេអាចចូលរួមក្នុងអំពើពុករលួយ ដោយក្រុមហ៊ុនមិនដឹង ដូច្នេះក្រុមហ៊ុនត្រូវមានគោលនយោបាយលម្អិត និងការគាំទ្រដោយ៖
  - ធ្វើការត្រួតពិនិត្យឱ្យបានហ្មត់ចត់ ក្នុងការជ្រើសរើសពួកគេ
  - ប្រាស្រ័យទាក់ទងជាមួយពួកគេអំពីគោលនយោបាយ និងនីតិវិធីក្រុមហ៊ុន
  - ទទួលការប្ដេជ្ញាជាផ្លូវការ និងជាលាយលក្ខណ៍អក្សរពីពួកគេ ចំពោះកម្មវិធីប្រឆាំងអំពើពុករលួយរបស់ក្រុមហ៊ុន (ឧទា. ជាផ្នែកមួយនៃកិច្ចសន្យារួមគ្នា)
  - បង្កើតដំណើរការលម្អិតទាក់ទងនឹងប្រាក់ឈ្នួល ឯកសារចំណាយ និងរក្សាកំណត់ត្រាទាក់ទងនឹងពួកគេ
  - គាំទ្រពួកគេ (ឧទា. ផ្ដល់ការបណ្ដុះបណ្ដាល)

        - ត្រួតពិនិត្យអាកប្បកិរិយាពួកគេជាប្រចាំ និង
        - អនុវត្តទោសទណ្ឌទាក់ទងការមិនអនុលោម និងលើកទឹកចិត្តពួកគេ សម្រាប់ការអនុលោមតាមច្បាប់ ។
    - វិសាលភាពការងារ គួរផ្អែកលើការវាយតម្លៃហានិភ័យលើពួកគេ (ឧទា. ភ្នាក់ងារពាក់ព័ន្ធមន្ត្រីរដ្ឋាភិបាលច្រើន ឬក្នុងឧស្សាហកម្មមានហានិភ័យខ្ពស់) ។

៥) <u>អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់ (Contractors and suppliers)</u>
    - ជាដៃគូសំខាន់ និងចាំបាច់សម្រាប់ជោគជ័យ និងនិរន្តរភាពជំនួញ ប៉ុន្តែក្រុមហ៊ុនអាចមិនមានឥទ្ធិពលលើពួកគេ ហើយពួកគេអាចមានច្រើន បើសិនជាក្រុមហ៊ុនមានទំហំធំ
    - អាចប៉ះពាល់ដល់កិត្តិយសក្រុមហ៊ុន និងអាចមានបញ្ហាបើពួកគេត្រូវបានតុលាការកាត់ឱ្យមានទោសពីបទល្មើសពុករលួយ និងមិនអាចបំពេញភារកិច្ចខ្លួនតាមកិច្ចសន្យាបាន
    - ដើម្បីកាត់បន្ថយហានិភ័យទាំងនេះ ក្រុមហ៊ុនត្រូវបង្ហាញពីការរំពឹងទុករបស់ខ្លួននៅក្នុងគោលនយោបាយលម្អិត (ឧទា. ជាផ្នែកមួយនៃក្រមសីលធម៌សម្រាប់អ្នកផ្គត់ផ្គង់) និងបង្កើតទម្លាប់កាត់បន្ថយផលវិបាកឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ។
    - ក្រុមហ៊ុនអាចសហការជាមួយដៃគូផ្សេងទៀតក្នុងការគ្រប់គ្រងទំនាក់ទំនង ជាមួយពួកគេ (ឧទា. ដោយធ្វើការបណ្តុះបណ្តាលការប្រឆាំងអំពើពុករលួយរួមគ្នា) ។

<u>+ គ្រប់គ្រងហានិភ័យទំនាក់ទំនងធុរកិច្ច</u>

- ក្រុមហ៊ុនត្រូវធ្វើការយកចិត្តទុកដាក់ស្គាល់អតិថិជន ក្នុងការជ្រើសរើសដៃគូធុរកិច្ច និងការត្រួតពិនិត្យទំនាក់ទំនង ។
- ក្នុងការជ្រើសរើសដៃគូធុរកិច្ច ក្រុមហ៊ុនត្រូវ៖
    - យកចិត្តទុកដាក់ស្គាល់អតិថិជនទាំងលើទិដ្ឋភាពយុទ្ធសាស្ត្រ ពាណិជ្ជកម្ម ប្រតិបត្តិការកេរ្តិ៍ឈ្មោះ និងហានិភ័យនៃអំពើពុករលួយ ហើយត្រូវធ្វើការងារនេះមុនសម្រេចជ្រើសរើស ដើម្បីរកហានិភ័យ និងសកម្មភាពដែលអាចកាត់បន្ថយហានិភ័យបាន
    - មានដំណើរការ និងតម្រូវការឯកសារច្បាស់លាស់ដើម្បីទប់ស្កាត់ភាពមិនប្រក្រតី (ឧទា. ទំនាស់ផលប្រយោជន៍) ។

- ការយកចិត្តទុកដាក់ស្គាល់អតិថិជន អាចរួមមានការឆែកមើលផ្នែកមានហានិភ័យអំពើពុករលួយ និងផ្នែកហានិភ័យជាក់លាក់នៃទំនាក់ទំនង ដូចជា៖
    - ឆែកមើលស្ថានភាពច្បាប់ និងប្រភេទអង្គភាពរបស់ដៃគូជំនួញ រួមមានយុត្តាធិការនៃសាជីវកម្ម
    - វាយតម្លៃការពឹងផ្អែកលើហិរញ្ញវត្ថុ ឬអង្គភាព និងរចនាសម្ព័ន្ធនៃម្ចាស់កម្មសិទ្ធិរបស់ដៃគូជំនួញ
    - កំណត់ទំនាស់ផលប្រយោជន៍ដែលអាចមាន នៃបុគ្គលិកសំខាន់ៗរបស់ដៃគូជំនួញ
    - វាយតម្លៃពីការប្តេជ្ញាប្រឆាំងអំពើពុករលួយ ពីថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់ដៃគូជំនួញ (ឧទា. តាមរយៈការពិគ្រោះយោបល់ជាមួយដៃគូផ្សេងៗ សមាគមពាណិជ្ជកម្មក្នុងស្រុក ស្ថានទូត ។ល។)
    - ត្រួតពិនិត្យមើលកំណត់ត្រាទាក់ទងអំពើពុករលួយ (ឧទា. បញ្ហាដែលមានកន្លងមក)
    - វាយតម្លៃគុណភាពនៃកម្មវិធីប្រឆាំងអំពើពុករលួយ ដែលមានរបស់ដៃគូជំនួញ ។
- ផ្អែកលើលទ្ធផលនៃការយកចិត្តទុកដាក់ស្គាល់អតិថិជន ក្រុមហ៊ុនត្រូវរៀបចំសកម្មភាពកាត់បន្ថយផលវិបាកពាក់ព័ន្ធ រួមមាន ការប្តេជ្ញាជាផ្លូវការ និងជាលាយលក្ខណ៍អក្សររបស់ដៃគូ ចំពោះក្រមសីលធម៌របស់ក្រុមហ៊ុន - ការចូលរួមបណ្តុះបណ្តាល ឬការផ្តល់ព័ត៌មានពីកម្មវិធីប្រឆាំងអំពើពុករលួយរបស់ដៃគូជំនួញ ។
- បើមិនច្បាស់ មិនមានព័ត៌មាន ឬមិនអាចលើកទឹកចិត្តដៃគូជំនួញឱ្យធ្វើសកម្មភាពកាត់បន្ថយហានិភ័យបាន គឺមិនគួរពាក់ព័ន្ធជាមួយពួកគេទេ ។

+ ការត្រួតពិនិត្យដៃគូជំនួញ

- វិសាលភាព គឺអាស្រ័យលើហានិភ័យទូទៅ ឧទា. ការត្រួតពិនិត្យមើលត្រឹមការប្តេជ្ញាជាផ្លូវការ និងលាយលក្ខណ៍អក្សរ អាចគ្រប់គ្រាន់ ។
- ក្នុងផ្នែកមានហានិភ័យខ្ពស់ ក្រុមហ៊ុនអាចធ្វើការវិភាគលម្អិតពីកម្មវិធីប្រឆាំងអំពើពុករលួយ រួមមាន ការសម្ភាសន៍ភាគីពាក់ព័ន្ធ និងការវាយតម្លៃរបស់អ្នកជំនាញ ។
- ការត្រួតពិនិត្យអាចធ្វើតាមរយៈ៖
    - ស្វ័យវាយតម្លៃ៖ ក្រុមហ៊ុនអាចតម្រូវថា ដៃគូជំនួញផ្តល់ព័ត៌មានពីស្ថានភាពនៃកម្មវិធីប្រឆាំងអំពើពុករលួយរបស់ខ្លួនតាមរយៈទម្រង់ស្វ័យវាយតម្លៃ

- ការស៊ើបអង្កេតផ្ទាល់ខ្លួន៖ ក្រុមហ៊ុនអាចធ្វើការវិភាគផ្ទាល់ខ្លួន ដើម្បីវាយតម្លៃពីកម្រិតនៃគុណភាព និងវិសាលភាពនៃកម្មវិធីប្រឆាំងអំពើពុករលួយរបស់ដៃគូជំនួញដោយអាចផ្អែកលើការស្រាវជ្រាវ និងព័ត៌មានសារតា ឬតាមរយៈការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយដៃគូ
- ការវាយតម្លៃឯករាជ្យ៖ ធ្វើដោយភាគីទី ៣ ។

- គួរធ្វើឱ្យបានទៀងទាត់ ដោយសារហានិភ័យកំណត់បាននៅគ្រាដំបូងអាចប្រែប្រួល និងអាចធ្វើការត្រួតពិនិត្យជាពិសេសសម្រាប់ដៃគូជំនួញដែលមានហានិភ័យខ្ពស់
- ការទទួលខុសត្រូវចម្បងក្នុងការជ្រើសរើស និងត្រួតពិនិត្យ គឺជាមុខងារប្រតិបត្តិការធុរកិច្ច ដែលគាំទ្រដោយក្រុមអ្នកជំនាញច្បាប់ហិរញ្ញវត្ថុ និងជំនាញផ្សេងៗទៀត (អាស្រ័យលើទំហំរបស់ក្រុមហ៊ុនដែរ) និងអាចរួមមានផងដែរនូវតំណាងពីផ្នែកសវនកម្ម ឬទីប្រឹក្សាផ្ទៃក្រៅ ហើយក៏គួរត្រូវមានការកត់ត្រា និងរាយការណ៍ពីលទ្ធផលដែលទទួលបានទៅក្រុមប្រឹក្សានាយក គណៈកម្មការសវនកម្ម ឬអង្គត្រួតពិនិត្យផ្សេងពីនេះរបស់ក្រុមហ៊ុន ។

+ ការលើកទឹកចិត្តដៃគូជំនួញឱ្យគោរពតាមបទដ្ឋានក្រុមហ៊ុន

- បើក្រុមហ៊ុនមិនមានឥទ្ធិពលលើដៃគូច្រើនទេ ក្រុមហ៊ុនត្រូវពិចារណាលើវិធានការលើកទឹកចិត្ត ឬដាក់ទណ្ឌកម្ម ដូចជា៖
    - ផ្តាច់ការទំនាក់ទំនង (លុបកិច្ចសន្យា) - ហាមឃាត់ពីឱកាសជំនួញ ឬផ្តល់លក្ខខណ្ឌជំនួញដែលមិនអំណោយផល ឬឱកាសជំនួញដែលអំណោយផល (ឧទា. កាត់បន្ថយភាពញឹកញាប់ក្នុងការត្រួតពិនិត្យពីលើ) (នេះ គឺសម្រាប់ទណ្ឌកម្ម ឬការលើកទឹកចិត្តបែបពាណិជ្ជកម្ម)
    - ពិន័យ សំណងលើការខូចខាត ឬបន្ថយទោសដោយសារអាកប្បកិរិយាកែខ្លួន (រដ្ឋជាច្រើនអនុវត្តវិធីនេះ) (នេះគឺសម្រាប់ទណ្ឌកម្ម ឬការលើកទឹកចិត្តតាមផ្លូវច្បាប់)
    - បោះពុម្ពព្រឹត្តិការណ៍ទាក់ទងការប្រឆាំងនឹងអំពើពុករលួយរួមមាន ទណ្ឌកម្ម ឬការលើកទឹកចិត្តទាក់ទងនឹងកេរ្តិ៍ឈ្មោះ (អាចរៀបចំធ្វើដោយសមាគមពាណិជ្ជកម្ម) ។
- ការលើកទឹកចិត្តសម្រាប់ការកាត់បន្ថយផលវិបាក គួរត្រូវប្រើសម្រាប់ស្ថានីតិសម្បទាក្រុមហ៊ុនដែលបានកែលម្អអាកប្បកិរិយាប្រឆាំងអំពើពុករលួយ ។

*សម្គាល់*

*+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs*

- SMEs អាចមានការលំបាកក្នុងការអនុវត្តបទដ្ឋានប្រឆាំងអំពើពុករលួយខ្លួនតាមរយៈ វិធានការលុប ឬផ្ដាច់ទំនាក់ទំនងជំនួញ ប៉ុន្តែ SMEs ក៏គប្បីធ្វើការត្រួតពិនិត្យឱ្យ បាន ហ្មត់ចត់ដែរ ព្រោះបើមានបញ្ហាពាក់ព័ន្ធ គឺទទួលផលវិបាកដូចក្រុមហ៊ុនធំៗដែរ
- SMEs អាចរកទីប្រឹក្សាផ្នែកក្រៅ ដើម្បីធ្វើការវាយតម្លៃហានិភ័យបឋម ។

*+ ការរាយការណ៍*

- ក្រុមហ៊ុនគប្បីរៀបរាប់ពីនិយមន័យ និងវិសាលភាពដៃគូជំនួញ (អ្នកផ្គត់ផ្គង់ ភ្នាក់ងារ ដៃគូធុរកិច្ចរួមគ្នា)
- ពណ៌នាអំពីរបៀបធ្វើការប្ដេជ្ញាចិត្តប្រឆាំងអំពើពុករលួយរបស់ក្រុមហ៊ុន ចំពោះដៃគូ ជំនួញ ក៏ដូចជាពីដៃគូជំនួញទៅក្រុមហ៊ុនវិញ
- ពណ៌នាអំពីកម្រិតខ្សែសង្វាក់ផ្គត់ផ្គង់ ដែលគោលនយោបាយប្រឆាំងអំពើពុករលួយ គ្របដណ្ដប់ដល់ (ទំហំ ឬប្រភេទអ្នកផ្គត់ផ្គង់ - អ្នកផលិត)
- បញ្ជាក់ពីគោលនយោបាយលម្អិតសម្រាប់ដៃគូជំនួញ
- ពណ៌នាអំពីវិធានការទំនាក់ទំនងជាក់លាក់ និងចំណាត់ការនានា ដូចជាការបណ្ដុះ បណ្ដាលដែលមាន ដើម្បីលើកទឹកចិត្តដល់ដៃគូជំនួញឱ្យអនុវត្តកម្មវិធីប្រឆាំងអំពើពុក រលួយ
- ពណ៌នាអំពីដំណើរការត្រួតពិនិត្យប្រសិទ្ធភាព នៃវិធានការប្រាស្រ័យទាក់ទង និង ចំណាត់ការទាំងនោះ
- ផ្ដល់ព័ត៌មាន និងចំណាត់ការជាក់ស្ដែងដែលបានធ្វើ ឬផលដែលទទួលបាន ។

## F. 1. យោជ័បដជ្ឋានអន្តរជាតិ

សាជីវកម្មគួរត្រូវហាមឃាត់ការសូកប៉ាន់ លើគ្រប់ប្រតិបត្តិការធុរកិច្ចទាំងឡាយ ដោយ ផ្ទាល់ ឬតាមរយៈអ្នកទី៣ និងតាមរយៈប្រភេទនៃទំនាក់ទំនងអាជីវកម្មផ្សេងៗ ដែលស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់ខ្លួន ។ សាជីវកម្មដែលមានសិទ្ធិគ្រប់គ្រងធំជាងគេ ត្រូវតែអនុវត្ត កម្មវិធីប្រឆាំងអំពើពុករលួយនៅគ្រប់អង្គភាពធុរកិច្ច និងប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ដោយ ជំរុញឱ្យមានកម្មវិធីនេះ នៅរាល់ទំនាក់ទំនងពាណិជ្ជកម្ម ដែលខ្លួនបានវិនិយោគជាមួយ ។

សាជីវកម្មត្រូវតែធ្វើការរៀបចំឯកសារឱ្យបានត្រឹមត្រូវ ដោយធ្វើការយកចិត្តទុកដាក់ស្គាល់អតិថិជន នៃសាជីវកម្មដែលខ្លួនមានបំណងចង់ទាក់ទងជាមួយ រួមមាន ការរួមបញ្ចូលគ្នា ការទិញយក និងការវិនិយោគ ។ សាជីវកម្មត្រូវមានសិទ្ធិក្នុងការបញ្ឈប់ទំនាក់ទំនងធុរកិច្ចក្នុងករណីសាជីវកម្មដែលខ្លួនមានទំនាក់ទំនងធុរកិច្ចជាមួយ មានជាប់ពាក់ព័ន្ធក្នុងសកម្មភាពសូកប៉ាន់ ។

## F. 2. ករណីសិក្សា

**ករណីសិក្សា F.2.1៖ *ក្រុមហ៊ុនចម្រុះជាតិសាសន៍ C ដែលមានធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានអនុវត្តកិច្ចសន្យាប្រឆាំងការសូកប៉ាន់ ជាមួយដៃគូរផ្គត់ផ្គង់របស់ខ្លួន***

- ជាក្រុមហ៊ុនភេសជ្ជៈចម្រុះជាតិសាសន៍ ដែលមានម៉ាកផលិតផលល្បីល្បាញ នាំមុខគេលើពិភពលោក និងមានការលក់ចេញខ្ពស់រយៈពេលជាង១០០ឆ្នាំ មកហើយ ។ ក្រុមហ៊ុនបាននឹងកំពុងធ្វើធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីរក្សាឈ្មោះជាក្រុមហ៊ុនដែលអនុវត្តប្រតិបត្តិការធុរកិច្ចស្អាតស្អំ រាល់ដៃគូផ្គត់ផ្គង់ទាំងអស់ ដែលមានទំនាក់ទំនងធុរកិច្ចជាមួយ នឹងត្រូវតម្រូវឱ្យចុះកិច្ចសន្យាបន្ថែម លើបទបញ្ញត្តិក្នុងការប្រឆាំងការសូកប៉ាន់ ។
- រាល់ដៃគូរធុរកិច្ចទាំងអស់ត្រូវសន្យា និងគោរពឱ្យបានថា ក្នុងការធ្វើធុរកិច្ច ឬមានទំនាក់ទំនងធុរកិច្ចជាមួយអាជីវកម្មដទៃទៀតដែលពាក់ព័ន្ធជាមួយក្រុមហ៊ុន C ពួកគេពុំអាចផ្តល់ការសន្យា ផ្តល់អំណោយមានតម្លៃ ដោយផ្ទាល់ ឬប្រយោល ដល់មន្ត្រីរាជការ ឬបុគ្គលិករបស់ក្រុមហ៊ុនណាដែលគ្រប់គ្រងដោយរដ្ឋ ឬបក្សនយោបាយណាមួយ ដើម្បីទទួលផលប្រយោជន៍មិនស្របច្បាប់ណាមួយឡើយ ។ ក្រុមហ៊ុន C នឹងមិនផ្តល់សំណងដល់ដៃគូរធុរកិច្ចណាបានធ្វើការសូកប៉ាន់ ដែលផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់នៃប្រទេសដើមរបស់ក្រុមហ៊ុន C ឡើយ ។ រាល់ការចំណាយដោយដៃគូផ្គត់ផ្គង់ និងកម្មករនិយោជិតដែល តំណាងឱ្យក្រុមហ៊ុន C ទាំងអស់ត្រូវមានកំណត់ត្រាគណនេយ្យត្រឹមត្រូវ ហើយនិងត្រូវចម្លងជូនក្រុមហ៊ុន C ផងដែរ ។
- ក្រុមហ៊ុន C រក្សាសិទ្ធិក្នុងការបញ្ចប់កិច្ចសន្យាជាមួយដៃគូក្នុងករណី (១) រំលោភលើកិច្ចសន្យាជាមួយខ្លួន (២) លួចបន្លំក្នុងប្រតិបត្តិការនៃកិច្ចសន្យា (៣) កែប្រែព័ត៌មានក្នុងកិច្ចសន្យា (៤) ក្នុងករណីដែលក្រុមហ៊ុន C ជឿជាក់ថា ដៃគូរធុរកិច្ចមានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តមិនស្របច្បាប់ ឬមិនស្របតាមក្រមសីលធម៌ ។

**ករណីសិក្សា F.2.2៖ *ក្រុមហ៊ុន K ធ្វើការយកចិត្តទុកដាក់ស្គាល់អតិថិជន ដែលជាភាគីទី៣របស់ខ្លួន***

- *ជាក្រុមហ៊ុនហេដ្ឋារចនាសម្ព័ន្ធ និងវិស្វកម្មសំណង់នាំមុខគេលើពិភពលោក ដែលមានបុគ្គលិកចំនួន៥ម៉ឺន នាក់ ធ្វើប្រតិបត្តិការនៅ ៨០ ប្រទេស ហើយធ្វើប្រតិបត្តិការក្នុងផ្នែកមួយដែលមានហានិភ័យពុករលួយខ្ពស់ ដោយសារជាញឹកញយត្រូវការដាក់ឱ្យដេញថ្លៃសម្រាប់គម្រោងធំៗ ទាំងសាធារណៈ និងឯកជន ។*
- *ក្រុមហ៊ុនទទួលស្គាល់ថា ខ្លួនអាចនឹងរងនូវការខូចកេរ្តិ៍ឈ្មោះ និងខុសច្បាប់ ប្រសិនបើដៃគូធុរកិច្ច ជាភាគីទី៣ ប្រព្រឹត្តមិនស្របច្បាប់ មិនអនុលោមតាមក្រមសីលធម៌ និងពុំមានសុចរិតភាព ។ ក្រុមហ៊ុនបានធ្វើការយកចិត្តទុកដាក់ស្គាល់អតិថិជនដោយផ្តោតសំខាន់លើហានិភ័យរបស់ភាគីទី៣ តាមរយៈការស្វែងយល់ឱ្យច្បាស់អំពីកេរ្តិ៍ឈ្មោះ និងប្រវត្តិរបស់ភាគីទី៣ ដើម្បីជៀសវាងភាគីទី៣ដែលមានប្រវត្តិពុករលួយ ។*
- *ក្រុមហ៊ុន K បានរៀបចំបញ្ជីការងារត្រួវត្រួតពិនិត្យ សម្រាប់វាយតម្លៃហានិភ័យអំពើពុករលួយដែលអាចមានក្នុងគម្រោងកំពុងត្រូវបានពិចារណា និងហានិភ័យលទ្ធកម្ម និងការត្រួតពិនិត្យផ្សេងៗទៀត ជុំវិញដំណើរការ ការដាក់ដេញថ្លៃគម្រោងដើម្បីធានាថាការដេញថ្លៃនេះស្របតាមតម្រូវការ និងមានគុណភាព ។ បញ្ជីនេះមានទាក់ទងនឹង៖*

    - **ទង់ក្រហម (Red Flag) និងយុត្តិកម្មធុរកិច្ច (Business Justification)៖** *ក្រុមហ៊ុនប្រើបញ្ជីផែកទង់ក្រហម និង យុត្តិកម្មធុរកិច្ច ដើម្បីកំណត់ និងកាត់បន្ថយហានិភ័យជាប់ទាក់ទងជាមួយដៃគូភាគីទី៣*
    - **ភ្នាក់ងារ និងប្រាក់កម្រៃជើងសារ៖** *ក្រុមហ៊ុន ជៀសវាងការប្រើភ្នាក់ងារច្រើនព្រោះពិបាកត្រួតពិនិត្យ*
    - **ការការពារកិច្ចសន្យា៖** *ភាគីទី៣ ត្រូវអនុលោមតាមគោលការណ៍ច្បាប់ប្រឆាំងអំពើពុករលួយ និងតាមនីតិវិធីរបស់ក្រុមហ៊ុន ។ ក្រុមហ៊ុនក៏មានសិទ្ធិធ្វើសវនកម្មលើដៃគូដែលជាភាគីទី៣ដែលមានហានិភ័យខ្ពស់ផងដែរ ។*

**ករណីសិក្សា F.2.3៖** *ក្រុមហ៊ុនសំណង់ និងវិស្វកម្ម L ដែលមានមូលដ្ឋាននៅប្រទេសអូស្ត្រាលី ផ្តល់ការអប់រំដល់អ្នកម៉ៅការរបស់ខ្លួនអំពីការរំពឹងទុករបស់ក្រុមហ៊ុន*

- *ជាក្រុមហ៊ុនមានមូលដ្ឋាននៅប្រទេសអូស្ត្រាលី និងជាបុត្រសម្ព័ន្ធរបស់សាជីវកម្មវិស្វកម្មសហរដ្ឋអាមេរិកមួយ ក្រុមហ៊ុនបានទទួលកិច្ចសន្យា តម្លៃ១៣លានដុល្លារអាមេរិក សម្រាប់ពង្រីង និងបន្តទីតាំងរាវអគ្គិសនីចំងាយប្រហែល៣០០គ.ម ពីទីក្រុងធំមួយនៅតំបន់អាស៊ីអាគ្នេយ៍ ។*
- *ក្រុមហ៊ុនមានទំនាក់ទំនងជាមួយអ្នកម៉ៅការក្នុងប្រទេសនោះ ជាជំនួយដល់ការសាងសង់គម្រោង ហើយអ្នកម៉ៅការទាំងនេះមានលក្ខណៈជាគ្រួសារ និងពុំមានក្រមនីតិវិធី និងគោលការណ៍លម្អិត ។ ក្រុមហ៊ុនបានរៀបចំនីតិវិធីជាច្រើន ដើម្បីធានាថាអ្នកម៉ៅការនីមួយៗ បានយល់ពីកាតព្វកិច្ចរបស់ខ្លួនដោយពុំអាចផ្តល់ការសន្យា ផ្តល់សំណូក ឬផលប្រយោជន៍ទៅដល់មន្ត្រីសាធារណៈឡើយ ។ ក្រុមហ៊ុនបានរៀបចំជាសិក្ខាសាលា និងបានអញ្ជើញអ្នកម៉ៅការទាំងនោះចូលរួមស្តាប់ និងបានបង្ហាញអំពីទស្សនៈក្រមសីលធម៌ និងវប្បធម៌របស់ក្រុមហ៊ុន វិធីសាស្ត្រនៃការសហការ និងអំពីគោលការណ៍មិនអនុគ្រោះ សម្រាប់ការប្រព្រឹត្តមិនស្របច្បាប់ និងមិនត្រឹមត្រូវ ក៏ដូចជាការតម្រូវឱ្យរាយការណ៍ដល់ក្រុមហ៊ុននូវភាពមិនប្រក្រតី ដែលអាចមាន ។*
- *ក្នុងពេលសាងសង់គម្រោង ក្រុមហ៊ុនបានធ្វើសវនកម្មលើកំណត់ត្រាអ្នកម៉ៅការទាំងនោះជាលក្ខណៈចោះៗ ។ នៅពេលបញ្ចប់គម្រោង ទំនាក់ទំនងដែលមានក្នុងកិច្ចសន្យាក៏ត្រូវបានបញ្ចប់ផងដែរ ។*

## G. ការត្រួតពិនិត្យផ្ទៃក្នុង និងការកត់ត្រាឯកសារ

- ជំនួញគួរផ្អែកលើជំនឿចិត្តគ្នាទៅវិញទៅមក ។ ជំនឿរវាងផ្នែកគ្រប់គ្រង និងបុគ្គលិក ក៏ដូចជាដៃគូ មានសារៈសំខាន់សម្រាប់បរិយាកាសការងារ ។ ដូច្នេះហើយ ផ្នែកគ្រប់គ្រង បុគ្គលិក និងដៃគូ ត្រូវធ្វើសកម្មភាពស្របតាមតម្លៃសីលធម៌របស់ក្រុមហ៊ុន ទោះបីជាមិនមានចែងច្បាស់ក្នុងគោលនយោបាយ និងនីតិវិធីក៏ដោយ ។
- ប៉ុន្តែការពឹងផ្អែកលើទំនុកចិត្តពេក អាចនាំឱ្យក្រុមហ៊ុនជួបហានិភ័យ ដែលមានផលអវិជ្ជមានធ្ងន់ធ្ងរ (ដូចជាការពិន័យផ្លូវច្បាប់ធ្ងន់ធ្ងរ) ដោយសារការប្រព្រឹត្តអំពើពុករលួយរបស់បុគ្គលិកមិនល្អម្នាក់ ឬដោយការធ្វេសប្រហែស ឬដោយការមិនដឹង ឬដោយកំហុសមនុស្សទូទៅ ។
- ដូច្នេះបន្ថែមលើការផ្តោតលើការអនុលោមតាមក្រមសីលធម៌ ក្រុមហ៊ុនគប្បីមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ។ គោលបំណងចម្បងនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺផ្តល់ការធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃ៖
    - ប្រតិបត្តិការក្រុមហ៊ុន
    - ភាពទុកចិត្តនៃរបាយការណ៍ហិរញ្ញវត្ថុ
    - ការអនុលោមតាមច្បាប់ បទបញ្ញត្តិ និងគោលនយោបាយផ្ទៃក្នុងជាធរមាន
    - កម្មវិធីប្រឆាំងអំពើពុករលួយ (ស្របតាមបំណងថ្នាក់គ្រប់គ្រងជាន់ខ្ពស់)
    - ការកាត់បន្ថយហានិភ័យអំពើពុករលួយ ។

### + ធាតុផ្សំនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយ

- តុល្យភាពរវាងទំនុកចិត្តលើបុគ្គលិក និងដៃគូជំនួញ គឺមានសារៈសំខាន់សម្រាប់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងផ្នែកត្រួតពិនិត្យរបស់ក្រុមហ៊ុន ។
- ប្រព័ន្ធតុល្យភាពត្រូវផ្អែកលើហានិភ័យ និងគួរជៀសវាងការត្រួតពិនិត្យជ្រុល ឬមិនគ្រប់គ្រាន់ ព្រោះការត្រួតពិនិត្យជ្រុលនាំឱ្យមិនទុកចិត្តគ្នា និងពន្យឺតការងារ រីឯការត្រួតពិនិត្យមិនគ្រប់គ្រាន់នឹងនាំឱ្យងាយមានអំពើពុករលួយ ។
- ជារួម គោលបំណងនៃការត្រួតពិនិត្យផ្ទៃក្នុង គឺទប់ស្កាត់ និងរកឱ្យឃើញភ្លាមនូវអំពើពុករលួយ បើមាន ។ ធាតុផ្សំនៃការងារនេះមាន៖

- វិធានការអង្គភាព៖
    - អាចធ្វើសមាហរណកម្មចូលក្នុងដំណើរការធុរកិច្ច ដើម្បីទប់ស្កាត់អំពើពុករលួយតាមរយៈគោលនយោបាយ និងនីតិវិធីអនុវត្តប្រចាំថ្ងៃ
    - រួមមាន ការពណ៌នាអំពីតួនាទីច្បាស់ៗ - ការកំណត់ព្រំដែនការអនុម័ត - ការបំបែកការទទួលខុសត្រូវ (ឧទា. អ្នកចេញវិក្កយបត្រ ត្រូវតែមានតួនាទីផ្សេងគ្នាពីអ្នកទូទាត់សាច់ប្រាក់) និងការដាក់កំហិតដល់ការចូលរួមក្នុងសកម្មភាពធុរកិច្ចរសើបៗ (ឧទា. ការអនុម័តរើសអ្នកផ្គត់ផ្គង់ថ្មី) ។
- ការត្រួតពិនិត្យ៖
    - អាចធ្វើដោយឡែកសម្រាប់ដៃគូ ទាំងលើការបណ្តុះបណ្តាល លើគោលនយោបាយ និងលើនីតិវិធីធុរកិច្ច ឬដោយសមាហរណកម្មចូលក្នុងដំណើរការដំនួញដែលមាន
    - អនុវត្តលើការគាំទ្រ និងការអនុលោមតាមវិធានការអង្គភាព ឧទា. ការគោរពតាមលក្ខខណ្ឌ ត្រូវបំពេញមុនពេលអាចផ្តល់ហិរញ្ញប្បទាន ដល់គណបក្សនយោបាយ (ទប់ស្កាត់) ឬការត្រួតពិនិត្យលើការបង់ប្រាក់ឧបឬដដែលៗ ដោយបំបែកតូចៗ ទៅឱ្យអ្នកផ្គត់ផ្គង់ ដើម្បីរកឱ្យឃើញការបង់ប្រាក់លើស ឬការគេចពីព្រំដែននៃការអនុម័ត (រកឱ្យឃើញ) ។

**ចំណាំ៖** ការត្រួតពិនិត្យអាចធ្វើដោយដៃ (ពប់សារពើភណ្ឌ) ឬដោយស្វ័យប្រវត្តិ (IT) ។

- ព័ត៌មានពីការអនុវត្តដែលត្រូវបានត្រួតពិនិត្យ ត្រូវកត់ត្រាឱ្យបានគ្រប់គ្រាន់ (សម្រាប់រៀន និងកែលម្អទៅថ្ងៃអនាគត) ។

## + ការទទួលខុសត្រូវសម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

- ការតាក់តែង ការអនុវត្ត និងការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង៖
    - ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ទទួលអនុវត្ត ប៉ុន្តែអាចធ្វើប្រតិភូកម្មដល់ផ្នែកណាមួយដូចជាផ្នែកគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ឬលទ្ធកម្ម ជាពិសេសទាក់ទងនឹងដំណើរការ
    - ក្រុមហ៊ុនគួរចាត់ឱ្យមានម្ចាស់ត្រួតពិនិត្យផ្ទៃក្នុងតាមជំនាញ ឧទា. ផ្នែកអនុលោមតាមច្បាប់ អាចទទួលការអនុវត្ត ខណៈដែលផ្នែកហិរញ្ញវត្ថុអាចទទួលការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ និងការរៀបចំនូវគណនេយ្យ និងកំណត់ត្រា ។

- វាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង៖
    - ផ្នែកសវនកម្មផ្ទៃក្នុង (និង/ឬសវនកម្មផ្ទៃក្រៅ) វាយតម្លៃពីការងារត្រួតពិនិត្យផ្ទៃក្នុងជាប្រចាំ ។ ផ្នែកនេះគឺជាផ្នែកឯករាជ្យក្នុងក្រុមហ៊ុន ដែលគោលបំណងចម្បង គឺត្រួតពិនិត្យប្រសិទ្ធភាព ប្រសិទ្ធផល និងតុល្យភាពនៃវិធានការ និងការត្រួតពិនិត្យដែលមាន
    - ឯករាជ្យភាពនៃផ្នែកនេះ គឺសំខាន់ណាស់ ព្រោះអាចជួយដល់ការវាយតម្លៃជាសត្យានុម័ត និងសមហេតុផល ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
    - របាយការណ៍ផ្នែកនេះ គួររាយការណ៍ទៅក្រុមប្រឹក្សានាយក (ឬទៅគណៈកម្មការសវនកម្ម) ។
- ការត្រួតពិនិត្យពីលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង៖
    - ក្រុមប្រឹក្សានាយក ឬអង្គគ្រប់គ្រងប្រហែលនេះ ជាអ្នកជានាប្រសិទ្ធភាពនៃប្រព័ន្ធនេះ ។

## + សៀវភៅ និងកំណត់ត្រាត្រឹមត្រូវ

- សៀវភៅ និងកំណត់ត្រា គឺជាមូលដ្ឋានសម្រាប់ការអនុវត្តការត្រួតពិនិត្យ ហើយជាការតម្រូវសម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយ ។ សៀវភៅ និងកំណត់ត្រា ក៏សម្រាប់ផ្តល់ជាភស្តុតាង ក្នុងករណីមានភាពមិនប្រក្រតី ។
- ដើម្បីរក្សាសៀវភៅ និងកំណត់ត្រាឱ្យបានត្រឹមត្រូវ ក្រុមហ៊ុនគួរមានគោលនយោបាយ និងនីតិវិធីគាំទ្រច្បាស់លាស់ ដូចជា៖
    - ចុះគ្រប់ប្រតិបត្តិការ ទ្រព្យ និងបំណុលឱ្យបានត្រឹមត្រូវ ឱ្យបានលម្អិតគ្រប់គ្រាន់ និងមានឯកសារដើមមកជាមួយ
    - ចុះគ្រប់ប្រតិបត្តិការក្នុងសៀវភៅផ្លូវការរបស់ក្រុមហ៊ុន ។ គណនីក្រៅសៀវភៅគួរត្រូវហាមឃាត់
    - ចុះឱ្យបានទាន់ពេល និងតាមលំដាប់លំដោយនូវប្រតិបត្តិការ ទ្រព្យ និងបំណុល
    - ត្រូវថែរក្សាឱ្យមានសុវត្ថិភាព ដើម្បីទប់ស្កាត់ការខូចខាតដោយចេតនា ឬដោយអចេតនា ការកែ ឬលាតត្រដាងដោយមិនត្រឹមត្រូវ ឬដោយគ្មានការអនុញ្ញាត
    - មិនគួរត្រូវបំផ្លាញ មុនផុតការកំណត់ដោយច្បាប់ ឬបទប្បញ្ញត្តិទេ
    - ត្រូវកត់ត្រាគ្រប់ប្រតិបត្តិការឱ្យមានសង្គតិភាព ពីការចាប់ផ្តើមរហូតដល់បញ្ចប់

- ប្រតិបត្តិការ គួរមានបំណងពិតប្រាកដ និងស្របច្បាប់
- កំណត់ត្រាអេឡិចត្រូនិច គួររក្សាក្នុងទម្រង់ដែលមិនអាចលុបបាន និងមិនអាចកែបាន ហើយត្រូវរៀបចំឱ្យបានល្អ និងអាចបោះពុម្ពបានភ្លាមៗ ។

- សៀវភៅ និងកំណត់ត្រាគួរមានសម្រាប់ការផ្ទៀងអធិការកិច្ចរបស់ក្រុមប្រឹក្សានាយក ឬផ្នែកទទួលខុសត្រូវណាមួយ ក៏ដូចជាសវនករផ្ទៃក្នុង និងផ្ទៃក្រៅ ។
- សវនករផ្ទៃក្នុង និងផ្ទៃក្រៅ គួរអាចត្រួតពិនិត្យគណនីធនាគាររបស់ក្រុមហ៊ុន និងទំនាក់ទំនងរវាងតំណាងក្រុមហ៊ុន និងតំណាងធនាគារបានដែរ (ដើម្បីវាយតម្លៃទំនាស់ផលប្រយោជន៍ដែលអាចមាន) ។

## សម្គាល់

### + បញ្ហាប្រឈម និង ឱកាសសម្រាប់ SMEs

- SMEs គួរមានគោលនយោបាយ និងនីតិវិធីសម្រាប់រក្សាសៀវភៅ និងកំណត់ត្រាដើម្បីកាត់បន្ថយហានិភ័យពុករលួយ
- បញ្ហាប្រឈមសម្រាប់ SMEs៖
  - អាចនាំឱ្យមានការយល់ថា ការត្រួតពិនិត្យផ្ទៃក្នុង គឺជាសញ្ញានៃការមិនទុកចិត្តគ្នា
  - កង្វះធនធានមនុស្ស និងហិរញ្ញវត្ថុ
  - ការទទួលខុសត្រូវមានលក្ខណៈមជ្ឈការ
  - ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងពឹងផ្អែកលើធន្ទៈ និងការគាំទ្រពីថ្នាក់ដឹកនាំកំពូលរបស់ក្រុមហ៊ុន ដោយសារមានផ្នែកគ្រប់គ្រងតែមួយកម្រិត
- គួរប្រើអភិក្រមផ្អែកលើហានិភ័យហ្មត់ចត់ ឧទា. ក្រុមហ៊ុនអាចចាត់តាំងអ្នកគ្រប់គ្រងម្នាក់ដើម្បីអនុម័ត និងត្រួតពិនិត្យប្រតិបត្តិការ និងសកម្មភាពធុរកិច្ចដែលមានហានិភ័យ (អាចផ្អែកលើតម្លៃកម្រិតច្បាស់លាស់ ឬ Threshold ដែលបានកំណត់) ឬប្រើប្រព័ន្ធត្រួតពិនិត្យស្វ័យប្រវត្តិ ដើម្បីត្រួតពិនិត្យជាប្រចាំ (ប្រព័ន្ធនេះអាចថ្លៃ តែសម្រាប់រយៈពេលយូរ គឺចំណេញទៅវិញទេ)
- ឧត្តមភាពមួយសម្រាប់ SMEs គឺងាយរកឃើញការប្រព្រឹត្តខុស ដោយសារការរៀបចំរបស់គេមិនស្មុគស្មាញ ហើយទំនាក់ទំនងផ្ទៃក្នុងមានភាពជិតស្និទ្ធ ។

+ *ការរាយការណ៍*

- ក្រុមហ៊ុនគប្បីពណ៌នាពីការត្រួតពិនិត្យផ្ទៃក្នុងជាក់លាក់ ដូចជាគោលនយោបាយ និងដំណើរការអនុម័ត ផែនការសវនកម្ម គោលការណ៍ណែនាំការចំណាយ និងវិក័យបត្រ ។ល។
- ពណ៌នាអំពីរបៀបត្រួតពិនិត្យមើលឡើងវិញ នូវការត្រួតពិនិត្យផ្ទៃក្នុងទាំងនេះ
- ពណ៌នាអំពីគោលនយោបាយ និងនីតិវិធី (ឧទា. ភាពញឹកញាប់ វិសាលភាពត្រួតពិនិត្យ កម្រិតនៃការត្រួតពិនិត្យស្វ័យប្រវត្តិ ក្របខ័ណ្ឌអន្តរជាតិដែលបានប្រើ)
- រាយការណ៍ថាតើសវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅ មានបានធ្វើឬទេ
- រាយការណ៍ពីអាណត្តិជាក់លាក់របស់សវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅ
- អាចផ្តល់ព័ត៌មាន និងបញ្ជាក់ពីសកម្មភាពជាក់ស្តែងដែលបានធ្វើ ឬលទ្ធផលដែលទទួលបាន ។

## G. 1. យោងបទដ្ឋានអន្តរជាតិ

សាជីវកម្មត្រូវរៀបចំឱ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដើម្បីប្រឆាំងការសូកប៉ាន់រួមមានៈ ការត្រួតពិនិត្យហិរញ្ញវត្ថុ និងការពិនិត្យមើលសមតុល្យរបស់ស្ថាប័ន លើការអនុវត្ត ការរក្សាកំណត់ត្រាគណនេយ្យ និងនីតិវិធីធុរកិច្ចផ្សេងៗដែលមាន ។ សាជីវកម្មត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង លើការអនុវត្តកំណត់ត្រាឯកសារ និងគណនេយ្យជាប្រចាំ និងធ្វើសវនកម្មដើម្បីផ្តល់ការធានាដល់ការអនុវត្តឱ្យមានប្រសិទ្ធភាព ។ សាជីវកម្មមិនត្រូវអនុញ្ញាតឱ្យមានការកត់ត្រាចំណាយ ឬចំណូលក្លែងក្លាយ ឬបង្កើតជាគណនីសម្ងាត់ដែលពុំមានឯកសារបញ្ជាក់ ឬប្រើប្រាស់គណនីណាមួយដើម្បីប្រព្រឹត្តអំពើពុករលួយ និងបំផ្លាញឯកសារចោលទេ ហើយត្រូវអនុលោមតាមច្បាប់ពន្ធដារ និងច្បាប់ផ្សេងៗទៀត ដោយមិនអាចកាត់កងចំណាយសូកប៉ាន់ជាមួយនឹងការបង់ពន្ធលើប្រាក់ចំណូលបានទេ ។

## G. 2. យោងបទដ្ឋានជាតិ

***ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យ សហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ២០០២*** តម្រូវឱ្យគ្រប់សហគ្រាសទាំងអស់ រៀបចំរបាយការណ៍ហិរញ្ញវត្ថុស្រប តាមបទដ្ឋានគណនេយ្យកម្ពុជា និងតាមបទដ្ឋានគណនេយ្យអន្តរជាតិ ។ រាល់ប្រតិបត្តិការគណនេយ្យត្រូវសំអាងលើឯកសារយុត្តិការ ។ របាយការណ៍ហិរញ្ញវត្ថុ ដែលទាក់ទងនឹង

កិច្ចការគណនេយ្យ ព្រមទាំងឯកសារយុត្តិការនានាដែលពាក់ព័ន្ធ ដូចជា៖ ទិនានុប្បវត្តិ សៀវភៅធំ និងសៀវភៅសារពើភណ្ឌ ត្រូវរក្សាទុកក្នុងរយៈពេល យ៉ាងតិច ១០ (ដប់) ឆ្នាំ ។ រាល់សហគ្រាសដែលមានចំនួនទឹកប្រាក់នៃផលរបរ ឬនិងចំនួននិយោជិតរបស់ខ្លួនលើសពីកម្រិត ដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដាក់បញ្ជីគណនេយ្យរបស់ខ្លួនឱ្យមានការត្រួតពិនិត្យដោយសវនករឯករាជ្យ ។ អនុលោមតាម **ច្បាប់ស្តីពីសារពើពន្ធ ១៩៩៧** សហគ្រាស និងរូបវន្តបុគ្គលត្រូវមានទោសក្នុងករណីមិនបានរក្សាបញ្ជីកាគណនេយ្យ លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសាររបាយការណ៍ ឬពត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងកិច្ចការជំនួញរបស់ខ្លួន ។

## G. 3. ករណីសិក្សា

**ករណីសិក្សា G.3.1៖ ក្រុមហ៊ុនហេដ្ឋារចនាសម្ព័ន្ធ ចម្រុះជាតិសាសន៍ M បានណែនាំអំពីការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីត្រួតពិនិត្យតាមដាន និងពិនិត្យមើលសកម្មភាព និងការបង់ប្រាក់ទៅភ្នាក់ងារ**

- ក្រុមហ៊ុនមានស្នាក់ការកណ្តាលនៅអឺរ៉ុប និងស្នាក់ការប្រតិបត្តិធំៗមួយចំនួននៅអឺរ៉ុបភាគខាងកើត និងភាគខាងលិច, មជ្ឈិមបូព៌ា, និងមានគម្រោងពង្រីកទៅតំបន់អាស៊ីប៉ាស៊ីហ្វិក, និងប៉ែកអាហ្វ្រិកទៀត ។ ក្រុមហ៊ុនបានបង្កើតផ្នែកអនុលោមតាមច្បាប់អចិន្ត្រៃយ៍ ដោយមានប្រធានផ្នែកអនុលោមតាមច្បាប់ម្នាក់ ដែលមានភារកិច្ចរាយការណ៍ជូនផ្ទាល់ និងប្រយោលទៅអ្នកគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សានាយក ។
- ក្រុមហ៊ុនយល់ច្បាស់ថា ខ្លួននឹងត្រូវទទួលខុសត្រូវក្រោមច្បាប់របស់ប្រទេសដើមខ្លួនក្នុងការប្រឆាំងការសូកប៉ាន់ និងអំពើពុករលួយសម្រាប់រាល់ចំណាយពុករលួយដែលបានផ្តល់ជូន ដូចជា ការសន្យា ការសូកប៉ាន់ដល់មន្ត្រីសាធារណៈ ក្នុងនាមក្រុមហ៊ុនដោយភ្នាក់ងារទី៣ ដែលខ្លួនមានទំនាក់ទំនងធុរកិច្ចជាមួយ ។ ក្រុមហ៊ុនបានបង្កើតនីតិវិធីក្នុងការយកចិត្តទុកដាក់ស្គាល់អតិថិជន សម្រាប់ពិនិត្យមើលភ្នាក់ងារទាំងអស់មុនពេលធ្វើការសហការជាមួយគ្នា ។
- សម្រាប់តំបន់ដែលមានហានិភ័យខ្ពស់ ក្រុមហ៊ុនបានដាក់ឱ្យមាននីតិវិធីផ្ទៃក្នុង និងការត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីធានាថាសកម្មភាពរបស់ភ្នាក់ងារត្រូវបានពិនិត្យមើល និងមានការពិនិត្យតាមដាន ។ នីតិវិធី និងការត្រួតពិនិត្យភ្នាក់ងារ រួមមាន (១)ការ

តម្រូវឱ្យផ្ដល់របាយការណ៍សកម្មភាពប្រចាំខែ (២)ការប្ដេជ្ញាដោយមានចុះហត្ថលេខា ១ ឆ្នាំម្ដង ឬ ២ ដង ថានឹងមិនមានការចំណាយប្រាក់មិនត្រឹមត្រូវ ក្នុងនាមក្រុមហ៊ុន (៣)ការធ្វើសវនកម្មជាប្រចាំលើឯកសារ និងកំណត់ត្រា (៤)ការត្រួតពិនិត្យ និងគ្រប់គ្រងចំណាយទៅឱ្យភ្នាក់ងារ ដោយមានការចុះហត្ថលេខា ៣ ទៅ ៤ កម្រិត និងដោយមានការកំណត់កម្រិតទឹកប្រាក់ (Threshold) នៃការចំណាយច្បាស់លាស់ ។

**ករណីសិក្សា G.3.2៖ *ក្រុមហ៊ុនសណ្ឋាគារលំដាប់ប្រណីត N ជំរុញការប្រឆាំងអំពើពុករលួយតាមរយៈ ការត្រួតពិនិត្យហិរញ្ញវត្ថុផ្ទៃក្នុង និងការរក្សាកំណត់ត្រា សម្រាប់ចំណាយបុរេប្រទានវេជ្ជទេយ្យ***

- ក្រុមហ៊ុនផ្ដល់សេវាកម្មសណ្ឋាគារដ៏ប្រណីតនៅអឺរ៉ុប ដែលគ្មានគូប្រៀប បានទិញសិទ្ធិកាន់កាប់លើសណ្ឋាគារជាច្រើននៅអឺរ៉ុប ។
- ក្រុមហ៊ុនក៏បានទិញសណ្ឋាគារមួយចំនួនទៀតជុំវិញពិភពលោក ហើយជាផ្នែកមួយនៃដំណើរការទិញសណ្ឋាគារទាំងនេះ ក្រុមហ៊ុន N បានធ្វើការវាយតម្លៃហានិភ័យយ៉ាងល្អិតល្អន់ ។ ភាគច្រើននៃសណ្ឋាគារទាំងនោះ គឺពុំមានការអនុលោមតាមគោលការណ៍របស់ក្រុមហ៊ុន N ក្នុងការប្រឆាំងអំពើពុករលួយទេ ព្រោះលទ្ធផលនៃការវាយតម្លៃបង្ហាញថា សណ្ឋាគារទាំងនោះចាំបាច់ត្រូវកែលម្អក្នុងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ទូទាត់ចំណាយវេជ្ជទេយ្យ ។ ក្រុមហ៊ុន N ក៏បានរៀបចំឱ្យមាននីតិវិធីផ្ទៃក្នុងគ្រប់គ្រងការចំណាយវេជ្ជទេយ្យ នៅពាល់សណ្ឋាគារដែលខ្លួនបានទិញទាំងនោះ ។
- ក្រុមហ៊ុនបានរៀបចំឱ្យមានការគ្រប់គ្រងចំណាយវេជ្ជទេយ្យដោយប្រព័ន្ធបច្ចេកវិទ្យាជំនួសឱ្យប្រព័ន្ធក្រដាសស្នាម ដែលពិបាកក្នុងការគ្រប់គ្រង ក្នុងប្រតិបត្តិការធុរកិច្ចជាសាកល ដើម្បីទប់ស្កាត់ និងតាមដានចំណាយទាក់ទងនឹងការសូកប៉ាន់ ឬអំពើពុករលួយនានា ។

## H. ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាល

- ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាលជាប្រចាំ ដើរតួសំខាន់ក្នុងការបង្កើនការយល់ដឹង និងទទួលបាននូវការប្តេជ្ញា ចំពោះកម្មវិធីប្រឆាំងអំពើពុករលួយ ។
- ក្រុមហ៊ុនត្រូវធានាថា៖
    - បុគ្គលិក និងដៃគូធុរកិច្ចពាក់ព័ន្ធរបស់ខ្លួនយល់ដឹងពីគោលនយោបាយ និងនីតិវិធីប្រឆាំងអំពើពុករលួយ
    - ព័ត៌មាន និងជំនាញចាំបាច់ក្នុងការកំណត់អត្តសញ្ញាណ និងការប្រឆាំងនឹងបញ្ហាប្រឈមនានាទាក់ទងនឹងអំពើពុករលួយ មានគ្រប់គ្រាន់ ។

<u>+ ចំណុចសំខាន់ៗត្រូវពិចារណាសម្រាប់ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាល</u>

- ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាលត្រូវធ្វើសម្រាប់៖
    - ដៃគូធុរកិច្ច និងបុគ្គលិក ដែលក្រុមហ៊ុនមានឥទ្ធិពល និងអាចត្រួតត្រាបាន
    - អ្នកផ្គត់ផ្គង់ និងជាពិសេសដៃគូដែលមានហានិភ័យខ្ពស់ ដូចជាផ្នែកលទ្ធកម្ម និងភស្តុភារ ឬឧស្សាហកម្ម ដែលមានហានិភ័យខ្ពស់ ។
- គួរធ្វើជាប្រចាំ ហើយផ្អែកតាមការវាយតម្លៃហានិភ័យលើបុគ្គល ។ ក្រុមហ៊ុនគួរសម្រេចថា ផ្តោតលើបុគ្គលិកទាំងអស់ ឬខ្លះ ។ បុគ្គលិកផ្ទៃក្នុងអាចទទួលការប្រាស្រ័យទាក់ទង និងចូលរួមការបណ្តុះបណ្តាលតាមបទដ្ឋានចាំបាច់ យ៉ាងតិចម្តងមួយឆ្នាំ ហើយអ្នកគ្រប់គ្រងថ្នាក់កណ្តាល ដែលនៅជាប់បុគ្គលិកជាប្រចាំ ដើរតួសំខាន់ក្នុងការផ្តល់សារគន្លឹះ ពីការបណ្តុះបណ្តាល និងការប្រាស្រ័យទាក់ទង ។
- ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាលក៏គួរគ្របដណ្តប់ទៅលើការជ្រើសរើសបុគ្គលិកផ្ទៃក្នុង និងផ្ទៃក្រៅ ។ ការយល់ដឹងពីកម្មវិធីប្រឆាំងអំពើពុករលួយរបស់ក្រុមហ៊ុនគួរជាលក្ខណៈវិនិច្ឆ័យមួយក្នុងការជ្រើសរើសបុគ្គលិក ឬការផ្តួចផ្តើមនូវទំនាក់ទំនងអាជីវកម្ម ។
- ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាលក៏អាចភ្ជាប់ជាមួយឱកាសពិសេស ឬព្រឹត្តិការណ៍ធំៗ ដូចជា៖
    - ធ្វើបច្ចុប្បន្នភាពលើគោលនយោបាយផ្ទៃក្នុង ឬបទបញ្ញត្តិច្បាប់ផ្ទៃក្រៅ
    - ការផ្លាស់ប្តូររចនាសម្ព័ន្ធ (ឧទា. ប្រធានប្រតិបត្តិថ្មី)

- គោលការណ៍ណែនាំផ្ទៃក្នុងថ្មី ឬឧបករណ៍គាំទ្រ
- កិច្ចប្រជុំប្រចាំឆ្នាំរបស់ម្ចាស់ភាគហ៊ុន
- ព្រឹត្តិការណ៍តាមរដូវកាល ឧទា. ព្រឹត្តិបត្រពិសេស ឬបណ្តុះបណ្តាលពីអំណោយក្នុងរដូវណាមួយ
- ទិវាប្រឆាំងអំពើពុករលួយជាតិ ឬអន្តរជាតិ ដូចជា ទិវាប្រឆាំងអំពើពុករលួយ 9 ធ្នូ ជាដើម ។

- ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាល គួរត្រូវទុកជាឯកសារដើម្បីអាចវាយតម្លៃប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តរភាពបាន ។ កំណត់ត្រាវត្តមានបុគ្គលិកចូលរួមបណ្តុះបណ្តាល ក៏គួរត្រូវរក្សាទុកផងដែរ ព្រោះអាចការពារក្រុមហ៊ុនបានថ្ងៃណាមួយ ។

## + ប្រភេទនៃការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាល

- កម្មវិធីប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាល គួររួមមានការនិយាយអំពីៈ
  - គោលនយោបាយ និងនីតិវិធីប្រឆាំងអំពើពុករលួយ
  - វិចារណកម្ម គោលបំណង និងដំណើរការ
  - សារពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងអង្គភាពត្រួតពិនិត្យពីលើ
  - ឧទាហរណ៍ជាក់ស្តែងពីទង្វើល្អស្របនឹងនិយាម និងតម្លៃរបស់ក្រុមហ៊ុន
  - ព័ត៌មានពីច្បាប់ អ្នកផ្តត់ផ្គង់ ។ល។
- របៀបបណ្តុះបណ្តាល អាចរួមមានៈ
  - ការសំដែងតួ (ការប្រតិកម្មទៅនឹងសំណើទារប្រាក់ពីនរណាម្នាក់)
  - ការរៀបចំឱ្យមានទំនាក់ទំនងរវាងបុគ្គលិក និងថ្នាក់គ្រប់គ្រង ឬបុគ្គលិក និងបុគ្គលិក
  - កម្មវិធីអាចរៀបចំសម្រាប់ស្វ័យសិក្សា ដូចជាតាមវិបសាយ អ៊ីមេល ព្រឹត្តិប័ត្រ
  - ពិភាក្សាពីបទពិសោធន៍ និងស្ថានភាពប្រជែង - វគ្គបន្ថែម - សិក្ខាសាលា ។ល។

## សម្គាល់

## + បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs

- ការទំនាក់ទំនង និងការបណ្តុះបណ្តាល មានសារៈសំខាន់ណាស់សម្រាប់ SMEs ហើយការធ្វើឡើងដោយថ្នាក់គ្រប់គ្រង គឺសំខាន់សម្រាប់ការប្តេជ្ញាចិត្តប្រឆាំងអំពើពុក

រលួយ ។ ការងារនេះ គួរធ្វើដោយមានលក្ខណៈផ្ទាល់ ដើម្បីបង្កើនការយល់ដឹង និងការទទួលបាននូវចំណេះ ទាក់ទងនឹងគោលនយោបាយ និងនីតិវិធី ។

- បើជួបបញ្ហាធនធាន SMEs អាចៈ
  - ចូលរួមបណ្តុះបណ្តាលជាខ្សែសង្វាក់ជាមួយក្រុមហ៊ុនធំ
  - ប្រើឯកសារទំនាក់ទំនង និងបណ្តុះបណ្តាលដែលមាន បោះពុម្ព - តាមវិបសាយ ។ល។
  - ប្រើអតិក្រមបណ្តុះបណ្តាលគ្រូបង្គោលដើម្បីបង្រៀនបន្ត
  - បង្កើតក្រុមមានចំណាប់អារម្មណ៍ដូចគ្នា (តាមរយៈកិច្ចសហការជាមួយសមាគម ឬសភាពាណិជ្ជកម្មក្នុងស្រុក) ។

### + ការរាយការណ៍

- ក្រុមហ៊ុនគប្បីពណ៌នាពីការប្រាស្រ័យទាក់ទងផ្ទៃក្នុងដែលមាន ដូចជាយុទ្ធនាការប្រឆាំងអំពើពុករលួយ ការទំនាក់ទំនងនៃការគ្រប់គ្រង កិច្ចប្រជុំតាមផ្នែក ឯកសារបោះពុម្ព គោលការណ៍ណែនាំការធ្វើជំនួញ ធនធានអ៊ិនធឺណែត
- ផ្តល់វិធានការត្រួតពិនិត្យ ដូចជា លទ្ធផលស្ទាបស្ទង់ឥរិយាបថបុគ្គលិក ឯកសារបោះពុម្ពជាភាសាខ្មែរ
- ពណ៌នាអំពីភាពញឹកញាប់នៃការប្រាស្រ័យទាក់ទង (ឧទា.តាមត្រីមាស - ប្រចាំឆ្នាំ)
- ពណ៌នាអំពីកិច្ចផ្តួចផ្តើមការបណ្តុះបណ្តាលប្រឆាំងអំពើពុករលួយ
- ពន្យល់ថាតើការប្រាស្រ័យទាក់ទង និង/ឬធនធានសម្រាប់ការបណ្តុះបណ្តាល ត្រូវបានបកប្រែ
- ក្រុមហ៊ុនអាចផ្តល់ព័ត៌មាន និងបញ្ជាក់ពីសកម្មភាពជាក់ស្តែងដែលបានធ្វើ ឬលទ្ធផលដែលទទួលបាន ។

## H. 1. **យោងបទដ្ឋានអន្តរជាតិ**

- ***ការប្រាស្រ័យទាក់ទងៈ*** សហគ្រាសគួរតែបង្កើតនូវកម្មវិធីទំនាក់ទំនងផ្ទៃក្នុង និងផ្ទៃក្រៅឱ្យមានប្រសិទ្ធភាព ។ សហគ្រាសគួរតែផ្សព្វផ្សាយជាសាធារណៈនូវកម្មវិធីប្រឆាំងអំពើពុករលួយ ។ សហគ្រាសក៏គួរបើកឱ្យទូលាយក្នុងការទទួលយកនូវទំនាក់ទំនងពីដៃគូដែលពាក់ព័ន្ធទៅនឹងកម្មវិធីនេះ ។

- ***ការបណ្តុះបណ្តាល៖*** សហគ្រាសគួរតែដាក់ចេញនូវកម្មវិធីបណ្តុះបណ្តាលលើការប្រឆាំងការស៊ីសំណូក ។ អ្នកគ្រប់គ្រង និយោជិត និងភ្នាក់ងារផ្សេងៗ គួរតែទទួលបាននូវការបណ្តុះបណ្តាលនូវកម្មវិធីនេះ ដើម្បីសម្របខ្លួនទៅនឹងស្ថានភាពដែលអាចនឹងកើតមានឡើង ។ អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ និងអ្នកពាក់ព័ន្ធសំខាន់ៗឯទៀតគួរតែទទួលបាននូវការបណ្តុះបណ្តាលលើកម្មវិធីនេះ ។ ការបណ្តុះបណ្តាលគួរតែត្រូវធ្វើការវាយតម្លៃជាប្រចាំដើម្បីរក្សាប្រសិទ្ធភាព ។

## H. 2. ករណីសិក្សា

***ក្រុមហ៊ុនចម្រុះជាតិសាសន៍លក់គ្រឿងអេឡិចត្រូនិក O អនុវត្តការបណ្តុះបណ្តាលផ្នែកទំនាក់ទំនង***

- *ក្រុមហ៊ុន O ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៦៩ ហើយបានក្លាយខ្លួនទៅជាក្រុមហ៊ុននាំមុខគេផ្នែកអេឡិចត្រូនិចដែលមានសាខាលើពិភពលោកចំនួន ៣០ ប្រទេស មានបុគ្គលិកប្រហែលជា ២០ ម៉ឺននាក់ ហើយ ៦០% នៃបុគ្គលិកទាំងនេះធ្វើការនៅក្រៅប្រទេសដែលស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន O ស្ថិតនៅ ។*
- *ក្រុមហ៊ុនបានរៀបចំវគ្គបណ្តុះបណ្តាលលម្អិត ដោយមានគោលបំណងពង្រឹងការអនុវត្តច្បាប់ និងក្រមសីលធម៌គ្រប់ទីកន្លែងដែលក្រុមហ៊ុនបានដាក់ទីតាំង ។ អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ មានដូចជាអ្នកគ្រប់គ្រងជាន់ខ្ពស់នៅតាមសាខានៃប្រទេសនីមួយៗ អ្នកត្រួតពិនិត្យ និងនិយោជិតផ្សេងៗទៀត ។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ក្រុមហ៊ុនបានគិតអំពី (១)ការអនុលោមតាមបទបញ្ញត្តិប្រឆាំងអំពើពុករលួយពាក់ព័ន្ធនឹងនិយោជិតដែលមកពីប្រទេសផ្សេងៗគ្នា (២)ការប្រាស្រ័យទាក់ទងឱ្យមានប្រសិទ្ធភាពអំពីផលវិបាកនៃការប្រព្រឹត្តអំពើពុករលួយ (៣)ការជំរុញឱ្យមានទំនាក់ទំនងប្រកបដោយលក្ខណៈអន្តរសកម្ម ជាមួយដៃគូពាក់ព័ន្ធនានា ។ វគ្គបណ្តុះបណ្តាលដែលត្រូវបានបង្រៀនដោយប្រធានផ្នែកអនុលោមតាមច្បាប់ និងថ្នាក់ដឹកនាំក្រុមហ៊ុនផ្តោតទៅលើប្រធានបទមួយចំនួន ដូចជា៖*
    - *ការប្តេជ្ញារបស់ក្រុមហ៊ុនក្នុងការអនុវត្តច្បាប់ និងក្រមសីលធម៌ចាប់ផ្តើមពីថ្នាក់លើ*
    - *មធ្យោបាយក្នុងការឱ្យនិយោជិតផ្សព្វផ្សាយនូវវប្បធម៌នៃក្រមសីលធម៌*

- ច្បាប់ប្រឆាំងអំពើពុករលួយពាក់ព័ន្ធ
- គោលនយោបាយរបស់ក្រុមហ៊ុន ក្នុងការប្រឆាំងនឹងពាណិជ្ជកម្មខុសច្បាប់ និងអំពើពុករលួយគ្រប់រូបភាព
- គោលការណ៍ណែនាំរបស់ក្រុមហ៊ុនទៅលើការផ្តល់ និងទទួលអំណោយ និងការកំសាន្តទាក់ទងនឹងមន្ត្រីសាធារណៈ
- សារៈប្រយោជន៍នៃការរក្សាកំណត់ត្រាឱ្យបានត្រឹមត្រូវ និង
- សារៈសំខាន់នៃការរក្សាទុក និងការការពារព័ត៌មាន ដែលមិនមាននៅក្នុងទីសាធារណៈ ។

- វគ្គបណ្តុះបណ្តាល ក៏ត្រូវរៀបចំជាឯកសារសម្រាប់ធ្វើបទបង្ហាញ ការពិភាក្សាលើបញ្ហាជាក់ស្តែងនៃបញ្ហាប្រឈមរបស់និយោជិត ហើយនិងការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់បង្រៀនបន្តទៅដល់ផ្នែកផ្សេងៗទៀតដែលមិនបានចូលរួមផងដែរ ។

# I. ការលើកទឹកចិត្តចំពោះការប្រព្រឹត្តដោយសីលធម៌ និងការអនុលោមតាមច្បាប់

គម្រោងលើកទឹកចិត្ត គឺជាជម្រើសមួយ ដែលអាចប្រើដើម្បីគាំទ្រការទទួលបាននូវកម្មវិធីប្រឆាំងអំពើពុករលួយទូទៅ រក្សាបាននូវគោលបំណងធំៗ ក្នុងការកាត់បន្ថយអំពើពុករលួយ ។ ការលើកទឹកចិត្ត ចាំបាច់ត្រូវគិតដល់កត្តាដូចខាងក្រោម៖

## + វិចារណកម្មសម្រាប់ការលើកទឹកចិត្ត

- ការលើកទឹកចិត្តនឹងជួយបង្កើនអាកប្បកិរិយាដែលក្រុមហ៊ុនចង់បាន បង្កើនការបំពេញការងារ និងផ្តល់ជាសញ្ញាអំពីអ្វីដែលក្រុមហ៊ុនចាត់ទុកថាសំខាន់
- ការលើកទឹកចិត្តអាចផ្តល់ដល់បុគ្គលិក និងដៃគូធុរកិច្ចដែលក្រុមហ៊ុនមិនមានឥទ្ធិពលលើពេញលេញ ដើម្បីជាការជំរុញឱ្យយកចិត្តទុកដាក់ដល់ការអនុលោមតាមច្បាប់ (ឧទា. ក្រុមហ៊ុនអាចផ្តល់ឋានៈ ឬបុព្វសិទ្ធិពិសេសណាមួយ ដល់អ្នកផ្គត់ផ្គង់) ។

## + ប្រភេទនៃការលើកទឹកចិត្ត

- រង្វាន់ជាហិរញ្ញវត្ថុ៖ ការតម្លើងប្រាក់ខែ - ការតម្លើងតួនាទី - ការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម - ការផ្តល់អំណោយ ឬការផ្តល់លក្ខខណ្ឌធុរកិច្ចពិសេស
- រង្វាន់មិនមែនជាហិរញ្ញវត្ថុ៖ ការទទួលស្គាល់ណាមួយ - អបអរក្នុងព្រឹត្តិបត្រ ។ល។

## + វាយតម្លៃសីលធម៌ និងការអនុលោមតាមច្បាប់

- គោលនយោបាយធនធានមនុស្ស ជាទូទៅភ្ជាប់រង្វាន់ទៅនឹងគោលដៅផលិតភាព ដូចជាគោលដៅហិរញ្ញវត្ថុ អត្រាកាត់បន្ថយកំហុស ឬចំនួនអតិថិជនថ្មី ។
- ការលើកទឹកចិត្តត្រង់នេះ គួរបញ្ចូលទៅក្នុងគោលនយោបាយធនធានមនុស្ស និងដំណើរការវាយតម្លៃការបំពេញការងារ ដូច្នេះក្រុមហ៊ុនគួរបង្កើតឱ្យមានគោលដៅសម្រាប់ការបំពេញការងារដោយសីលធម៌ និងអនុលោមតាមច្បាប់ ។ លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ និងកម្រិតប្រភេទផ្សេងៗ នៃការលើកទឹកចិត្ត ត្រូវកត់ត្រាដោយតម្លាភាព និងដោយច្បាស់ៗក្នុងគោលនយោបាយធនធានមនុស្ស ។
- គម្រោងលើកទឹកចិត្តគួរអនុវត្តសម្រាប់ការវាយតម្លៃ និងការវាស់វែងការបំពេញការងារក្នុងទម្រង់ផ្សេងៗ ដូចជា៖

- ការចូលរួម និងការបំពេញការងារក្នុងការបណ្តុះបណ្តាលពីការអនុលោមតាមច្បាប់
- កម្រិតនៃការគាំទ្រ និងការអភិវឌ្ឍកម្មវិធីប្រឆាំងអំពើពុករលួយ ដោយសកម្ម
- ការអនុម័តទាក់ទងនឹងការអនុលោមតាមច្បាប់
- ចំណេះដឹងពីតម្លៃ និងនិយាមរបស់ក្រុមហ៊ុន (ឧទា. ក្រមប្រតិបត្តិ)
- ឆន្ទៈក្នុងការសួរ ឬបដិសេធអំពើ ឬសំណើមិនល្អ ។

- គួរជៀសវាងការវាយតម្លៃពីតម្លៃ ចំណាប់អារម្មណ៍ ឬទស្សនៈផ្ទាល់ខ្លួន ព្រោះវាទាក់ទងនឹងចរិតលក្ខណៈ និងផ្នត់គំនិតបុគ្គល (អាចនាំឱ្យលម្អៀង និងមានភាពអត្តនោម័ត)
- ការលើកទឹកចិត្តអាចផ្តល់ដល់៖
  - អ្នកគ្រប់គ្រងដែលមានថ្នាក់ក្រោមរបស់ខ្លួន បានចូលរួមបណ្តុះបណ្តាលប្រឆាំងអំពើពុករលួយបានច្រើន
  - ជាក្រុម ឬផ្នែក ដើម្បីឱ្យអ្នកក្នុងក្រុម ឬផ្នែកជួយជ្រោមជ្រែងគ្នា ។
- ការលើកទឹកចិត្តអាចត្រូវកែសម្រួល បើមិនមានតុល្យភាពរវាងផលិតភាព និងការគោរពសីលធម៌ ឧទា. ការយកចិត្តទុកដាក់ស្គាល់អតិថិជន គឺសំខាន់ ក៏ប៉ុន្តែត្រូវគិតដល់ល្បឿន និងបរិមាណការងារផងដែរ ។

+ <u>បញ្ហាប្រឈមនៅពេលផ្តល់ការលើកទឹកចិត្ត</u>

- ការលើកទឹកចិត្ត ពេលខ្លះនាំឱ្យមានបញ្ហាចម្រូងចម្រាស់ ឬខាតផលិតភាពទៅវិញ ដូច្នេះក្រុមហ៊ុនចាំបាច់ ត្រូវពិចារណា និងដោះស្រាយបញ្ហាប្រឈម ដូចខាងក្រោម៖
  - ធ្វើឱ្យមានតុល្យភាពរវាងគោលដៅបំពេញការងារ និងការលើកទឹកចិត្ត៖ ឧទា. ការលើកទឹកចិត្តត្រូវមានសមាមាត្រនឹងទំហំការងារចង់បាន
  - ផ្តល់រង្វាន់ដល់អាកប្បកិរិយាដែលរំពឹងទុក៖ សម្រាប់សកម្មភាពដែលលេចធ្លោ និងសកម្មភាពស្ម័គ្រចិត្ត ដើម្បីលើកស្ទួយកម្មវិធីប្រឆាំងអំពើពុករលួយឱ្យបានខ្លាំងក្លា ក៏គួរផ្តល់រង្វាន់ដែរ
  - កាត់បន្ថយកម្លាំងចិត្តពីខាងក្នុង៖ ព្រោះពេលខ្លះនាំឱ្យមានការគិតខុសថាជាអំពើពុករលួយទៅវិញ នៅពេលមានការលើកទឹកចិត្ត ។ គម្រោងការលើកទឹកចិត្ត ក៏ចាំបាច់ត្រូវមានស្របនឹងគម្រោងទណ្ឌកម្មផងដែរ
  - អត្តនោម័តក្នុងការវាយតម្លៃការបំពេញការងារ៖ ចាំបាច់ត្រូវមានលក្ខណៈវិនិច្ឆ័យ

ដើម្បីវាយតម្លៃដោយតម្លាភាព និងដោយសត្យានុម័ត ពោលគឺជៀសវាងការយល់ខុសថា ការធ្វើអំពើមួយនឹងបានរង្វាន់ ព្រោះអាចនាំឱ្យមានការខកចិត្ត

- ឱកាសមិនស្មើគ្នា៖ ឱកាសចូលរួមក្នុងកម្មវិធីប្រឆាំងអំពើពុករលួយគួរស្មើគ្នា ដើម្បីបានឱកាសទទួលស្គាល់ស្នាដៃស្មើគ្នាដែរ ។ ដូច្នេះក្រុមហ៊ុនមិនគួរដាក់កំហិតត្រឹមតំណែងធំៗ ទើបទទួលបានឱកាសទេ ព្រោះអាចនាំឱ្យមានផលអវិជ្ជមាន
- ផ្តល់រង្វាន់ដល់អ្នកផ្តល់ព័ត៌មាន៖ លើកទឹកចិត្តឱ្យរាយការណ៍ពេលឃើញកំហុសអ្នកដទៃ ប៉ុន្តែធ្វើដូច្នេះអាចនាំឱ្យបុគ្គលិកមិនទុកចិត្ត និងឈ្នានីសគ្នាទៅវិញទៅមក ដោយរាយការណ៍កុហក ។ ដូច្នេះក្រុមហ៊ុនត្រូវប្រយ័ត្នពីទង្វើនេះ ដោយត្រូវវិភាគពីផលវិបាកដែលអាចមាន និងកំណត់ការលើកទឹកចិត្តឱ្យបានសមរម្យ ។

សម្គាល់

+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs

- SMEs ចាំបាច់ត្រូវធ្វើដូចក្រុមហ៊ុនធំដែរ ប៉ុន្តែការលើកទឹកចិត្តជាហិរញ្ញវត្ថុ អាចជាបញ្ហា ដូច្នេះការលើកទឹកចិត្តមិនមែនជាហិរញ្ញវត្ថុ គឺល្អជាង
- គួរមានតុល្យភាពរវាងការលើកទឹកចិត្តជាហិរញ្ញវត្ថុ និងមិនមែនជាហិរញ្ញវត្ថុ
- គ្រប់ក្រុមហ៊ុនត្រូវធានាថា យុទ្ធសាស្ត្រទំនាក់ទំនងរបស់ពួកគេឆ្លើយតបច្បាស់លាស់ទៅនឹងបញ្ហាប្រឈមខាងលើ នៅពេលបង្កើតគម្រោងផ្តល់ការលើកទឹកចិត្ត សម្រាប់ការគោរពសីលធម៌ និងការអនុលោមតាមច្បាប់ ។

+ ការរាយការណ៍

- ក្រុមហ៊ុនគប្បីពិពណ៌នាពីរបៀបក្រុមហ៊ុន អនុវត្តនូវគោលនយោបាយបុគ្គលិកមានប្រសិទ្ធភាព និងដំណើរការដែលគាំទ្រដល់ការប្តេជ្ញាប្រឆាំងអំពើពុករលួយ ដូចជា ការវាយតម្លៃពីការបំពេញការងារ ការផ្តល់ប្រាក់ឧបត្ថម្ភ និងដំណើរការទទួលស្គាល់ស្នាដៃការងារ ។ល។

## I.1. យោងបទដ្ឋានអន្តរជាតិ

សហគ្រាសគួរបង្ហាញការប្តេជ្ញាចិត្តក្នុងការអនុវត្តកម្មវិធី ដោយផ្ទុះបញ្ចាំងក្នុងគោលនយោបាយធនធានមនុស្ស ដូចជា ការជ្រើសរើស ការតម្លើងតួនាទី ការបណ្តុះបណ្តាល

ការវាយតម្លៃពីការបំពេញការងារ ការផ្តល់លាភការ ការទទួលស្គាល់ស្នាដៃជាដើម ។ សហគ្រាសគួរបង្ហាញឱ្យច្បាស់ផងដែរថា ការគោរពតាមកម្មវិធីគឺជាកាតព្វកិច្ច ហើយមិនមាននិយោជិតណាម្នាក់រងផលវិបាកអវិជ្ជមាន ដូចជាបន្ថយតួនាទី ដាក់ពិន័យ រើសអើង ឬទទួលការសងសឹកផ្សេងៗ ក្នុងករណីពួកគេ (ក)បដិសេធមិនប្រព្រឹត្តអំពើពុករលួយ ទោះនាំឱ្យក្រុមហ៊ុនបាត់បង់ធុរកិច្ច (ខ)រាយការណ៍ដោយសុឆន្ទៈពីការរំលោភគោលនយោបាយប្រឆាំងអំពើពុករលួយរបស់សហគ្រាស ។

## I. 2. ករណីសិក្សា

***ក្រុមហ៊ុន P ដែលផ្តល់សេវាក្នុងវិស័យគាំពារសុខភាព បានរួមបញ្ចូលគ្នានូវគោលនយោបាយអនុលោមតាមច្បាប់ និងគោលនយោបាយធនធានមនុស្ស ដើម្បីបង្កើតជារចនាសម្ព័ន្ធលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ សម្រាប់ការអនុលោមតាមច្បាប់ និងក្រមសីលធម៌***

- ក្រុមហ៊ុន P ជាក្រុមហ៊ុនផ្តល់សេវាវិស័យគាំពារសុខភាព មានដើមទុន ១ពាន់លានដុល្លារ ចុះបញ្ជីក្នុងផ្សារភាគហ៊ុន និងមានប្រតិបត្តិការជុំវិញពិភពលោក ។
- ក្រុមហ៊ុនបានដាក់ចេញនូវ "***គោលការណ៍គ្មានឱកាសត្រូវបាត់បង់***" សម្រាប់ការខិតខំប្រឹងប្រែងលើការប្រតិបត្តិតាមរបស់បុគ្គលិកខ្លួន ដោយបញ្ជ្រាបនៅគ្រប់របៀបវារៈគោលបំណង និងរចនាសម្ព័ន្ធក្រុមហ៊ុន ។ ការផ្តល់ការលើកទឹកចិត្តរបស់ក្រុមហ៊ុនដែលត្រូវបានកែលម្អ រាល់ ៣ឆ្នាំម្តង ផ្តោតលើទិដ្ឋភាព ៣ គឺ (១)បៀវត្សមូលដ្ឋាន (២)ការលើកទឹកចិត្តរយៈពេលខ្លី និង (៣)ការលើកទឹកចិត្តរយៈពេលវែង ដូចជាការផ្តល់ជាភាគហ៊ុនជាដើម ។ យន្តការដែលត្រូវបានកែសម្រួលចុងក្រោយ ផ្តោតលើការគ្រប់គ្រងការប្រតិបត្តិ និងការអនុលោមតាមច្បាប់ដោយប្រើប្រព័ន្ធគ្រប់គ្រងហានិភ័យ ។ យន្តការនេះត្រូវបានប្រើដើម្បីវាស់វែងការប្រតិបត្តិក្នុងក្រមសីលធម៌ និងកំណត់ "ការលើកទឹកចិត្តផ្សេងៗ" សម្រាប់៖
    - ***អ្នកគ្រប់គ្រងសំខាន់ៗ៖*** វាយតម្លៃរាល់ពេលបិទបញ្ជីប្រចាំឆ្នាំ
    - ***បុគ្គលិក៖*** វាយតម្លៃ ២ឆ្នាំម្តង ដោយអ្នកគ្រប់គ្រង និងបុគ្គលិកមកពីផ្នែកអនុលោមតាមច្បាប់រាល់ពេលពិនិត្យការបំពេញការងាររបស់បុគ្គលិក
    - ***ថ្នាក់ដឹកនាំជាន់ខ្ពស់ក្រុមហ៊ុន៖*** វាយតម្លៃដោយក្រុមប្រឹក្សានាយកគណៈកម្មការលាភការ និងគណៈកម្មការសវនកម្មផ្ទៃក្នុង តាមការសម្ភាសន៍ជាមួយទីប្រឹក្សា និងប្រធានផ្នែកអនុលោមតាមច្បាប់ ។

## J. ការស្វែងរកការណែនាំ - ការតាមរក និងការរាយការណ៍ពីការរំលោភបំពាន

- ក្រុមហ៊ុនមានកម្មវិធីប្រឆាំងអំពើពុករលួយមានប្រសិទ្ធភាពប៉ុណ្ណាក៏នៅតែមានការរំលោភបំពានដែរ ហើយប៉ុន្មានឆ្នាំចុងក្រោយនេះ មានការកើនឡើងនូវហានិភ័យផ្នែកច្បាប់ និងកិត្តិយសកើតចេញពីការរំលោភបំពានរបស់ដៃគូធុរកិច្ច ។ ដូច្នេះក្រុមហ៊ុនត្រូវមានវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការរកឱ្យឃើញនូវការ រំលោភបំពានខណៈដែលត្រូវរក្សាតុល្យភាពរវាងហានិភ័យ និងការត្រួតពិនិត្យ ។
- គួរចងចាំថា កម្មវិធីប្រឆាំងអំពើពុករលួយដែលមានប្រសិទ្ធភាព ត្រូវមានយន្តការតាមរក - ស៊ើបអង្កេត - ដាក់ទោសលើការប្រព្រឹត្តល្មើស ដូច្នេះការរកឃើញការរំលោភបំពានគួរគិតថាជារឿងវិជ្ជមាន ។
- ក្រុមហ៊ុន ចាំបាច់ត្រូវផ្តល់ការឆ្លើយតប ដោយវិជ្ជមាន ដល់បុគ្គលិក និងដល់ដៃគូដែលបានស្នើសុំការណែនាំ នៅពេលពួកគេជួប និងឃើញបញ្ហា ឬដែលផ្តល់ការរាយការណ៍ពីការរំលោភបំពានផ្សេងៗ ។

### + ការផ្តល់ការណែនាំតាមសំណើ

- ក្រុមហ៊ុនអាចរៀបចំឱ្យមានបុគ្គលទទួលច្បាស់លាស់ ឬផ្នែកណាមួយក្នុងក្រុមហ៊ុន ឬទូរស័ព្ទទាន់ហេតុការណ៍
- ជួយបុគ្គលិក និងដៃគូធុរកិច្ច ក្នុងការបកស្រាយដាក់ស្តែងនូវគោលនយោបាយ និងនីតិវិធី ជួយដល់ការប្រាស្រ័យទាក់ទង និងកសាងទំនុកចិត្តរវាងផ្នែកគ្រប់គ្រងការអនុលោមតាមច្បាប់ និងបុគ្គលិក/ដៃគូធុរកិច្ច ហើយនឹងជួយរកឱ្យឃើញនូវចំណុចព្រួយបារម្ភដែលត្រូវការគាំទ្រ និងការបណ្តុះបណ្តាល ។

### + ការតាមរកការរំលោភបំពាន

- ក្រុមហ៊ុនអាចប្រើប្រភពផ្ទៃក្នុង និងផ្ទៃក្រៅ ដើម្បីតាមរកការរំលោភ
- ការប្រើប្រភពផ្ទៃក្នុង នឹង៖
  - អាចជៀសវាងបាននូវផលវិបាកអវិជ្ជមាន ដូចជាការខូចកិត្តិយសពីការរាយការណ៍ជាសាធារណៈនូវអំពើពុករលួយ

- អាចឱ្យបុគ្គលិក និងដៃគូធុរកិច្ចយល់ថាធ្វើឡើងដោយការមិនទុកចិត្តគ្នា ហើយអាចនាំឱ្យមានការសង្ស័យមិនចេះចប់ និងការភ័យខ្លាច
- ត្រូវធ្វើដោយតម្លាភាពបំផុតនៅពេលមានការស៊ើបអង្កេត ពោលគឺត្រូវមានដំណើរការ/ជំហានស៊ើបអង្កេតច្បាស់លាស់ មានអ្នកទទួលខុសត្រូវសម្រាប់ជំហានទីមួយៗ និងមានការកំណត់ព្រំដែនច្បាស់លាស់ នៃដំណាក់កាលទីមួយៗផងដែរ ។

- ដំណាក់កាលនៃការតាមរក អាចរួមមាន៖
  - កំណត់ឱ្យមានអាណត្តិអាចធ្វើការស៊ើបអង្កេតផ្ទៃក្នុងបាន
  - ស្រាវជ្រាវ និងរៀបចំផែនការស៊ើបអង្កេត
  - ស៊ើបអង្កេតជាក់ស្តែង (អាចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចផងដែរ បើចាំបាច់)
  - រាយការណ៍ និងវាយតម្លៃផ្លូវច្បាប់ ។
- ប្រភពផ្ទៃក្នុង និងផ្ទៃក្រៅ អាចរួមមាន៖

| ប្រភពផ្ទៃក្នុងសម្រាប់តាមរកការរំលោភបំពានដែលអាចមាន ឬការអនុវត្តមិនប្រក្រតី | ប្រភពផ្ទៃក្រៅសម្រាប់តាមរកការរំលោភបំពានដែលអាចមាន ឬការអនុវត្តមិនប្រក្រតី |
|---|---|
| • ការត្រួតពិនិត្យផ្ទៃក្នុង<br>• ការស៊ើបអង្កេតផ្ទៃក្នុង<br>• សវនកម្មផ្ទៃក្នុង<br>• ទូរស័ព្ទទាន់ហេតុការណ៍ផ្ទៃក្នុងសម្រាប់ការណែនាំ និងរាយការណ៍ | • សវនកម្មផ្ទៃក្រៅ<br>• ពាក្យបណ្តឹង និងការព្រួយបារម្ភពីភាគីផ្ទៃក្រៅផ្សេងៗទៀត<br>• របាយការណ៍សារព័ត៌មាន |

- គោលការណ៍នៃដំណើរការស៊ើបអង្កេត៖
  - គោរពនីតិរដ្ឋ និងគោលការណ៍សច្ចាធារណ៍និរទោស (Presumption of innocence)
  - ស្មោះត្រង់ - រក្សាសុចរិតភាពនៃការស៊ើបអង្កេតតាមរយៈគោលការណ៍ «ត្រូវដឹង ទើបដឹង»
  - រក្សាការសម្ងាត់សម្រាប់ទិន្នន័យឯកជន
  - ធានាថា ការតាមរកតាមរយៈប្រភពផ្ទៃក្នុង មិនរំខានដល់ការកសាងនូវបរិយាកាសផ្អែកលើការទុកចិត្តគ្នាទេ

- ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ គួរទទួលបាននូវរបាយការណ៍ជាប្រចាំពីការរកឃើញភាពមិនប្រក្រតី ឬការប្រព្រឹត្តខុស ។

## + ការរាយការណ៍ពីការរំលោភបំពាន

- អ្នករាយការណ៍ត្រូវបានទទួលស្គាល់ថាជាប្រភពដ៏សំខាន់ ព្រោះអំពើពុករលួយអាចមានភាពស្មុគស្មាញខ្លាំង ហើយអ្នករាយការណ៍ ជាទូទៅ ជាមនុស្សខាងក្នុងដែលមានព័ត៌មាន ហើយដែលប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរកមិនឃើញ ឬមិនមាន
- ព័ត៌មានពីអ្នករាយការណ៍អាចមិនមែនជាភស្តុតាង តែអាចបង្ហាញពីកំហុស និងអាចឈានដល់ការស៊ើបអង្កេត
- ក្រុមហ៊ុនអាចបង្កើតយន្តការគាំទ្រ ដើម្បីជួយសម្រួលដល់ការរាយការណ៍ពីការរំលោភបំពានដោយអាចចាត់តាំង ថ្នាក់ដឹកនាំម្នាក់ដែលអាចទុកចិត្តបាន ឬផ្នែកណាមួយទទួល និងដោយលាក់ការ និងគ្មានហានិភ័យពីការសងសឹក (ដូចជាការបាត់បង់ការងារ ឬការរើសអើងជាដើម) តាមរយៈការមានគោលនយោបាយច្បាស់ៗថាការរាយការណ៍ពីការរំលោភបំពាន គឺត្រូវតែធ្វើគ្រប់គ្នា បើសិនជាបានឃើញ ឬបានដឹង ។ យន្តការនេះត្រូវការពារអ្នករាយការណ៍ ហើយក៏ត្រូវរាយការណ៍ទៅអ្នកប្តឹងវិញដែរព្រោះបើមិនរាយការណ៍វិញទេ ពួកគេអាចឈប់ប្តឹងទៀត ឬទៅប្តឹងដល់អ្នកក្រៅ ។

## សម្គាល់

## + បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs

- SMEs គួរធ្វើការងារនេះ ដូចក្រុមហ៊ុនធំៗ តែអាចមិនមានធនធានគ្រប់គ្រាន់
- SMEs អាចរកអ្នកផ្តល់សេវាពីក្រៅ សម្រាប់ទូរស័ព្ទទាន់ហេតុការណ៍ ។

## + ការរាយការណ៍

- ក្រុមហ៊ុនគប្បីពណ៌នាពីដំណោះស្រាយនានាដែលបានអនុវត្តកន្លងមក
- ផ្តល់ស្ថិតិពីការប្រើយន្តការអ្នកផ្តល់ព័ត៌មាន ប្រឹក្សាយោបល់ ឬទូរស័ព្ទទាន់ហេតុការណ៍
- បញ្ជាក់លម្អិតពីប្រភេទនៃការស៊ើបអង្កេត តែត្រូវធានាថាមិនមានការបែកធ្លាយការសម្ងាត់ ឬប៉ះពាល់ដល់សន្តិសុខអ្នកផ្តល់ព័ត៌មាន ។

## J.1. យោជបនដ្ឋានអន្តរជាតិ

សហគ្រាសគួរលើកទឹកចិត្តឱ្យនិយោជិត និងបុគ្គលពាក់ព័ន្ធផ្សេងទៀត លើកឡើងពីការព្រួយបារម្ភ - សុំការណែនាំ - ផ្តល់យោបល់លើការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ - រាយការណ៍ពីអំពើពុករលួយ ឬស្ថានភាពសង្ស័យនានាដល់អ្នកទទួលខុសត្រូវ ឱ្យបានឆាប់ ដោយផ្តល់នូវមធ្យោបាយរាយការណ៍ ដែលធានានូវសុវត្ថិភាព រក្សាការសម្ងាត់ និងគ្មានហានិភ័យ ។ សហគ្រាសគួរឆ្លើយតប និងមានចំណាត់ការចំពោះការលើកឡើង ជាពិសេសបង្ហាញឱ្យឃើញច្បាស់ថា នឹងមានការដាក់ទណ្ឌកម្មយ៉ាងសាកសមចំពោះការរំលោភបំពានកម្មវិធីប្រឆាំងអំពើពុករលួយ ។

## J. 2. ករណីសិក្សា

### ក្រុមហ៊ុន Q បង្កើតប្រព័ន្ធទូរស័ព្ទរាយការណ៍ទាន់ហេតុការណ៍

- ក្រុមហ៊ុនបានបង្កើតប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍សាកលមិនគិតថ្លៃ (២៤/៧) និងផ្តល់នូវការធានារក្សាការសម្ងាត់ ចំពោះការរាយការណ៍ពីអំពើពុករលួយ ពីបុគ្គលិក និងភាគីពាក់ព័ន្ធ ។ ប្រព័ន្ធត្រូវបានរៀបចំឡើងដោយ (១)ជ្រើសរើសអ្នកទទួលការងារ (២)អាចឱ្យមានការទូរស័ព្ទចូលពីគ្រប់ប្រទេសដែលក្រុមហ៊ុនមានសាខា (៣)សិក្សាពីច្បាប់ក្នុងប្រទេសនីមួយៗ និងការការពារការលួចព័ត៌មាន (៤)ផ្សព្វផ្សាយពីប្រព័ន្ធនេះ ។
- ក្រុមហ៊ុនក៏រៀបចំឱ្យមានការស៊ើបអង្កេត ធ្វើដោយអ្នកស៊ើបអង្កេតផ្ទៃក្នុង ដើម្បីធានាសង្គតិភាព សម្របសម្រួលជំនាញក្នុងការស៊ើបអង្កេត និងការប្រមូលផ្តុំស្ថិតិ ។ លទ្ធផលនៃការស៊ើបអង្កេតលើការរាយការណ៍ ត្រូវបានចែករំលែក ដើម្បីអាចជួយទប់ស្កាត់ការកើតឡើង ឬកើតឡើងវិញនូវការប្រព្រឹត្តខុសរបស់បុគ្គលពាក់ព័ន្ធ និងអាចជួយរៀបចំកម្មវិធីបណ្តុះបណ្តាល និងសកម្មភាពដោះស្រាយឱ្យចំគោលដៅទៅថ្ងៃមុខ ។
- ប្រព័ន្ធនេះបានជួយធ្វើឱ្យប្រសើរឡើងនូវដំណើរការ និងនីតិវិធីការងារកាត់បន្ថយការប្រព្រឹត្តខុសឆ្គងផ្សេងៗ ។

## K. ការឆ្លើយតបទៅនឹងការរំលោភបំពានគោលការណ៍

- នៅពេលមានការរាយការណ៍ ឬរកឃើញការរំលោភបំពាន ក្រុមហ៊ុនចាំបាច់ត្រូវដោះស្រាយ ដើម្បីបង្ហាញពីការប្ដេជ្ញាមិនអត់ឱនឱ្យអំពើពុករលួយរបស់ក្រុមហ៊ុន និងជៀសវាងការដាក់ទោសពីការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងកុំឱ្យប៉ះពាល់ដល់កិត្តិយសក្រុមហ៊ុន ។
- ការដោះស្រាយបញ្ហារំលោភបំពាន ក៏ជាឱកាសរៀនសូត្រ និងពង្រឹងកម្មវិធីប្រឆាំងអំពើពុករលួយរបស់ក្រុមហ៊ុនដែរ ហើយនៅពេលរកឃើញការរំលោភបំពាន ក្រុមហ៊ុនក៏ត្រូវសហការជាមួយអាជ្ញាធរក្នុង និង/ឬក្រៅប្រទេសពាក់ព័ន្ធដែរ ។

### + ការរៀបចំការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការរំលោភបំពាន

ក្រុមហ៊ុនចាំបាច់ត្រូវមានគោលនយោបាយវិន័យច្បាស់ៗ និងមានតម្លាភាព ដើម្បីធានានូវការដោះស្រាយបញ្ហាដោយយុត្តិធម៌ និងដោយគណនេយ្យភាព ។ គោលនយោបាយនេះគួររួមមាន៖

#### ក) កាតាឡុកនៃការដាក់ទោសទណ្ឌ

- ជាទម្រង់ផ្សេងៗនៃទោសទណ្ឌ ដែលត្រូវបានកំណត់រួចជាស្រេចនៅក្នុងគោលនយោបាយកម្មវិធីប្រឆាំងអំពើពុករលួយ ឬក្រមសីលធម៌របស់ក្រុមហ៊ុន
- អាចរួមមានការពិន័យជាប្រាក់ ការផ្ដល់ប្រាក់សំណង ការផ្ទេរទៅតំណែងផ្សេង ការបណ្ដេញចេញពីការងារ ឬការបញ្ឈប់ពីការងារជាដើម
- ទោសទណ្ឌគួរផ្ដោតលើទាំងការប្រព្រឹត្តអំពើពុករលួយ និងកង្វះខាតក្នុងការគោរពតាមគោលការណ៍របស់ក្រុមហ៊ុន (ឧទា. ការគេចវេសពីការត្រួតពិនិត្យផ្ទៃក្នុង) ។
- ទោសទណ្ឌអាចពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ឬអាចមិនពាក់ព័ន្ធ ។ កត្តាគួរពិចារណា ក្នុងការកំណត់ទោស៖
  (១) ទោសទណ្ឌគួរស្របជាមួយច្បាប់ជាធរមាន៖ ស្របតាមច្បាប់ជាធរមាន និងស្របតាមបទដ្ឋានល្អ ហើយគួរមានលក្ខណៈបន្ទាច
  (២) ទោសទណ្ឌគួរមានលក្ខណៈពាក់ព័ន្ធ និងមានសមាមាត្រទៅនឹងកំហុស៖ កុំឱ្យតូចពេក កុំឱ្យធំពេក ព្រោះអាចនាំឱ្យគ្មានអ្នករាយការណ៍ទៀត ហើយគួរមានការបែងចែកទោសទណ្ឌតាមប្រភេទនៃការរំលោភបំពាន និងគួរសុំយោបល់

ត្រឡប់ពីបុគ្គលិក និងដៃគូធុរកិច្ចមុនរៀបចំដាក់ចេញឱ្យអនុវត្ត

(៣) ទោសទណ្ឌគួរអាចអនុវត្តបានជាក់ស្តែង៖ បើអនុវត្តមិនបាន គឺនាំឱ្យប៉ះពាល់ដល់ឈ្មោះកម្មវិធីប្រឆាំងអំពើពុករលួយ និងឈ្មោះក្រុមហ៊ុន ហេតុនេះទោសទណ្ឌត្រូវអនុវត្តឱ្យបាននៅគ្រប់កម្រិត

(៤) ទោសទណ្ឌគួរពឹងផ្អែកលើការត្រួតពិនិត្យដោយប្រសិទ្ធភាព៖ ក្រុមហ៊ុនគួរធានាថា ការត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាព និងអាចទុកចិត្តបាន ទើបការដាក់ទោសមានភាពត្រឹមត្រូវ និងអាចទប់ស្កាត់ ឬបង្ការបាន

(៥) បើមានទោសទណ្ឌ ក៏គួរមានការលើកទឹកចិត្តដែរ៖ រង្វាន់ និងដំបង ។

## ខ) គោលការណ៍ណែនាំពីនីតិវិធី និងការទទួលខុសត្រូវ

គោលការណ៍នេះ ត្រូវគាំទ្រដល់ការដោះស្រាយបញ្ហាដោយយុត្តិធម៌ និងដោយតម្លាភាព និងជៀសវាងបាននូវភាពអត្តនោម័តិ និងលម្អៀង។ គោលការណ៍នេះ គួរឆ្លើយតបនឹង៖

(១) លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់កម្រិតទម្ងន់នៃការរំលោភបំពាន (ទំហំ - វិសាលភាព - ជាការប៉ុនប៉ង ឬអំពើបានសម្រេច - ចរិតលក្ខណៈនៃការប្រព្រឹត្ត - គោលបំណងនៃការប្រព្រឹត្តជាដើម)

(២) ទំនាក់ទំនងរវាងកម្រិតទម្ងន់នៃការរំលោភបំពាន និងទោសទណ្ឌ (ប្រវត្តិវិន័យរបស់អ្នករំលោភបំពាន និងគុណវិបត្តិដែលធ្លាប់មានកន្លងមក ។ល។)

(៣) ការកាត់បន្ថយទោសទណ្ឌសម្រាប់អ្នកសារភាពដោយខ្លួនឯង (ឧទា. បន្ថយទោស ឬកម្មវិធីអភ័យឯកសិទ្ធិ)

(៤) ការចាត់តាំងការទទួលខុសត្រូវលើការងារស៊ើបអង្កេត (គួរមានការតែងតាំងច្បាស់លាស់)

(៥) ដំណើរការ និងបទបញ្ញត្តិក្នុងពេលស៊ើប (ឧទា. សិទ្ធិការពារទិន្នន័យ ច្បាប់ការងារ)

(៦) ការប្រាស្រ័យទាក់ទងផ្ទៃក្នុង (ឧទា. ដោយផ្អែកធនធានមនុស្ស)

(៧) កិច្ចសហការផ្ទៃក្រៅជាមួយអាជ្ញាធរពាក់ព័ន្ធ

(៨) ការត្រួតពិនិត្យវឌ្ឍនភាព និងការទុកដាក់ឯកសារពាក់ព័ន្ធ ។

- គោលការណ៍នេះ គួរបោះពុម្ព និងផ្តល់ដល់បុគ្គលិក និងដៃគូធុរកិច្ច ដើម្បីបានយល់ជ្រួតជ្រាប ។

### គ) ឱកាសក្នុងការប្តឹងតវ៉ា

- មានសារៈសំខាន់សម្រាប់ការធានានូវយុត្តិធម៌នៃការដាក់ទោសទណ្ឌ និងនីតិវិធីវិន័យ
- គួរកំណត់ឱ្យបានច្បាស់អំពីលក្ខណៈវិនិច្ឆ័យ នីតិវិធី និងបែបបទនានាក្នុងការប្តឹងតវ៉ា ដើម្បីកាត់បន្ថយការដាក់ទោសទណ្ឌ (រយៈពេល សមត្ថកិច្ច ឯកសារ ជាដើម ។ ល។)
- ឱកាសក្នុងការប្តឹងតវ៉ា គឺជាសិទ្ធិសំខាន់ដែលគួរតែផ្តល់ដល់និយោជិត និងដៃគូធុរកិច្ច។

### ឃ) ការផ្តល់ព័ត៌មាន ឬការផ្សព្វផ្សាយពីការរំលោភបំពាន

- ការរំលោភបំពានធ្ងន់ធ្ងរដោយបុគ្គលិក គួរផ្តល់ព័ត៌មាន ឬផ្សព្វផ្សាយពីការរំលោភបំពាននោះនៅទូទាំងក្រុមហ៊ុន ហើយរាល់ការរំលោភបំពានដែលរកឃើញដោយផ្នែកអនុលោមតាមច្បាប់ គួរផ្តល់ព័ត៌មានដល់ផ្នែកធនធានមនុស្ស ឬផ្នែកបណ្តុះបណ្តាលដែលអាចផ្តួចផ្តើមចំណាត់ការវិន័យ ឬរកដំណោះស្រាយ
- ការរំលោភបំពានធ្ងន់ធ្ងរដោយដៃគូធុរកិច្ច ក៏គួរផ្តល់ព័ត៌មានដល់ផ្នែកពាក់ព័ន្ធដែរ
- គួរមានបទដ្ឋានសម្រាប់របាយការណ៍ផ្ទៃក្នុង ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានតាមផ្នែក និងតំបន់ ហើយការផ្តល់ព័ត៌មានបែបបុរេសកម្មពីការរំលោភបំពាន អាចទទួលបានការកាត់បន្ថយទោសទណ្ឌ
- ក្រុមហ៊ុនគួរពិចារណាពីក្របខ័ណ្ឌច្បាប់ជាតិ នៅពេលផ្តល់ព័ត៌មានដល់អាជ្ញាធរបរទេសពីការរំលោភបំពាន ។

### ង) ការសម្រេចពីចំណាត់ការដោះស្រាយ

- ការរកឃើញការប៉ុនប៉ង ឬការរំលោភបំពាន គួរចាត់ទុកជាឱកាស ដើម្បីពង្រឹងកម្មវិធីប្រឆាំងអំពើពុករលួយ ឬដំណើរការធុរកិច្ច ឧទា. ការរំលោភបំពានលើច្បាប់លទ្ធកម្មអាចជាសញ្ញាថា យន្តការលទ្ធកម្មគ្មានប្រសិទ្ធភាព ដូច្នេះចាំបាច់ត្រូវវិភាគរកចំណុចខ្សោយ ឬដំណោះស្រាយដែលអាចរួមមាន៖
    - ការពង្រឹងបរិស្ថានត្រួតពិនិត្យផ្ទៃក្នុង៖ គួរធ្វើឱ្យបានញឹកញាប់ជាងមុន - ស៊ីជម្រៅជាងមុន ឬអាចផ្លាស់ប្តូរថ្មីតែម្តង
    - ការបង្កើនការបណ្តុះបណ្តាល និងការប្រាស្រ័យទាក់ទង៖ បើការរំលោភបំពានកើតឡើង ដោយការមិនដឹង (ឧទា. ករណីប្រាក់សម្រួលការងារ) ឬ ដោយការពិបាកគោរពតាមក្រមសីលធម៌ (ឧទា.សំណើទារប្រាក់ដោយបង្ខំ) ក្រុមហ៊ុន

គប្បីបង្កើនសកម្មភាពបណ្តុះបណ្តាល និងហ្វឹកហ្វឺន ឬត្រួតពិនិត្យឡើងវិញនូវការប្រាស្រ័យទាក់ទងពីការប្រឆាំងអំពើពុករលួយ (ដោយប្រើមូលដ្ឋានច្បាប់ដើម្បីជាមូលដ្ឋានចរថា - ការប្រើកម្រងសេវាសាធារណៈ - ការលើកឡើងពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ - ការរាយការណ៍មកអង្គភាពប្រឆាំងអំពើពុករលួយ ។ល។)

  - ការត្រួតពិនិត្យគោលនយោបាយវិន័យរបស់ក្រុមហ៊ុនឡើងវិញ(ឧទា.គោលនយោបាយអាចខ្សោយពេក - ទោសទណ្ឌអាចស្រាលពេក)

- គ្រប់ព្រឹត្តិការណ៍ គួរកត់ត្រាជាឯកសារសម្រាប់ការត្រួតពិនិត្យនៅថ្ងៃមុខ និងពង្រឹងការហ្វឹកហ្វឺន និងការប្រាស្រ័យទាក់ទង ។ កំណត់ត្រាអាចជួយឱ្យប្រៀបធៀបគ្នាបាន និងគួររួមមានប្រភពព័ត៌មាន អ្នកទទួលព័ត៌មាន និងរបៀបឆ្លើយតបនឹងព្រឹត្តិការណ៍
- គួរដាក់ចេញនូវលក្ខណៈវិនិច្ឆ័យក្នុងការកាត់បន្ថយទោសទណ្ឌ (ឧទា. ការផ្តល់នូវព័ត៌មានបន្ថែមដែលរកមិនឃើញ ការសហការល្អជាមួយអ្នកទទួលបន្ទុកត្រួតពិនិត្យ ការដឹងខ្លួនខុសហើយកែខ្លួនជាដើម)
- ការលើកទឹកចិត្តកាត់បន្ថយទោសទណ្ឌនេះ អាចជាសញ្ញានៃការទុកចិត្តដែលអាចលើកទឹកចិត្តអ្នករំលោភបំពានឱ្យគោរពតាមគោលនយោបាយ និងនីតិវិធីនៅថ្ងៃអនាគតហើយក៏អាចឱ្យកម្មវិធីប្រឆាំងអំពើពុករលួយបានទទួលជោគជ័យផងដែរ ។

## ច) ការឆ្លើយតបទៅនឹងការរំលោភបំពាន

- កំហុសដែលជាទូទៅត្រូវបានគិតថា តូចតាច ឬមធ្យម គួរដាក់ទោសឱ្យបានសមរម្យដើម្បីបង្ហាញថា ក្រុមហ៊ុនមិនអត់ឱនឱ្យការធ្វើខុសទេ ហើយក៏មិនដាក់ទោសធ្ងន់ធ្ងរហួសពីកំហុសដែលបានប្រព្រឹត្តដែរ ។ ការធ្វើដូច្នេះ គឺកាន់តែសំខាន់ នៅពេលមិនមានការខាតបង់ដោយសារកំហុស ប៉ុន្តែកំហុសកើតឡើងដោយសារការមិនយកចិត្តទុកដាក់ ឬការគេចវេស ។
- ការឆ្លើយតប ស្របតាមគោលនយោបាយវិន័យ រួមមាន៖
  - ការដាក់ទោសទណ្ឌ ដល់បុគ្គលិក និងដៃគូដែលមានការពាក់ព័ន្ធ
  - ការជូនដំណឹងដល់អាជ្ញាធរផ្ទៃក្នុង និងផ្ទៃក្រៅ និង
  - ការសម្រេចលើចំណាត់ការដោះស្រាយ ។

## ៨) ការដាក់ទោសទណ្ឌ

- ទោសទណ្ឌសម្រាប់បុគ្គលិក៖ អាចរួមមានការពិន័យជាប្រាក់ - កាត់ប្រាក់បៀវត្ស - មិនតម្លើងឋានៈ - ទម្លាក់តំណែងទាបជាងមុន ឬបញ្ចប់កិច្ចសន្យាការងារ ។
- ក្រុមហ៊ុន គួរជៀសវាងអនុញ្ញាតឱ្យមាន៖
    - ការពន្យាពេលបញ្ចប់កិច្ចសន្យាការងារសម្រាប់បុគ្គលិកដែលមានការងារច្រើន ឬថ្នាក់គ្រប់គ្រងជាន់ខ្ពស់
    - ការលាលែង ដោយមិនចាំបាច់បណ្ដេញចេញ (ព្រោះអាចនាំឱ្យមានសញ្ញាខ្សោយក្នុងការអនុវត្តវិន័យ) ។
- ទោសទណ្ឌសម្រាប់ដៃគូធុរកិច្ច៖
    - អាចរួមមានការផ្ដាច់ទំនាក់ទំនង៖ បិទឱកាសរកស៊ីជាមួយគ្នា (ឧទា. ហាមឃាត់) ឬផ្ដល់លក្ខខណ្ឌពាណិជ្ជកម្ម និងប្រតិបត្តិការដែលមិនអំណោយផល (ឧទា. តម្រូវឱ្យមានការយកចិត្តទុកដាក់ស្គាល់អតិថិជនខ្ពស់ជាងមុន)
    - តាមករណីជាក់ស្ដែង ក្រុមហ៊ុនអាចប្រកាសពីការដាក់ទោសទណ្ឌជាសាធារណៈ ដោយផ្អែកលើគោលនយោបាយវិន័យក្រុមហ៊ុនបន្ទាប់ពីអនុវត្តដំណើរការត្រួតពិនិត្យដោយសត្យានុម័ត និងតម្លាភាព ។

## + សារៈសំខាន់នៃការសហការជាមួយអាជ្ញាធរ

- រដ្ឋភាគី UNCAC គួរលើកទឹកចិត្តឱ្យក្រុមហ៊ុនរាយការណ៍ពីការរំលោភបំពានទៅអាជ្ញាធរពាក់ព័ន្ធ (ទោះបីជាមិនមានតម្រូវការផ្លូវច្បាប់ជាក់លាក់ក៏ដោយ) ។
- ក្រុមហ៊ុនមានតួនាទីសំខាន់ណាស់ក្នុងការទប់ស្កាត់ តាមរកឱ្យឃើញ និងកាត់ទោសអ្នកពាក់ព័ន្ធនឹងអំពើពុករលួយ ព្រោះក្រុមហ៊ុនអាចសហការ និងជួយអង្គភាពប្រឆាំងអំពើពុករលួយ ឱ្យយល់ពីរបៀបដែលអំពើពុករលួយកើតឡើង របៀបរកឱ្យឃើញ និងការនាំយកត្រឡប់មកវិញនូវផលនៃបទល្មើស ។
- ក្រុមហ៊ុនអាចសហការដោយស្ម័យរាយការណ៍ពីការរំលោភបំពាន និងផ្ដល់ភស្តុតាងជាក់ស្ដែងទាក់ទងព័ត៌មានផ្ទៃក្នុង និងដៃគូ មុនពេលអាជ្ញាធរចោទប្រកាន់ ហើយក៏អាចសហការក្រោយពេលដែលអាជ្ញាធរដឹងពីបទល្មើសពុករលួយដែរ ឧទា. អាចឱ្យបុគ្គលិកសវនកម្មផ្ទៃក្នុងគាំទ្រដល់ការស៊ើបអង្កេត ឬចាត់វិធានការដូចជា៖

- ស្តារឡើងវិញដោយស្ម័គ្រចិត្តនូវការខូចខាត ឬបាត់បង់ដោយសារបទល្មើស
- រឹបអូសមកវិញនូវផលនៃបទល្មើស
- ទប់ស្កាត់ដោយស្ម័គ្រចិត្តផ្សេងៗ (ឧទា. មិនចូលរួមដេញថ្លៃ)
- ទទួលយកនូវអ្នកត្រួតពិនិត្យការអនុលោមតាមច្បាប់ផ្ទៃក្រៅ
- ចំណាត់ការកែសម្រួលការរៀបចំ (ឧទា. ដក ឬ ដាក់វិន័យបុគ្គលិក)
- ពង្រឹងកម្មវិធីប្រឆាំងអំពើពុករលួយ ដោយលុបចំណុចខ្សោយ ។

- ទោសទណ្ឌដែលក្រុមហ៊ុនរំលោភបទដ្ឋានប្រឆាំងអំពើពុករលួយ អាចរួមមានទណ្ឌកម្មផ្លូវច្បាប់ ទណ្ឌកម្មពាណិជ្ជកម្ម និងការខូចកិត្តិយស ។
- ប្រទេសខ្លះអាចផ្តល់ឱ្យក្រុមហ៊ុន ដែលបានសហការផ្តល់ព័ត៌មានសំខាន់ៗស្តីពីការប្រព្រឹត្តខុសរបស់ក្រុមហ៊ុននូវអត្ថប្រយោជន៍មួយចំនួនដូចជា៖
  - ការបន្ថយពិន័យប្រាក់ (បើអាចបង្ហាញថា រឿងកើតឡើង គឺដោយសារតែបុគ្គលិកមិនល្អម្នាក់ មិនមែនជាការបរាជ័យបែបប្រព័ន្ធរបស់កម្មវិធីប្រឆាំងអំពើពុករលួយទេ)
  - ដកចេញពីបញ្ជីខ្មៅ ។
- កត្តាជំរុញឱ្យក្រុមហ៊ុនសហការ អាចរួមមាន៖
  - កាត់បន្ថយ ឬព្យួរទោស
  - រក្សាការសម្ងាត់ពីភាពមិនប្រក្រតី
  - ជៀសវាងនីតិវិធីព្រហ្មទណ្ឌ និងជ្រើសយកនីតិវិធីរដ្ឋប្បវេណីវិញ
  - អនុញ្ញាតឱ្យមានការដោះស្រាយក្រៅតុលាការ
  - ស្តារសម្បទាក្រុមហ៊ុនមានទោស ដោយប្រកាសជាសាធារណៈពីអាកប្បកិរិយាដែលបានកែលម្អ ។
- ការលើកទឹកចិត្តលើការបន្ថយទោសមុនពេលអាជ្ញាធរបានដឹង គឺជាការចង់បានជាជាងក្រោយពេលអាជ្ញាធរបានដឹង ឧទា. ការប្រកាសដោយស្ម័គ្រចិត្តពីកំហុសខ្លួន អាចឱ្យក្រុមហ៊ុនបន្តចូលរួមដេញថ្លៃគម្រោងបាន ។ ប៉ុន្តែការលើកទឹកចិត្តបែបនេះអាចកាត់បន្ថយឥទ្ធិពលនៃការដាក់ទោសបាន ប្រសិនបើលើកទឹកចិត្តខ្លាំងពេក ។ ហេតុដូច្នេះ ហើយការអនុវត្តជាក់ស្តែង គួរតែធ្វើការពិចារណាឱ្យបានហ្មត់ចត់ ។

+ បញ្ហាប្រឈមក្នុងការសហការជាមួយអាជ្ញាធរ

- បញ្ហាប្រឈមក្នុងករណីនេះ មានដូចជា៖
    - ការកាត់ទោសឆ្លងយុត្តាធិការ៖ សម្រាប់ក្រុមហ៊ុនមានប្រតិបត្តិការពហុយុត្តាធិការ ពេលសហការជាមួយអាជ្ញាធរប្រទេសមួយ ក្រុមហ៊ុនអាចគិតពីផលវិបាកនៃកិច្ចសហការជាមួយប្រទេសដទៃ
    - ការការពារបុគ្គលរាយការណ៍ ពីការប្រព្រឹត្តអំពើមិនសមរម្យ
    - ការការពារសាក្សី និងជនរងគ្រោះ ពីការសងសឹក និងការគំរាម
    - ការរំលោភបំពានលើទិន្នន័យឯកជនដែលអាចកើតឡើង ឧទា. ការសម្ងាត់ធនាគារ ។
- ការដោះស្រាយបញ្ហាប្រឈមខាងលើ គប្បីធ្វើឡើងដោយមានបទដ្ឋានគតិយុត្តគ្រប់គ្រាន់ ប៉ុន្តែក្នុងករណីបទដ្ឋានគតិយុត្តមិនទាន់មាន ក្រុមហ៊ុនគប្បីយកចិត្តទុកដាក់ផ្តល់ការការពារ និងផ្តល់ការលើកទឹកចិត្តឱ្យបានល្អប្រសើរ តាមតែអាចធ្វើបាន ។

សម្គាល់

+ បញ្ហាប្រឈម និងឱកាសសម្រាប់ SMEs

- SMEs គួរធ្វើដូចក្រុមហ៊ុនធំៗដែរ ក្នុងការដោះស្រាយការរំលោភបំពាន
- ការបណ្តេញបុគ្គលិកពុករលួយពីការងារ ឬផ្តាច់ទំនាក់ទំនងជាមួយដៃគូ អាចជាការខាតបង់ច្រើនក្នុងរយៈពេលខ្លី ប៉ុន្តែ SMEs គួរចាត់ទុកថា នេះជាការវិនិយោគសម្រាប់រយៈពេលវែង
- គួរពិចារណាការសហការជាមួយអាជ្ញាធរ ដូចក្រុមហ៊ុនធំៗដែរ ដើម្បីបានផល និងការលើកទឹកចិត្តបន្ធូរបន្ថយទោសទណ្ឌ
- SMEs អាចត្រូវការទីប្រឹក្សាជំនាញ (ឧទា. ផ្នែកច្បាប់) ដើម្បីណែនាំពីកិច្ចសហការជាមួយអាជ្ញាធរ ប៉ុន្តែការចំណាយអាចច្រើន
- SMEs អាចរកជំនួយពីប្រភពផ្សេងៗ ដូចជាសមាគមក្នុងស្រុកជាដើម ។

+ ការរាយការណ៍

- ក្រុមហ៊ុនគប្បីពណ៌នាពីដំណើរការដោះស្រាយបញ្ហា
- បញ្ជាក់ពីប្រភេទ ចំនួនបញ្ហា និងចំនួនចំណាត់ការដាក់វិន័យ

- បង្ហាញពីការស៊ើបអង្កេត ការចោទប្រកាន់ក្នុងរបាយការណ៍ ឬវិបសាយក្រុមហ៊ុន (តែប្រយ័ត្នព័ត៌មាននាំឱ្យខូចដល់ការស៊ើបអង្កេតកំពុងធ្វើ) ។

## K.1. យោជ័បឧជ្ឋានអន្តរជាតិ

សាជីវកម្មត្រូវបញ្ជាក់ឱ្យច្បាស់ថាការអនុលោមតាមកម្មវិធី គឺជាកាតព្វកិច្ច ហើយគ្មានបុគ្គលិកណាត្រូវទទួលរងនូវការទម្លាក់ឋានៈ ការពិន័យ និងផលអវិជ្ជមាន ចំពោះការមិនបង់ប្រាក់សំណូកឡើយ ទោះបីជាសាជីវកម្មអាចនឹងទទួលរងនូវលទ្ធផលនៃការបាត់បង់ធុរកិច្ចក៏ដោយ ។ សាជីវកម្មគួរតែសហការឱ្យបានត្រឹមត្រូវជាមួយនឹងអាជ្ញាធរពាក់ព័ន្ធ ទាក់ទងនឹងការស៊ើបអង្កេត និងការកាត់ទោស ពីបទស៊ីសំណូក និងពុករលួយ ។

## K.2. យោជ័បឧជ្ឋានជាតិ

***ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ២០១០*** អនុញ្ញាតឲ្យគ្រឹះស្ថានឥណទាន ឬស្ថាប័នហិរញ្ញវត្ថុរួចផុតពីការទទួលខុសត្រូវទាំងអស់ ហើយគ្មានបណ្តឹងព្រហ្មទណ្ឌណាមួយត្រូវបានធ្វើប្រឆាំងនឹងអ្នកដឹកនាំ ឬអាណត្តិនៃគ្រឹះស្ថាន ឬស្ថាប័ននោះឡើយ ប្រសិនបើប្រតិបត្តិការនោះត្រូវបានអនុវត្តស្របតាមបទបញ្ញត្តិច្បាប់ លើកលែងតែក្នុងករណីដែលរកឃើញថាមានការព្រមព្រៀងគ្នាជាមុន ដើម្បីរៀបចំបន្លំជាមួយម្ចាស់ប្រាក់ ឬអ្នកធ្វើប្រតិបត្តិការ ។ ***ក្រមព្រហ្មទណ្ឌ ២០០៩*** ក៏បានកំណត់ពីទោសទណ្ឌចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តអំពើពុករលួយ ដូចជាការស៊ីសំណូក ការសូកប៉ាន់ ជាដើម ។ ចំណែកឯ ***ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ២០១២*** ក៏បានកំណត់ពីទណ្ឌកម្ម និងទោសព្រហ្មទណ្ឌចំពោះអ្នកដេញថ្លៃ អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ ដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬផ្តល់ភស្តុតាងក្លែងក្លាយ ឬមិនត្រឹមត្រូវក្នុងការដាក់ពាក្យប្តឹងតវ៉ានៅក្នុងដំណើរការលទ្ធកម្ម ។

## K.3. ករណីសិក្សា

### *ក្រុមហ៊ុនទូរគមនាគមន៍មួយដោះស្រាយបញ្ហាសូកប៉ាន់ដោយភាគីទី៣*

- ក្រុមហ៊ុនចម្រុះជាតិសាសន៍របស់សហរដ្ឋអាមេរិក បានធ្វើប្រតិបត្តិការក្នុងវិស័យទូរគមនាគមន៍នៅអឺរ៉ុបខាងកើតជាច្រើនឆ្នាំ ។ នៅក្នុងសាខាមួយរបស់ក្រុមហ៊ុននេះ មានការចោទប្រកាន់ថា មានការសូកប៉ាន់មន្ត្រីមូលដ្ឋានរបស់រដ្ឋាភិបាល ដើម្បីទទួល

បានកិច្ចសន្យាសាងសង់ និងតបណ្តាញទូរគមនាគមន៍ ។ ប្រាក់សំណូកធ្វើឡើងតាមរយៈភាគីទី៣ ហើយមានព័ត៌មានថា នាយកប្រតិបត្តិរបស់សាខាក្រុមហ៊ុន ភាគីទី៣ និងអាជ្ញាធរមូលដ្ឋាន មានផលប្រយោជន៍រួមគ្នា និងមានហ៊ុនជាមួយគ្នាផងដែរ ។

- ក្រុមហ៊ុនបានធ្វើការស៊ើបអង្កេតផ្ទៃក្នុង ដើម្បីត្រួតពិនិត្យមើលលើចំណុចដែលត្រូវបានចោទប្រកាន់ តាមរយៈឯកសារនានា ការធ្វើកោសលវិច័យប្រព័ន្ធ IT ការពិនិត្យមើលទ្រព្យសម្បត្តិរបស់បុគ្គលពាក់ព័ន្ធ និងការសម្ភាសន៍បុគ្គលិក ។ បន្ទាប់ពីការស៊ើបអង្កេតមានភស្តុតាងបង្ហាញថា នាយកប្រតិបត្តិ និងអ្នកប្រឹក្សាយោបល់ មានទំនាក់ទំនងគ្នា និងមានហ៊ុនជាមួយគ្នា ប៉ុន្តែគ្មានភស្តុតាងបង្ហាញថា អ្នកទាំងពីរមានទំនាក់ទំនងជាមួយអ្នកនយោបាយទេ ។ ហើយករណីនេះ ប្រហែលជាអំពើពុករលួយក្នុងវិស័យពាណិជ្ជកម្ម ដែលមិនត្រូវបានដាក់ទណ្ឌកម្មដោយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយរបស់អាមេរិក ។
- ជាលទ្ធផល មេធាវីក្រុមហ៊ុនបានវាយតម្លៃថា គ្មានការចាំបាច់ត្រូវធ្វើស្វ័យរបាយការណ៍ទៅអាជ្ញាធរអាមេរិកទេ ព្រោះលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា មានតែការរំលោភបំពានលើកម្មវិធីប្រឆាំងអំពើពុករលួយរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ដោយសារកម្មវិធីនេះមានការខ្វះចន្លោះ ។ ហេតុនេះក្រុមហ៊ុនមេ បានសម្រេចបញ្ឈប់ការងាររបស់នាយកប្រតិបត្តិរូបនោះ និងកែសម្រួលគោលនយោបាយប្រឆាំងអំពើពុករលួយឡើងវិញ ដោយធ្វើយ៉ាងណារឹតបន្តឹងបន្ថែមទៀត និងបន្ស៊ីជាមួយច្បាប់អាមេរិក និងច្បាប់បរទេសពាក់ព័ន្ធ ។

## L. ការត្រួតពិនិត្យឡើងវិញ និងវាយតម្លៃជាប្រចាំនូវកម្មវិធីប្រឆាំងអំពើពុករលួយ

- ការងារនេះនឹងជួយឱ្យគោលនយោបាយ និងនីតិវិធីរបស់ក្រុមហ៊ុនមានភាពទាន់សម័យជានិច្ច ហើយក៏ជួយកំណត់ចំណុចខ្សោយ ឬឱកាសពង្រឹងកម្មវិធីប្រឆាំងអំពើពុករលួយទូទៅបានផងដែរ ។
- ការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ គួរជាដំណើរការរៀនបន្ត និងកែលម្អជានិច្ច ។

+ *វិចារណកម្មក្នុងការត្រួតពិនិត្យឡើងវិញ និងវាយតម្លៃជាប្រចាំ*

- ការត្រួតពិនិត្យឡើងវិញគឺៈ
  - ប្រមូលព័ត៌មាន និងវិភាគពីធាតុផ្សំនីមួយៗរបស់កម្មវិធីប្រឆាំងអំពើពុករលួយ
  - វាយតម្លៃដំណើរការ ដូចជាការចូលរួមបង្កើតក្រុមប្រតិបត្តិអំពីការចូលរួមផ្តល់ការឧបត្ថម្ភក្នុងកម្មវិធីមួយ
  - សិក្សាស៊ីជម្រៅ និងត្រូវធ្វើឡើងជាផ្នែកមួយនៃកម្មវិធី ។
- ការវាយតម្លៃគឺៈ
  - វិភាគលទ្ធផលនៃការត្រួតពិនិត្យឡើងវិញ
  - ផ្ទុយពីការត្រួតពិនិត្យឡើងវិញ ការងារនេះត្រូវមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់វាយតម្លៃលទ្ធផល ដើម្បីកំណត់រកនូវការចាំបាច់ក្នុងការកែសម្រួល និងកែលម្អ ឧទា. ការវាយតម្លៃមួយអាចនាំឱ្យមានការសន្និដ្ឋានថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៅក្រុមហ៊ុនបុត្រសម្ព័ន្ធមួយ ត្រូវកែលម្អដើម្បីប្រសិទ្ធភាព
  - នាំឱ្យមានឱកាសពង្រឹងប្រសិទ្ធផល ។
- វិចារណកម្មក្នុងការធ្វើការងារនេះគឺព្យាយាមកំណត់ថា តើគោលនយោបាយ ឬនីតិវិធីប្រឆាំងអំពើពុករលួយ ត្រូវការកែសម្រួល ឬអត់ ឧទា. ត្រូវបន្ថែមវិធានការថ្មីលើការហាមឃាត់ប្រាក់សម្រួលការងារ ការបណ្តុះបណ្តាលថ្មី ឬការសម្រួលនូវយុទ្ធសាស្ត្រ (ឧទា. ដោយរៀបចំឱ្យមានការផ្សាយសារពីថ្នាក់ដឹកនាំតាមសម្លេងជាជៀងតាមអ៊ីមែលជាដើម) ។

+ ប្រភពព័ត៌មានសម្រាប់ត្រួតពិនិត្យឡើងវិញ

- ការកែសម្រួលអាចនឹងត្រូវធ្វើ អាស្រ័យលើការផ្លាស់ប្តូរនៅក្នុងបរិយាកាសធុរកិច្ច ឬមេរៀនទទួលបានពីប្រតិបត្តិការផ្ទៃក្នុង ។ ការផ្លាស់ប្តូរបរិស្ថានទីផ្សារអាចមានព្រឹត្តិការណ៍ផ្ទៃក្នុង និងផ្ទៃក្រៅដូចជា៖
    - ទីផ្សារ និងប្រតិបត្តិការធុរកិច្ចថ្មី (ឧទា. តម្រូវឱ្យប្រើភាគីទី 3)
    - ទំនាក់ទំនងធុរកិច្ចថ្មី (ឧទា. អ្នកផ្គត់ផ្គង់ថ្មី)
    - រចនាសម្ព័ន្ធអង្គការថ្មី (ឧទា. បុគ្គលិកសម្ព័ន្ធថ្មី) និងដំណើរការអនុម័ត (ឧទា. ការរកលទ្ធកម្មពីខាងក្រៅ)
    - គោលដៅបំពេញការងារថ្មី
    - តម្រូវការច្បាប់ថ្មី ឬបទដ្ឋានឧស្សាហកម្មថ្មី
    - តម្រូវការថ្មីពីបរិយាកាសសង្គម និងភាគីពាក់ព័ន្ធ (ឧទា. អតិថិជន)
    - រឿងក្តីពុករលួយពីក្រុមហ៊ុនផ្សេងនៅក្នុងឧស្សាហកម្មដូចគ្នា ឬតំបន់មួយ ។
- ការរៀនពីប្រតិបត្តិការផ្ទៃក្នុងអាចរកឃើញនូវចំណុចខ្សោយ ឬឱកាសកែលម្អកម្មវិធីប្រឆាំងអំពើពុករលួយ ។ ដើម្បីរៀនបាន ត្រូវការព័ត៌មានពីប្រភពជាច្រើន ដូចជា៖
    - លទ្ធផលត្រួតពិនិត្យផ្ទៃក្នុង៖ អាចជួយឱ្យឃើញចំណុចខ្សោយ នៃការត្រួតពិនិត្យផ្ទៃក្នុង
    - លទ្ធផលនៃសវនកម្មផ្ទៃក្នុង និងផ្ទៃក្រៅ៖ អាចជួយដល់ការត្រួតពិនិត្យឡើងវិញនូវការវាយតម្លៃរបស់ថ្នាក់គ្រប់គ្រងលើកម្មវិធីប្រឆាំងអំពើពុករលួយ
    - យោបល់ត្រឡប់មកវិញ៖ ព័ត៌មានពីការត្រួតពិនិត្យឡើងវិញនូវគោលនយោបាយ និងកម្មវិធីផ្សេងៗ (អាចបានពីការស្ទាបស្ទង់ពីបុគ្គលិក និងដៃគូធុរកិច្ច)
    - ការវាយតម្លៃ៖ ពីជំនាញបុគ្គលិក ដៃគូ គោលនយោបាយ និងហានិភ័យ អាចផ្តល់រូបភាពគ្រប់ជ្រុងជ្រោយពីធាតុផ្សំផ្សេងៗ នៃកម្មវិធីប្រឆាំងអំពើពុករលួយ ឧទា. ការវាយតម្លៃពីបុគ្គលិកជំនាញនៅតំបន់មានហានិភ័យខ្ពស់អាចបង្ហាញថា ការបណ្តុះបណ្តាលបានធ្វើគ្រប់គ្រាន់ ឬទេ
    - ការកំណត់ការប្រៀបធៀប (Benchmark)៖ របាយការណ៍ ឬឯកសារបោះពុម្ពដែលបានរៀបចំដោយក្រុមហ៊ុនដទៃ ។
- ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ចាំបាច់ត្រូវប្រើព័ត៌មានពីគ្រប់ប្រភពសម្រាប់ជាធាតុចូលក្នុង

ការត្រួតពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយមួយ ហើយការត្រួតពិនិត្យឡើងវិញនេះ គួរធ្វើជាប្រចាំ ។

### + លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ

- បន្ទាប់ពីត្រួតពិនិត្យគ្រប់ជ្រុងជ្រោយ លើកម្មវិធីប្រឆាំងអំពើពុករលួយហើយ ក្រុមហ៊ុនអាចវាយតម្លៃពីការបំពេញការងាររបស់កម្មវិធី ដើម្បីរកចំណុចត្រូវកែលម្អ ។ លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃគ្រប់ជ្រុងជ្រោយ មានដូចជា៖
    - ប្រសិទ្ធភាព៖ ប្រសិទ្ធភាពនៃគោលនយោបាយ និងនីតិវិធីប្រឆាំងអំពើពុករលួយ ឧទា. បានកាត់បន្ថយហានិភ័យប្រាក់សម្រួលការងារ
    - ប្រសិទ្ធផល៖ កាត់បន្ថយចំណាយលើកម្មវិធីប្រឆាំងអំពើពុករលួយ តែជានាលទ្ធផលដដែល
    - និរន្តរភាព៖ កម្រិតដែលគោលនយោបាយ និងនីតិវិធីប្រឆាំងអំពើពុករលួយជួយនាំដល់ការកាត់បន្ថយហានិភ័យអំពើពុករលួយសម្រាប់រយៈពេលវែង ។

ឧទាហរណ៍៖

| សមាសភាពកម្មវិធី | លក្ខណៈវិនិច្ឆ័យ | | |
|---|---|---|---|
| | ប្រសិទ្ធភាព | ប្រសិទ្ធផល | និរន្តរភាព |
| គោលនយោបាយ | | | |
| ការបណ្តុះបណ្តាល និងការប្រាស្រ័យទាក់ទង | | | |
| ការត្រួតពិនិត្យផ្ទៃក្នុង | | | |
| គម្រោងលើកទឹកចិត្ត | | | |
| ការដោះស្រាយបញ្ហា | | | |
| ។ល។ | | | |

- ក្នុងករណីការវាយតម្លៃឃើញថា មិនបានផលដូចការរំពឹងទុកនោះថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងផ្នែកត្រួតពិនិត្យពីលើអាចសម្រេចធ្វើការកែលម្អផ្សេងៗ លើផ្នែកណាមួយចាំបាច់ ។

+ ការប្រើប្រាស់លទ្ធផលទទួលបាន

- លទ្ធផលអាចត្រូវប្រើជាឱកាសសម្រាប់កែលម្អ នៅពេលខាងមុខ
- ចែករំលែក ផ្សព្វផ្សាយ និងអាចឱ្យមានការពិភាក្សាក្នុងចំណោមបុគ្គលិក និងដៃគូដើម្បីបង្ហាញពីការប្តេជ្ញាបន្ត ។ លទ្ធផលអាចរួមមាន ប្រភពព័ត៌មាន - លទ្ធផលវាយតម្លៃ - សកម្មភាពកែលម្អ - កត្តាប្រតិបត្តិការផ្សេងៗ ដូចជាតារាងពេលវេលានៃការអនុវត្តជាដើម ។

+ ការទទួលខុសត្រូវ

- ផ្នែកគ្រប់គ្រងជាន់ខ្ពស់៖ គួរធ្វើការត្រួតពិនិត្យឡើងវិញជាប្រចាំពីកម្មវិធីប្រឆាំងអំពើពុករលួយ និងការវាយតម្លៃពីចំណាត់ការល្អបំផុតដើម្បីកែលម្អ ដូចជាការកាត់បន្ថយប្រសិទ្ធភាព ហើយលទ្ធផល និងអនុសាសន៍ប្រមូលបានត្រូវប្រគល់ជូនក្រុមប្រឹក្សានាយក
- ក្រុមប្រឹក្សានាយក ឬអង្គស្មើគ្នាផ្សេងពីនេះ៖ ត្រូវវាយតម្លៃ និងអនុម័តលើចំណាត់ការដែលបានជ្រើសរើស ដោយផ្នែកគ្រប់គ្រងជាន់ខ្ពស់ ហើយក៏អាចផ្តួចផ្តើមឱ្យធ្វើការត្រួតពិនិត្យ និងវាយតម្លៃពិសេសបន្ថែមដែរបើចាំបាច់ ។

សម្គាល់

+ បញ្ហាប្រឈម និង ឱកាសសម្រាប់ SMEs

- ការអនុវត្តកម្មវិធីប្រឆាំងអំពើពុករលួយ ត្រូវតែជាដំណើរការ និងការប្តេជ្ញាបន្តសម្រាប់ SMEs
- ដោយសារកត្តាហិរញ្ញវត្ថុ និងពេលវេលា ការវាយតម្លៃអាចពឹងផ្អែកលើយោបល់ត្រឡប់ និងឯកសារ ឬជាទម្រង់វាយតម្លៃហានិភ័យទូទៅ ។

+ ការរាយការណ៍

- ក្រុមហ៊ុនគប្បីពណ៌នាអំពីដំណើរការដែលមាន ភាពញឹកញាប់នៃការត្រួតពិនិត្យការបន្តកែលម្អ និងការយកលទ្ធផលមកប្រើប្រាស់
- ពណ៌នាអំពីដំណើរការទំនាក់ទំនងផ្ទៃក្នុង និងផ្ទៃក្រៅ នៃការត្រួតពិនិត្យ និងដំណើរការកែលម្អ និងលទ្ធផល
- ពណ៌នាអំពីការត្រួតពិនិត្យមើលពីលើនូវដំណើរការត្រួតពិនិត្យ
- ពណ៌នាអំពីចំណាត់ការ និងលទ្ធផលនៃការកែលម្អ - ការវាយតម្លៃឯករាជ្យផ្ទៃក្រៅ
- បញ្ជាក់ពីលក្ខណៈ និងវិសាលភាព នៃការវាយតម្លៃឯករាជ្យផ្ទៃក្រៅ

- បញ្ជាក់ពីវិសាលភាព នៃការចូលរួម
- ពណ៌នាថាតើលទ្ធផលនៃការវាយតម្លៃឯករាជ្យផ្នែកក្រៅ មានជាសាធារណៈ ឬអត់ ។

## L.1. យោងបទដ្ឋានអន្តរជាតិ

អ្នកគ្រប់គ្រងជាន់ខ្ពស់ក្រុមហ៊ុនត្រូវពិនិត្យ តាមដានកម្មវិធីប្រឆាំងអំពើពុករលួយ និង ត្រួតពិនិត្យឡើងវិញឱ្យទៀងទាត់នូវភាពគ្រប់គ្រាន់ ភាពសមស្រប និងប្រសិទ្ធភាពនៃការអនុវត្ត កម្មវិធីឱ្យបានប្រសើរឡើងតាមការចាំបាច់ ហើយត្រូវរាយការណ៍ទៅគណៈកម្មការសវនកម្ម និង/ឬក្រុមប្រឹក្សានាយកនូវលទ្ធផលនៃការត្រួតពិនិត្យកម្មវិធី ។ គណៈកម្មការសវនកម្ម និង ក្រុមប្រឹក្សានាយក ត្រូវតែធ្វើការវាយតម្លៃដោយឯករាជ្យនូវភាពគ្រប់គ្រាន់របស់កម្មវិធី និង ត្រូវបង្ហាញពីលទ្ធផលនៃរបាយការណ៍ប្រចាំឆ្នាំទៅម្ចាស់ភាគហ៊ុន ។

## L.2. ករណីសិក្សា

**ក្រុមហ៊ុនអន្តរជាតិ S ដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេស ត្រួតពិនិត្យការអនុវត្ត កម្មវិធីប្រឆាំងអំពើពុករលួយ**

- ក្រុមហ៊ុន S មានប្រតិបត្តិការនៅជាង ៨០ ប្រទេស ។ ក្នុងប្រតិបត្តិការរបស់ខ្លួន ក្រុមហ៊ុនមានការសង្ស័យថា មានហានិភ័យនៃការស៊ីសំណូក សូកប៉ាន់ ហេតុនេះ ក្រុមហ៊ុនបានធ្វើការស៊ើបអង្កេតផ្ទៃក្នុង ។ ដោយសារក្រុមហ៊ុនពុំមានកម្មវិធីប្រឆាំងអំពើ ពុករលួយ ក្រុមហ៊ុនបានបង្កើតក្រុមអនុលោមតាមច្បាប់ ដើម្បីវាយតម្លៃហានិភ័យ និងបង្កើតគោលនយោបាយ និងនីតិវិធីសមស្របសម្រាប់អនុវត្តផ្ទៃក្នុង ។
- បន្ទាប់ពីកម្មវិធីប្រឆាំងអំពើពុករលួយរបស់ខ្លួនត្រូវបានបង្កើត ក្រុមហ៊ុនបានធ្វើការ ត្រួតពិនិត្យការអនុវត្ត ដោយមានសកម្មភាព ៣ សំខាន់គឺ សវនកម្ម - ការត្រួតពិនិត្យ ឡើងវិញ - និងការធ្វើស្វ័យវាយតម្លៃ ។ ធាតុផ្សំទាំង៣ នេះ ត្រូវបានរៀបចំឡើងដើម្បី រកឲ្យឃើញនូវចំណុចខ្សោយ និងចែករំលែកការអនុវត្តល្អៗ ។ ការធ្វើសវនកម្ម និងការ ត្រួតពិនិត្យឡើងវិញ ត្រូវបានអនុវត្តទៅលើប្រធានបទសំខាន់ចំនួន៧ គឺ (១)អភិបាលកិច្ច (២)ការវាយតម្លៃហានិភ័យ (៣)ការយកចិត្តទុកដាក់ស្គាល់អតិថិជន/ការគ្រប់គ្រងដៃគូ ធុរកិច្ច (៤)ការបណ្តុះបណ្តាល និងហ្វឹកហាត់ (៥)នីតិវិធី និងការត្រួតពិនិត្យការ ប្រឆាំងអំពើពុករលួយ (៦)ការផ្តល់ឱកាសសួរសំណួរ បញ្ចេញមតិព្រួយបារម្ភ និង មតិយោបល់ និង (៧)ការត្រួតពិនិត្យឡើងវិញ ។

- ជាលទ្ធផល យន្តការទាំងអស់នេះអាចធ្វើឲ្យអ្នកគ្រប់គ្រងក្រុមហ៊ុន ស្វែងយល់បានពីកម្រិតនៃការយល់ដឹងរបស់បុគ្គលិកអំពីកម្មវិធីប្រឆាំងអំពើពុករលួយ ការកាត់បន្ថយហានិភ័យនៃអំពើពុករលួយ និងទទួលបាននូវចំណេះដឹងថ្មីទៀតពីមតិយោបល់របស់បុគ្គលិក និងអាចកែសម្រួលកម្មវិធីរបស់ខ្លួនបានល្អ និងទាន់ពេលវេលា ។

## IV. ការផ្លាស់ប្តូរពីកម្រិតក្រុមហ៊ុន ទៅជាចំណាត់ការរួម

- ការអនុវត្ត និងបន្តកែលម្អកម្មវិធីប្រឆាំងអំពើពុករលួយ គឺជាសមិទ្ធផលធំរបស់ក្រុមហ៊ុន ហើយក៏ជាមូលដ្ឋានគ្រឹះសម្រាប់ការប្រឆាំងអំពើពុករលួយនៅក្នុងបរិស្ថានធុរកិច្ចដែរ។
- ប៉ុន្តែក្រុមហ៊ុនអាចប្រឈមនឹងហានិភ័យថា ក្រុមហ៊ុនដទៃមិនគោរពតាមបទដ្ឋានប្រឆាំងអំពើពុករលួយដូចគ្នា ហើយក៏អាចប្រឈមនឹងការទាមទារ និងជំរិតពីផ្នែកសាធារណៈដែរ ជាពិសេស SMEs (ក្រុមហ៊ុនធំៗនៅក្នុងបរិស្ថានសាកល និងមានការប្រកួតប្រជែងខ្លាំងក៏ដូច្នេះដែរ) ។
- វិធីមួយសម្រាប់ឱ្យក្រុមហ៊ុនដោះស្រាយហានិភ័យនេះគឺ «សកម្មភាពរួមគ្នា» ជាមួយដៃគូផ្សេងៗទៀតដែលអាចប្រឈមនឹងបញ្ហាដូចគ្នា ។ សកម្មភាពរួមគ្នា បង្កើននូវឥទ្ធិពល និងភាពជឿទុកចិត្តបានល្អជាងសកម្មភាពបុគ្គល ហើយក៏នឹងនាំឱ្យតួអង្គដ៏ងាយរងគ្រោះចូលក្នុងសម្ព័ន្ធនៃអង្គភាពដែលគិតដូចគ្នា និងដែលចង់ប្រកួតប្រជែងដោយស្មើភាពគ្នាផងដែរ ។ សកម្មភាពរួមគ្នា អាចបំពេញបន្ថែម និងជួយពង្រឹងការគោរពច្បាប់ និងការអនុវត្តការប្រឆាំងអំពើពុករលួយក្នុងស្រុកបានល្អ និងមាននិរន្តរភាព ។
- សកម្មភាពរួម គឺជាវិធីសាស្ត្រប្រឆាំងអំពើពុករលួយដ៏ល្អក្នុងឧស្សាហកម្មនានា និងក្នុងប្រទេសផ្សេងៗ ហើយអាចជាកិច្ចព្រមព្រៀងរយៈពេលខ្លីដល់វែងជាមួយនឹងស្ថាប័នអនុវត្តច្បាប់ពាក់ព័ន្ធ ។ ក្រុមហ៊ុនដែលចូលរួមនឹងគំនិតផ្តួចផ្តើមរួមគ្នា អាចសម្រេចបាននូវគោលបំណងរួម ដោយប្រសិទ្ធភាពជាជៀងធ្វើម្នាក់ឯង ។
- គំនិតផ្តួចផ្តើមរួម អាចធ្វើក្នុងចំណោមផ្នែកឯកជនខ្លួនឯង (ឧទា. SMEs ដែលស្នើសុំឱ្យមានបទដ្ឋានសម្រាប់អ្នកផ្គត់ផ្គង់ដូចគ្នា ពីក្រុមហ៊ុនធំៗ) ឬចូលរួមក្នុងភាពជាដៃគូរវាងផ្នែកសាធារណៈ និងឯកជន (ឧទា. ការដោះស្រាយរួមគ្នានូវបញ្ហា ដូចជាប្រាក់សម្រួលការងារ ឬការតស៊ូមតិឱ្យមានការកែលម្អបរិស្ថានបទបញ្ញត្តិ និងធុរកិច្ច) ។ ស្ថាប័នជាតិ និងអន្តរជាតិ រួមទាំងស្ថាប័នអនុវត្តច្បាប់ និងសមាគមធុរកិច្ចជាដើម អាចដើរតួសំខាន់ក្នុងការសម្របសម្រួលគំនិតផ្តួចផ្តើមបែបនេះ ។
- ជាមួយនឹងសកម្មភាពរួមគ្នា ក្រុមហ៊ុនគ្រប់ទំហំអាចក្លាយជាភ្នាក់ងារផ្លាស់ប្តូរដ៏មានន័យទាក់ទងនឹងគោលនយោបាយ និងនីតិវិធីប្រឆាំងអំពើពុករលួយដែលជំរុញកិច្ចប្រឹងប្រែងក្នុងផ្នែកឯកជន និងសាធារណៈក្នុងការកាត់បន្ថយអំពើពុករលួយ និងចូលរួមធ្វើកំណែទម្រង់ដ៏មានប្រសិទ្ធភាព ។

## V. សេចក្តីបញ្ចប់

- សៀវភៅណែនាំស្តីអំពីកម្មវិធីប្រឆាំងអំពើពុករលួយ សម្រាប់ធុរកិច្ចនៅកម្ពុជា ត្រូវបានរៀបចំឡើងមិនដើម្បីបង្កើតនូវបទដ្ឋានថ្មី ឬដើម្បីដាក់ចេញនូវតម្រូវការកាតព្វកិច្ចដាច់ខាតណាមួយសម្រាប់វិស័យឯកជនទេ ។ គោលបំណងសំខាន់របស់សៀវភៅណែនាំ គឺគ្មានអ្វីក្រៅពីចូលរួមបម្រើ និងដើរតួជាកម្រងព័ត៌មាន ជាមគ្គុទេសក៍សម្រាប់វិស័យឯកជនទូទៅ សិក្សា ដកស្រង់ និងទាញយកនូវខ្លឹមសារ និងគំនិតល្អៗដែលមានក្នុងនេះ មកពិចារណា ប្រើប្រាស់ និងអនុវត្តដាក់ស្តែងរៀងៗខ្លួន ។
- ទោះបីជាយ៉ាងណាក៏ដោយ អង្គភាពប្រឆាំងអំពើពុករលួយ លើកទឹកចិត្ត និងជំរុញដល់ស្ថាប័នឯកជនទូទៅ ទាំងស្ថាប័នដែលមានកម្មវិធីប្រឆាំងអំពើពុករលួយ សម្រាប់អនុវត្តផ្ទៃក្នុងខ្លួន និងស្ថាប័នដែលមិនទាន់មាន ឬកំពុងពិចារណារៀបចំបង្កើតកម្មវិធីដូចនេះ ធ្វើការទាញយកចំណេញឱ្យបានច្រើន តាមតែអាចធ្វើទៅបាន ពីសៀវភៅណែនាំនេះ សំដៅចូលរួមកសាង និងពង្រឹងវប្បធម៌ស្អាតស្អំផ្ទៃក្នុងស្ថាប័ន ក៏ដូចជាក្នុងវិស័យធុរកិច្ចនៅកម្ពុជា ។ អ.ប.ព. ជឿជាក់ថាវប្បធម៌ធុរកិច្ចស្អាតស្អំ នឹងជួយបង្កើតនូវបរិយាកាសធុរកិច្ចនៅកម្ពុជា ឱ្យកាន់តែអំណោយផលដល់ការប្រកួតប្រជែងដោយត្រឹមត្រូវ និងយុត្តិធម៌ ដែលជាលក្ខខណ្ឌចាំបាច់មួយសម្រាប់ការរីកចម្រើនប្រកបដោយចីរភាព ។
- កំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់របស់កម្ពុជា ដែលត្រូវបានជំរុញមួយផ្នែកធំដោយកំណើននៃការវិនិយោគទាំងក្នុង និងក្រៅប្រទេស ជាពិសេសការវិនិយោគពីសំណាក់ក្រុមហ៊ុនអន្តរជាតិធំៗ ដែលតែងតែដើរតួជាគំរូក្នុងការប្រឆាំងអំពើពុករលួយ និងការចុះ និងគម្រោងចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU)ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើពុករលួយ រវាង អ.ប.ព. និងក្រុមហ៊ុនជាច្រើន ដូចជា ក្រុមហ៊ុន Coca-Cola -ក្រុមហ៊ុន Prudential (Cambodia) Life Assurance - និងក្រុមហ៊ុន និងសមាគមពាណិជ្ជកម្មផ្សេងៗទៀត គឺជាសារវិជ្ជមានមួយទៀត ដែលស្តែងឱ្យឃើញថា ធុរកិច្ចស្អាតស្អំកំពុងចាក់ឫស និងរីកលូតលាស់ទៅមុខពីមួយថ្ងៃទៅមួយថ្ងៃនៅក្នុងសង្គមកម្ពុជា ។ អ.ប.ព. ជឿជាក់ថាសៀវភៅណែនាំ នឹងអាចធ្វើឱ្យឫសនៃភាពស្អាតស្អំកាន់តែចាក់ចូលជ្រៅទៅក្នុងសង្គមធុរកិច្ចនៅកម្ពុជា ។

- អ.ប.ព. រួមជាមួយនឹងដៃគូសំខាន់ៗរបស់ខ្លួន បន្តចូលរួម គាំទ្រ និងផ្តល់កិច្ចសហប្រតិបត្តិការតាមតម្រូវការចាំបាច់ គ្រប់ពេលជាមួយនឹងវិស័យឯកជនទូទៅលើការកសាងបរិយាកាសធុរកិច្ចស្អាតស្អំ និងជាពិសេសលើការងារប្រឆាំងអំពើពុករលួយនៅកម្ពុជា ៕

## ឯកសារយោង៖

1. មគ្គុទេសក៍ជាក់ស្តែង៖ កម្មវិធីក្រមសីលធម៌ប្រឆាំងអំពើពុករលួយ និងការអនុលោមតាមច្បាប់សម្រាប់ធុរកិច្ច ។ បោះពុម្ពដោយអង្គការ UNODC ឆ្នាំ ២០១៣
2. សៀវភៅណែនាំពីក្រមសីលធម៌ប្រឆាំងអំពើពុករលួយ និងការអនុលោមតាមច្បាប់សម្រាប់ធុរកិច្ច ។ បោះពុម្ពដោយអង្គការ UNODC ឆ្នាំ ២០១៣
3. គោលការណ៍ ១០ ចំណុចនៃអង្គការ UN Global Compact
4. កិច្ចពិគ្រោះយោបល់ជាមួយដៃគូក្នុងវិស័យឯកជន នៅកម្ពុជា ជាច្រើន ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១៖ សម្រង់មាត្រាមួយចំនួននៃច្បាប់ជាតិពាក់ព័ន្ធនឹងវិស័យឯកជន

1) *ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ (ឆ្នាំ២០១០)*

- **មាត្រា៤៖ និយមន័យ**

***-អ្នករាជការសាធារណៈ*** មានន័យថា៖

*ក-បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការ ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបាន ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុរបស់បុគ្គលនោះឡើយ ។*

*ខ-បុគ្គលឯទៀតដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។*

***-មន្ត្រីសាធារណៈបរទេស*** *មានន័យថា មន្ត្រីបរទេសដែលកាន់តំណែងក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការរបស់ប្រទេសក្រៅ ទោះជាបានតែងតាំង ឬបោះឆ្នោតជ្រើសរើសក៏ដោយ និងជនបរទេសដែលអនុវត្តមុខងារសាធារណៈសម្រាប់ប្រទេសក្រៅណាមួយ រួមមានទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ។*

***-មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ*** *មានន័យថា មន្ត្រីអន្តរជាតិ ឬជនណាដែលទទួលបានការអនុញ្ញាតពីអង្គការអន្តរជាតិឲ្យបំពេញភារកិច្ច ក្នុងនាមអង្គការអន្តរជាតិនោះ ។*

***-អត្ថប្រយោជន៍*** មានន័យថា៖

*ក-អំណោយអ្វីមួយ កម្ចី តម្លៃឈ្នួល រង្វាន់ ឬកម្រៃជើងសាដែលមិនមានការអនុញ្ញាតដោយច្បាប់ជាធរមាន ជាទឹកប្រាក់ ឬជាវត្ថុមានតម្លៃ ឬជាទ្រព្យសម្បត្តិប្រភេទអ្វីមួយ ។*

ខ-ការងារ តំណែង មុខងារ ការព្រមព្រៀង ឬកិច្ចសន្យាអ្វីមួយ ។

គ-ការបង់ប្រាក់ ការលើកលែង ការលុបចោល ការលុបបំបាត់នូវប្រាក់កម្ចីអ្វីមួយ កាតព្វកិច្ច ឬបំណុលដទៃទៀត ទោះជាទាំងមូលក្តី ឬដោយផ្នែកក្តី ។

ឃ-សេវាកម្មឯទៀត ឬការផ្តល់ជាគុណប្រយោជន៍ រួមទាំងកិច្ចការពារមិនឲ្យមានការដាក់ទណ្ឌកម្ម ដែលលេចចេញពីអំពើ ឬដំណើរការនៃការដាក់ទណ្ឌកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ទោះបីទណ្ឌកម្មនេះ ត្រូវបានកំណត់ ឬពុំទាន់ត្រូវបានកំណត់ក៏ដោយ ។

ង-ការអនុវត្ត ឬការរាំងមិនឲ្យអនុវត្តនូវសិទ្ធិ ឬអំណាច ឬភារកិច្ចអ្វីមួយ ។

ច-ការស្នើជូន ឬការសន្យាថាជូន ទោះបីមានលក្ខខណ្ឌ ឬគ្មានលក្ខខណ្ឌក្តី នូវអត្ថប្រយោជន៍ដូចមានចែងក្នុងកថាខណ្ឌ (ក) (ខ) (គ) (ឃ) និង(ង) ។

-**អំណោយ** មានន័យថា ទ្រព្យ ឬសេវាដែលត្រូវបានផ្តល់ឲ្យទៅបុគ្គលណាម្នាក់ ឬដើម្បីជាប្រយោជន៍ដល់បុគ្គលណាម្នាក់ ហើយដែលមិនត្រូវបានចាត់ទុកជាកិច្ចព្រមព្រៀង និងមិនមែនជាជំនូនតាមទំនៀមទម្លាប់ ឬប្រពៃណី ។

-**ទ្រព្យសម្បត្តិ** មានន័យថា ទ្រព្យគ្រប់ប្រភេទ ទោះជាចលនវត្ថុ ឬជាអចលនវត្ថុ រូបីយ ឬ អរូបីយ និងឯកសារគតិយុត្ត ឬលិខិតូបករណ៍ដែលបញ្ជាក់ពីកម្មសិទ្ធិ ឬផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិនោះ ។

- **មាត្រា៣៨៖ បទសូកប៉ាន់ចំពោះមន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលណាដែលគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលប្រគល់អំណោយ ឬជំនូន ឬធ្វើការសន្យាជាមួយ ឬផ្តល់អត្ថប្រយោជន៍អ្វីមួយដល់មន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ ដើម្បីឲ្យមន្ត្រីនោះ៖

១-បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

២-មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

- **មាត្រា ៤៧៖ ការផ្សាយចេញនូវកំណត់ត្រារបស់ធនាគារ**

គ្រឹះស្ថានឥណទាន ឬស្ថាប័នហិរញ្ញវត្ថុ រួចផុតពីការទទួលខុសត្រូវទាំងអស់ ហើយគ្មានបណ្តឹងព្រហ្មទណ្ឌណាមួយត្រូវបានធ្វើប្រឆាំងនឹងអ្នកដឹកនាំ ឬអាណត្តិនៃគ្រឹះស្ថាន ឬស្ថាប័ននោះឡើយ ប្រសិនបើប្រតិបត្តិការនោះត្រូវបានអនុវត្តស្របតាមបទប្បញ្ញត្តិច្បាប់ លើកលែងតែក្នុងករណីដែលរកឃើញថា មានការព្រមព្រៀងគ្នាជាមុន ដើម្បីរៀបចំបន្លំជាមួយម្ចាស់ប្រាក់ ឬអ្នកធ្វើប្រតិបត្តិការ ។

## 2) ក្រមព្រហ្មទណ្ឌ (ឆ្នាំ២០០៩)

- **មាត្រា២៧៨៖ បទស៊ីសំណូកនៃនិយោជិត**

អំពើប្រព្រឹត្តដោយនិយោជិត ដែលសុំ ឬយល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ ដើម្បីបំពេញ ឬមិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀងពីនិយោជកទេនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

- **មាត្រា២៧៩៖ បទសូកប៉ាន់ដល់និយោជិត**

បុគ្គលដែលប្រគល់ឲ្យនិយោជិតនូវអំណោយ ឬជូនជំនូន ធ្វើការសន្យាជាមួយ ឬយល់ព្រមឲ្យ អត្ថប្រយោជន៍អ្វីមួយដល់និយោជិត ដើម្បីឲ្យបំពេញ ឬមិនបំពេញ កិច្ចអ្វីមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀង ពីនិយោជកទេនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

- **មាត្រា២៨០៖ បទស៊ីសំណូករបស់អភិបាល ជាអាទិ៍**

១- បើបុគ្គលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ៣៩៣ (បទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬបុគ្គលផ្សេងទៀត) នៃក្រមនេះ ឬអធិការ បានទទួលផលប្រយោជន៍ជាទ្រព្យសម្បត្តិ ឬបានទាមទារ ឬបានសន្យាទទួលផលប្រយោជន៍នោះ ដោយបានទទួលការពឹងពាក់ខុសច្បាប់ បុគ្គលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

២- បទប្បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបុគ្គលដែលបានផ្តល់ផលប្រយោជន៍ដូចបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនោះ ឬបានស្នើសុំផ្តល់ ឬសន្យាផ្តល់ផលប្រយោជន៍នោះ ។

៣- ផលប្រយោជន៍ជាទ្រព្យសម្បត្តិដូចបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវដកហូត ។ បើមិនអាចដកហូតទាំងមូល ឬផ្នែកខ្លះនៃផលប្រយោជន៍នោះ ភាគដែលមិនអាចដកហូតយកបាន ត្រូវទារយកជាប្រាក់ ។

- **មាត្រា៣៨៧៖ បទដេញថ្លៃមិនត្រឹមត្រូវ**

អំពើប្រព្រឹត្ត នៅក្នុងការលក់ជាសាធារណៈ តាមការដេញថ្លៃ ដើម្បីកម្ចាត់អ្នកដេញថ្លៃ ឬធ្វើឲ្យខូចការដេញថ្លៃដោយអំណោយ ការសន្យា ការព្រមព្រៀង ឬតាមគ្រប់មធ្យោបាយទុច្ចរិតដទៃទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

- **មាត្រា៤០៤៖ និយមន័យនៃការសម្អាតប្រាក់**

ការសម្អាតប្រាក់ ជាអំពើផ្តល់ឲ្យតាមគ្រប់មធ្យោបាយនូវយុត្តិកម្មកុហក ដើម្បីលាក់បំបាំងអត្តប្រយោជន៍ផ្ទាល់ ឬប្រយោលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

ត្រូវចាត់ជាការសម្អាតប្រាក់ផងដែរ អំពើជួយដល់ប្រតិបត្តិការនៃការបណ្តាក់ទុន ការលាក់បំបាំង ឬការផ្លាស់ប្តូរផលផ្ទាល់ ឬប្រយោលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ។

- **មាត្រា៤០៥៖ ទោសដែលត្រូវអនុវត្ត**

ការសម្អាតប្រាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល រហូតស្មើនឹងតម្លៃមូលនិធិ ឬតម្លៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសម្អាតប្រាក់ ។

ក្នុងករណីបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិ ឬមូលនិធិដែលជាកម្មវត្ថុនៃការសម្អាតប្រាក់ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារធ្ងន់ជាងទោសដាក់ពន្ធនាគារ ដែលមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនោះ ការសម្អាតប្រាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដូចបទល្មើសដែលចារីបានដឹង ហើយក្នុងករណីបទល្មើសមានភ្ជាប់ មកជាមួយនូវស្ថាន

ទម្ងន់ទោសច្រើននោះ ចារីត្រូវទទួលទណ្ឌកម្ម ដោយយោងទៅតាមស្ថានទម្ងន់ទោស ដែលខ្លួនបានដឹងប៉ុណ្ណោះ ។

- **មាត្រា៤០៦៖ ស្ថានទម្ងន់ទោស**

ការសម្អាតប្រាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើបទល្មើសនេះ បានប្រព្រឹត្ត៖

១-ជាទម្លាប់ ។

២-ដោយប្រើភាពងាយស្រួល ដែលការប្រកបនូវសកម្មភាពវិជ្ជាជីវៈផ្តល់ឲ្យ ។

៣-ជាក្រុមមានការចាត់តាំង ។

- **មាត្រា៦០៥៖ បទសូកប៉ាន់**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលណាដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោល ប្រគល់អំណោយ ឬជំនូន ធ្វើការសន្យាជាមួយ ឬផ្តល់អត្ថប្រយោជន៍អ្វីមួយ ដល់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត ដើម្បីឲ្យអ្នករាជការ ឬពលរដ្ឋនោះ៖

1. បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយសារមុខងាររបស់ខ្លួន ។
2. មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយសារមុខងាររបស់ខ្លួន ។

### 3) ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យ សហគ្រាស និងវិជ្ជាជីវៈគណនេយ្យ (ឆ្នាំ២០០២)

- **មាត្រា ៤៖** រៀងរាល់ឆ្នាំ គ្រប់សហគ្រាសត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្រប តាមក្របខណ្ឌទស្សនទាន និងតាមបទដ្ឋានគណនេយ្យកម្ពុជា ដែលគោលការណ៍នានាត្រូវបានកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមរបៀបស្តង់ដារគណនេយ្យអន្តរជាតិ ។

- **មាត្រា ៥៖** គ្រប់សហគ្រាសត្រូវកាន់បញ្ជីគណនេយ្យរបស់ខ្លួននៅក្នុងសៀវភៅគណនេយ្យដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតាមរបៀបស្តង់ដារគណនេយ្យអន្តរជាតិ ។ រាល់ប្រតិបត្តិការគណនេយ្យ ត្រូវសំអាងលើឯកសារយុត្តិការ ។

- **មាត្រា ១២៖** របាយការណ៍ហិរញ្ញវត្ថុ ដែលទាក់ទងនឹងកិច្ចការគណនេយ្យ ព្រមទាំងសៀវភៅ និងឯកសារយុត្តិការនានាដែលពាក់ព័ន្ធ ត្រូវរក្សាទុកក្នុងរយៈពេល ១០ (ដប់)ឆ្នាំ យ៉ាងតិច ។ សៀវភៅទាំងនេះរួមមាន ទិនានុប្បវត្តិ សៀវភៅធំ និង សៀវភៅសារពើភណ្ឌ ។

- **មាត្រា ១៦៖** គ្រប់សហគ្រាសជារូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវដាក់បញ្ជីគណនេយ្យរបស់ខ្លួនឱ្យមានការត្រួតពិនិត្យដោយសវនករឯករាជ្យ ក្នុងករណីដែលចំនួនទឹកប្រាក់នៃផលរបរ ឬនិងចំនួនពិតសរុបរបស់តុល្យការ ឬនិងចំនួននិយោជិតរបស់ខ្លួនមានលើសពីកំរិតដែលបានកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការងារសវនកម្មត្រូវបំពេញដោយរូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានចុះឈ្មោះក្នុងបញ្ជីប្រតិស្រុត ។

### 4) ច្បាប់ស្តីពីសារពើពន្ធ (ឆ្នាំ១៩៩៧)

- **មាត្រា ១២៨៖** អំពើរាំងស្ទះការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ រួមមាន៖

<u>**១. ករណីដែលបុគ្គល៖**</u>

**ក.** មិនបានរក្សាបញ្ជីកាគណនេយ្យ និងឯកសារផ្សេងទៀតឬមិនបានចេញវិក្ក័យប័ត្រលើកិច្ចការជំនួញ ។

**ខ.** មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យឬ ឯកសារផ្សេងៗ ។

**គ.** មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ។

**ឃ.** មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ អំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី ដូចមានចែងក្នុងច្បាប់នេះ ។

**ង.** កសាងឬផ្តល់នូវកំណត់ត្រា ឯកសាររបាយការណ៍ឬពត៌មានក្លែងបន្លំផ្សេងៗ ។

**ច.** លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសាររបាយការណ៍ឬពត៌មានផ្សេងៗទៀត ។

**ឆ.** ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់និងការប្រមូលពន្ធ ។

**ជ.** មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធ ត្រូវបង់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់ ។

ឈ. ជួយជ្រោមជ្រែងដោយចេតនា ដល់អំពើទាំងឡាយខាងលើ ។

២. ករណីដែលមន្ត្រីរាជការ៖

ក. ធ្វើឱ្យធ្លាយពត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាតិ ។

ខ. ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់និងការប្រមូលពន្ធ ។

គ. ជួយជ្រោមជ្រែងដោយចេតនា ដល់អំពើទាំងឡាយខាងលើ ។

- **មាត្រា ១២៩៖** ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេសពន្ធដូចមានចែងក្នុង មាត្រា១២៧នៃច្បាប់នេះ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា១២៨នៃច្បាប់នេះ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទបញ្ញត្តិស្តីពីពន្ធដារ ។

## 5) ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ឆ្នាំ២០១២)

- **មាត្រា ៦៦៖**

អ្នកដេញថ្លៃ អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ ដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹង អំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬផ្តល់ភស្តុតាងក្លែងបន្លំ ឬមិនត្រឹមត្រូវក្នុងការដាក់ពាក្យប្តឹងតវ៉ានៅក្នុង ដំណើរការលទ្ធកម្ម ត្រូវបញ្ឈប់ជាបន្ទាន់ពីក្នុងលទ្ធកម្មសាធារណៈ ដែលកំពុងដំណើរការ ឬលុបកិច្ចសន្យាដែលកំពុងអនុវត្តភ្លាមៗ និងត្រូវកត់ត្រាចូលបញ្ជីខ្មៅ ។

ទណ្ឌកម្មនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

- **មាត្រា៦៨៖**

អំពើប្រព្រឹត្តនៅក្នុងដំណើរការលទ្ធកម្មសាធារណៈតាមការដេញថ្លៃ ដើម្បីកម្ចាត់អ្នកដេញថ្លៃ ឬធ្វើឲ្យខូចការដេញថ្លៃ ដោយអំណោយ ការសន្យា ការព្រមព្រៀង ឬតាមគ្រប់មធ្យោបាយទុច្ចរិតដទៃទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

- **មាត្រា៦៩៖**

អំពើប្រព្រឹត្តនៅក្នុងដំណើរការលទ្ធកម្មសាធារណៈតាមការដេញថ្លៃ ដើម្បីធ្វើជាឧបសគ្គដល់សេរីភាពនៃការដេញថ្លៃ ដោយហិង្សា ដោយការបង្ខិតបង្ខំ ឬដោយការគំរាមកំហែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

- **មាត្រា ៧២៖**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៦៨ និងមាត្រា៦៩ នៃច្បាប់នេះ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើនដូចមាន ចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

- **មាត្រា ៧៣៖**

បទល្មើសពុករលួយដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក៏ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយដែលជាអង្គភាពតែមួយគត់មានសមត្ថកិច្ចស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ ។

អង្គភាពនិងបុគ្គលដទៃទៀត ដែលបានដឹងពីបទល្មើសពុករលួយទាំងឡាយណាដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្តឹងទៅអង្គភាព ឬការិយាល័យរាជធានី ខេត្ត ប្រឆាំងអំពើពុករលួយអំពីរឿងហេតុនៃបទល្មើសទាំងនេះ ។

# ឧបសម្ព័ន្ធ ២៖ វិបសាយខ្លះពាក់ព័ន្ធនឹងកម្មវិធីប្រឆាំងអំពើពុករលួយ

1. Business Anti-Corruption Portal/Global Advice Network

   (www.business-anti-corruption.com)

2. UN Global Compact Anti-Corruption tools Inventory

   (www.business-anti-corruption.com/resources/anti-corruption-tools-inventory)

3. Coca-Cola Business Code of Conduct

   (www.coca-colacompany.com/investors/code-of-business-conduct/CBCC.pdf)

4. Siemens Business Conduct Guidelines

   (www.siemens.com/en/BCG.pdf)

5. IBM Business Code of Conduct

   (www.ibm.com/investors/governance/business-conduct-guidelines.pdf)